ឧបត្ថម្ភការបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលវប្បធម៌អាស៊ី-ប៉ាស៊ីហ្វិកនៃអង្គការយូណេស្កូ



# សៀវភៅ សិទ្ធិអ្នកនិពន្ធ អ្នកស្រុកអាស៊ី


និពន្ធដោយ តាម៉ុតស៊ុ ហុហ៊្សុយមី
បកប្រែជាភាសាខ្មែរដោយ លោកស្រី ជៀង យ៉ារិន
តុបតែងលម្អដោយ តារ៉ូ ហ្គោមី





ACCU
មជ្ឈមណ្ឌលវប្បធម៌អាស៊ី-ប៉ាស៊ីហ្វិកនៃអង្គការយូណេស្កូ
Asia/Pacific Cultural Centre for UNESCO

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
Ministry of Culture and Fine Arts

# សៀវភៅអ្នកនិពន្ធអ្នកស្រុកអាស៊ី

មជ្ឈមណ្ឌលវប្បធម៌អាស៊ី-ប៉ាស៊ីហ្វិកនៃអង្គការយូណេស្កូ (ACCU) ជាអង្គការមួយមិនរកប្រាក់កម្រៃសម្រាប់បំពេញសកម្មភាពនៅភូមិភាគអាស៊ីនិងប៉ាស៊ីហ្វិកតាមគោលការណ៍នៃអង្គការយូណេស្កូដើម្បីលើកកម្ពស់ការយល់ដឹងទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការវិស័យវប្បធម៌រវាងអ្នកស្រុកនៅក្នុងតំបន់។ តាំងពីបានចាប់ផ្តើមឡើងនាឆ្នាំ១៩៧១ មជ្ឈមណ្ឌលនេះអនុវត្តកម្មវិធីជួយសង្គ្រោះបេតិកភណ្ឌវប្បធម៌រូបីនិងអរូបី អភិវឌ្ឍផ្នែកសៀវភៅ និងការអប់រំអក្សរសាស្ត្រ ដោយរួមការងារជាមួយរដ្ឋទាំងឡាយនៅអាស៊ី និងប៉ាស៊ីហ្វិក ដែលជាសមាជិកនៃអង្គការយូណេស្កូ។

សៀវភៅដូចបានជម្រាបខាងលើសុទ្ធតែជាស្នាដៃនៃគំនិតបញ្ញា ការបង្កើតថ្មី និងវប្បធម៌របស់អ្នកស្រុក ដែលកំពុងរស់នៅគ្រប់ទីកន្លែងសម្រាប់រួមចំណែកធ្វើឱ្យកាន់តែសម្បូរឡើងនូវបេតិកភណ្ឌអរូបី និងកម្មសិទ្ធិបញ្ញានៅក្នុងភូមិភាគ។ ច្បាប់សិទ្ធិអ្នកនិពន្ធ ដើរតួនាទីយ៉ាងសំខាន់សម្រាប់ជំរុញសកម្មភាពនៅក្នុងប្រទេស និងក្រៅប្រទេសដើម្បីការពារសិទ្ធិអ្នកតែងនិពន្ធ អ្នកតុបតែងលម្អ និងជនទាំងឡាយដែលបង្កើតបានស្នាដៃ តាមរយៈការផ្តល់នូវនីតិវិធី។ ម្យ៉ាងវិញទៀត អាស្រ័យដោយការរីកចម្រើនឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថល និងការលួចស្នាដៃកាន់តែកើនឡើងៗ ទើបច្បាប់សិទ្ធិអ្នកនិពន្ធក្លាយជានយោបាយអាទិភាពរបស់អន្តរជាតិ។

សៀវភៅសិទ្ធិអ្នកនិពន្ធអ្នកស្រុកអាស៊ីនេះត្រូវបានគ្រោងនិងបោះពុម្ពផ្សាយសម្រាប់អ្នកស្រុកនៅប្រទេសក្នុងទ្វីបអាស៊ី ពិសេសសម្រាប់អ្នកផលិតសៀវភៅ ដូចជាអ្នកនិពន្ធ អ្នកកែសម្រួល អ្នកតុបតែងលម្អ អ្នកថតរូប។ល។ ដោយផ្តល់នូវទស្សនាទានសំខាន់ៗនិងចំណេះដឹងស្តីអំពីសិទ្ធិអ្នកនិពន្ធ ផ្តល់នូវគំនិត និងវិធីសម្រាប់អនុវត្ត។ ដើម្បីជំរុញឱ្យកាន់តែប្រសើរឡើងចំពោះសៀវភៅនេះមជ្ឈមណ្ឌលវប្បធម៌អាស៊ីប៉ាស៊ីហ្វិកនៃអង្គការយូណេស្កូមានផែនការរៀបចំសិក្ខាសាលាជាតិស្តីពីកិច្ចការពារសិទ្ធិអ្នកនិពន្ធ សម្រាប់ព្រាង កែសម្រួល និងបកប្រែជាភាសានៃប្រទេសនិមួយៗនៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក។ យើងសង្ឃឹមថា នាអនាគតអ្នកអានកាន់តែច្រើនឡើងនឹងរួមចំណែកផ្តល់មតិចំពោះសៀវភៅនេះ ហើយយើងជឿជាក់ថាមនុស្សទាំងនោះនឹងមានចំណេះដឹងកាន់តែប្រសើរឡើងក្នុងការបង្កើតថ្មី ដែលជាកត្តានាំមុខសម្រាប់ធ្វើឱ្យសម្បូរនូវបេតិកភណ្ឌវប្បធម៌នៅអាស៊ី។

មជ្ឈមណ្ឌលវប្បធម៌អាស៊ី-ប៉ាស៊ីហ្វិកនៃអង្គការយូណេស្កូ

# សៀវភៅ
# សិទ្ធិអ្នកនិពន្ធ
# អ្នកស្រុកអាស៊ី

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

Ministry of Culture and Fine Arts


និពន្ធដោយ តាម៉ុតស៊ុ ហូហ្ស៊ុយមី Tamotsu HOZUMI

បកប្រែជាភាសាខ្មែរដោយ លោកស្រី ជៀង យ៉ារិន CHEANG Yarin

សម្រួលអត្ថបទដោយ ស៊ឹម សារ៉ាក់ SIM Sarak

គុប៉តែងលម្អដោយ តារ៉ូ ហ្គោមី Taro GOMI



ACCU Asia/Pacific Cultural Centre for UNESCO

មជ្ឈមណ្ឌលវប្បធម៌អាស៊ី-ប៉ាស៊ីហ្វិកនៃអង្គការយូណេស្កូ

Asia/Pacific Cultural Centre for UNESCO

# សៀវភៅសិទ្ធិអ្នកនិពន្ធអ្នកស្រុកអាស៊ី

និពន្ធដោយ តាម៉ុតស៊ូ ហូហ៊្យុយមី
មជ្ឈមណ្ឌលវប្បធម៌អាស៊ី-ប៉ាស៊ីហ្វិកនៃអង្គការយូណេស្កូ ឆ្នាំ ២០០៩
បកប្រែជាភាសាខ្មែរដោយ លោកស្រី ជៀង យ៉ារិន
សម្រួលអត្ថបទដោយ ស៊ឹម សារ៉ាក់
តុបតែងលម្អ ដោយ តារ៉ូ ហ្គោមី

បោះពុម្ពផ្សាយជាភាសាខ្មែរលើកទី១ ខែកុម្ភៈ ឆ្នាំ២០០៩

ISBN-13: 978-99950-891-1-5

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលវប្បធម៌អាស៊ីប៉ាស៊ីហ្វិកនៃអង្គការយូណេស្កូ
បោះពុម្ពផ្សាយដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
©រក្សាសិទ្ធិគ្រប់យ៉ាង

បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា

ACCU

**Asia Pacific Cultural Centre for UNESCO**
Japan Publishers Building, N.6 Fukuromachi, Shijuku-ku,
Tokyo 162- 8484, Japan
Telephone: +81-3-3269-4435 Fascimile: +81-3-3269-4510
E-mail: general@accu.or.jp URL http: accu.or.jp

**Ministry of Culture and Fine Arts**
# 227, Preah Norodom Blvd, Phnom Penh, Cambodia.
Telephone : (855-23) 217 645
Fax : (855-23) 218 148

# សៀវភៅសិទ្ធិអ្នកនិពន្ធអ្នកស្រុកអាស៊ី

## មាតិកា


◆ **បុព្វកថា** ៧

**១ ស្លាដៃ** ១៣

បញ្ជីស្នាដៃ ១៤

**២ សិទ្ធិបេតិកភណ្ឌ សិទ្ធិសីលធម៌របស់អ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល** ១៧

សិទ្ធិអ្នកនិពន្ធ ១៨

សិទ្ធិបេតិកភណ្ឌ ២០

សិទ្ធិធ្វើអាជីវកម្មលើស្នាដៃបន្តនិងការប្រើប្រាស់ជាបន្ទាប់បន្សំស្នាដៃបោះផ្សាយ ២៦

សិទ្ធិសីលធម៌ ២៧

សិទ្ធិប្រហាក់ប្រហែល ២៩

រយៈពេលនៃកិច្ចការពារសិទ្ធិអ្នកនិពន្ធ ៣០

រយៈពេលនៃកិច្ចការពារសិទ្ធិបេតិកភណ្ឌ ៣០

រយៈពេលនៃកិច្ចការពារសិទ្ធិប្រហាក់ប្រហែល ៣១

**៣ មធ្យោបាយការពារស្នាដៃជាអន្តរជាតិ** ៣៣

**៤ អាជីវកម្មលើស្នាដៃអ្នកនិពន្ធ** ៣៧

វិធីនៃការធ្វើអាជីវកម្មលើស្នាដៃ ៣៩

ការកម្រិតសិទ្ធិអ្នកនិពន្ធ ៤០

ការផលិតឡើងវិញសម្រាប់ការប្រើប្រាស់ជាឯកជន ៤០

ភាពខុសគ្នារវាងអាជីវកម្មនិងអាគតដ្ឋាន ៤១

លក្ខខណ្ឌសម្រាប់អាគតដ្ឋាន ៤១

ការរំលោភបំពានលើសិទ្ធិអ្នកនិពន្ធ ៤២

**៥ ការប្រែប្រួលបរិស្ថានជុំវិញស្នាដៃ** ៤៥

ឌីជីថលនីយកម្ម បណ្តាញ (Networking) និងសិទ្ធិអ្នកនិពន្ធ ៤៨

**៦ សំណួរ និង ចម្លើយ** ៥០

ស&ច : តើចំណេះដឹងសៀវភៅ ការផ្សាយពាណិជ្ជកម្ម ។ល។ ជាស្នាដៃឬទេ? ៥០

ស&ច : តើគំនិតត្រូវទទួលបានកិច្ចការពារពីច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលដែរឬទេ? ៥០

ស&ច : តើនៅពេលណា ករណីណា ដែលស្នាដៃមួយមិនត្រូវបានទទួលនូវកិច្ចការពារពីច្បាប់? ៥០

ស&ច : តើសិទ្ធិអ្នកនិពន្ធចំពោះតំបន់បណ្តាញ (web site) មានដូចម្តេចដែរ? ៥១

ស&ច : តើអ្វីទៅជាស្នាដៃសហការ? ៥២

ស&ច : តើរឿងនិទានត្រូវទទួលកិច្ចការពារពីច្បាប់សិទ្ធិអ្នកនិពន្ធឬទេ? ៥២

ស&ច : តើបុគ្គលនិមួយៗអាចក្លាយជាអ្នកនិពន្ធបានឬទេ? ៥៣

ស&ច : តើអ្នកណាជាម្ចាស់នៃសិទ្ធិស្នាដៃបកប្រែ? ៥៣

ស&ច : តើកិច្ចការពារសិទ្ធិអ្នកនិពន្ធនៃប្រទេសពុំបានចូលរួមក្នុងសន្ធិសញ្ញាផ្សេងៗដូចម្តេចដែរ? ៥៤

ស&ច : សំណួរផ្សេងៗពាក់ព័ន្ធនឹងអាគតដ្ឋាន ៥៤

ស&ច : សំណួរដកស្រង់ពីសិក្ខាសាលាបណ្តុះបណ្តាលថ្នាក់ជាតិស្តីពីចំណេះដឹងសិទ្ធិអ្នកនិពន្ធ ៥៩

**៧ សេចក្តីបន្ថែម** ៦៥

អនុសញ្ញា សន្ធិសញ្ញា និងនិន្នាការអន្តរជាតិ ៦៦

ប្រជាជាតិជាសមាជិកនៃអង្គការអន្តរជាតិ ៧៣



# បុព្វកថា





សិទ្ធិអ្នកនិពន្ធជាផ្នែកមួយនៃសិទ្ធិមនុស្សដែលមានចែងក្នុងសេចក្តីប្រកាសសាកលស្តីពីសិទ្ធិមនុស្ស និងក្នុងកិច្ចព្រមព្រៀងអន្តរជាតិរបស់អង្គការសហប្រជាជាតិ និងជាច្បាប់ដ៏សំខាន់មួយសម្រាប់ការពារសិទ្ធិលើស្នាដៃវប្បធម៌។ ស្នាដៃមួយនៃវប្បធម៌ជាស្នាដៃដែលមនុស្សបង្កើតឡើងដើម្បីធ្វើឱ្យប្រសើរឡើងនូវចិត្តគំនិត និងការត្រិះរិះពិចារណារបស់មនុស្ស។ ស្នាដៃវប្បធម៌មិនរាប់បញ្ចូលនូវការបង្កើតគ្រឿងម៉ាស៊ីន ឬបច្ចេកវិទ្យា ដែលរួមចំណែកដោយចំពោះសម្រាប់បង្កើនភាពងាយស្រួលនៃរបៀបរស់នៅនិងការងារ។ វត្ថុទាំងអស់នោះមិនចាត់ទុកជាស្នាដៃវប្បធម៌ឡើយព្រោះជាការទាក់ទងសំខាន់ទៅនឹងការអភិវឌ្ឍបច្ចេកវិទ្យានៃអារ្យធម៌ ដូច្នេះហើយទើបច្បាប់ការពារសិទ្ធិលើវត្ថុទាំងនោះ ជាច្បាប់ផ្សេងពីសិទ្ធិអ្នកនិពន្ធ។ ឧទាហរណ៍ ដូចជាច្បាប់ប្រកាសនីយបត្រតក្កកម្មសម្រាប់ការពារសិទ្ធិមនុស្សទាំងឡាយណាដែលបានបង្កើតបច្ចេកវិទ្យា និងគ្រឿងយន្ត។ ច្បាប់ពាណិជ្ជនាមសម្រាប់ការពារផលិតផល ម៉ាកទំនិញ និងសញ្ញាក្រុមហ៊ុន។ល។ ច្បាប់សិទ្ធិគំនូរឧស្សាហកម្មសម្រាប់ការពារផលិតផលគំនូរឧស្សាហកម្ម។ សិទ្ធិទាំងនោះហៅថា "សិទ្ធិកម្មសិទ្ធិឧស្សាហកម្ម"។ មនុស្សបានចំណាយពេលវេលាខិតខំពិចារណាដើម្បីប្រែក្លាយមនុស្សឱ្យមានគំនិតបង្កបង្កើត និងអាចបង្កើតជាផលិតផល ដែលរួមចំណែកចំពោះការអភិវឌ្ឍវប្បធម៌ ឬអារ្យធម៌។ ច្បាប់ការពារសិទ្ធិដែលបានរៀបរាប់ខាងលើ ជាទូទៅគេហៅថា "ច្បាប់កម្មសិទ្ធិបញ្ញា"។

ខ្ញុំសូមអនុញ្ញាតពន្យល់លម្អិតអំពីនិយមន័យនៃស្នាដៃវប្បធម៌។ ស្នាដៃនេះសមស្របទៅនឹងការពិចារណា និងចិត្តគំនិត ដូច្នេះពាក្យស្នាដៃវប្បធម៌រួមមានគ្រប់ទម្រង់នៃអក្សរសិល្ប៍ ដូចជាប្រលោមលោក កំណាព្យ ឬឈុតរឿង ក៏ដូចជា គ្រប់ទម្រង់នៃការសម្តែងគំនិត មានរូបគំនូរ តូរ្យតន្ត្រី ភាពយន្ត និងលទ្ធផលនៃការសិក្សាខាងវិទ្យាសាស្ត្រស្មុគ្រស្មាញ។ ស្នាដៃវប្បធម៌អាចមាននិយមន័យជាការសម្តែងចេញនូវការបង្កបង្កើតដោយគំនិតបញ្ញា និងមនោសញ្ចេតនារបស់មនុស្ស។ ការសម្តែងចេញបែបនេះ អាចមានឥទ្ធិពលលើចិត្តគំនិត និងការរំភើបរបស់មនុស្សផ្សេងទៀត។ តើលោកអ្នកធ្លាប់រំជួលចិត្តទេពេលកំពុងអានអក្សរសិល្ប៍ កំពុងទស្សនាផ្ទាំងគំនូរស្រស់បំព្រង កំពុងស្តាប់តន្ត្រី កំពុងទស្សនាខ្សែភាពយន្តមួយ ដែលផ្តល់ឱ្យលោកអ្នកនូវបទពិសោធនៃពិភពលោកមួយប្លែកទាំងស្រុង? ការទទួលអារម្មណ៍បែបនេះ មិនមែនសុទ្ធតែនាំឱ្យយើងសប្បាយឬសុខស្រួលឡើយ ជួនកាលអាចនាំឱ្យយើងព្រួយចិត្ត ធ្លាក់ទឹកចិត្ត ឬបង្កឱ្យយើងគិតមិនឈប់ឈរ។ ការសម្តែងសិល្បៈ ផ្តល់ចំណេះដឹងផ្ទាល់ដល់ការគិតគូរពិចារណា និងមនោសញ្ចេតនា ហើយបង្កឱ្យយើងមានការផ្លាស់ប្តូរនូវការយល់ដឹង។

ដើម្បីរស់រានមានជីវិតមនុស្សត្រូវបរិភោគអាហារ។ ម្ហូបអាហារមានសារប្រយោជន៍សម្រាប់ទ្រទ្រង់រូបរាងកាយមនុស្ស។ ការបរិភោគអាហារផ្តល់ឱ្យរូបរាងកាយធំធាត់ និងធ្វើឱ្យមានជីវិត តែមនុស្សយើងត្រូវបានអភិវឌ្ឍឆាប់រហ័សពីមនុស្សបុព្វកាល ដោយមិនត្រឹមតែរីកធំធាត់ខាងរូបរាងកាយទេថែមទាំងរីកចម្រើនខាងគំនិតបញ្ញានិងមនោសញ្ចេតនាទៀតផង។ ដើម្បីងាយយល់ដឹងឱ្យបានច្រើនជាងនេះពីនិយមន័យនៃស្នាដៃវប្បធម៌ លោកអ្នកគួរគិតថា ស្នាដៃវប្បធម៌ជាម្ហូបអាហារសម្រាប់ធ្វើឱ្យរំភើបចិត្តនិងធ្វើឱ្យមានបញ្ញា។ លោកអ្នកគួរនឹកស្រមៃថាពិភពលោកមួយគ្មានស្នាដៃវប្បធម៌សម្រាប់បង្កើតព្រលឹង ឬបណ្តុះចំណេះដឹងមនុស្ស តើពិភពលោកនោះហាក់បីដូចជាគ្មានសៀវភៅប្រលោមលោក គ្មានកំណាព្យ គ្មានតូរ្យតន្ត្រី ឬគ្មានផ្ទាំងគំនូរមែនឬទេ ? ស្នាដៃវប្បធម៌ដែលផ្តល់ទ្រព្យសម្បត្តិជាចំណេះដឹង គឺជាបេតិកភណ្ឌមានតម្លៃដូចត្បូងពេជ្រត្រូវបានអភិរក្សឱ្យគង់វង្សក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ។ ការអភិរក្សកើតមានតាំងពីយូរមកហើយ គឺមុនពេលកើតមានគំនិតស្តីពីសិទ្ធិអ្នកនិពន្ធទៅទៀត។ ច្រើនឆ្នាំកន្លងទៅ ស្នាដៃវប្បធម៌បានក្លាយជា បេតិកភណ្ឌវប្បធម៌នៃកុលសម្ព័ន្ធមួយក្នុងតំបន់មួយ ឬក្នុងប្រទេសមួយ។ ជាមួយគ្នានោះដែរនៅពេលដែលមនុស្សបានកើតឡើងក្នុងសម័យនិមួយៗ មនុស្សបានទទួលឥទ្ធិពលពីបេតិកភណ្ឌវប្បធម៌ ហើយពួកគេក៏បានបង្កើតស្នាដៃថ្មីៗបំពេញបន្ថែមទៀត ធ្វើឱ្យបេតិកភណ្ឌវប្បធម៌មានការអភិវឌ្ឍឡើង។ ស្នាដៃវប្បធម៌ទាំងអស់នោះហើយដែលបន្តទ្រទ្រង់មនុស្សរហូតសព្វថ្ងៃ។ ខ្ញុំជឿជាក់ថា ស្នាដៃវប្បធម៌ពិតជាមានសារប្រយោជន៍ចំពោះជីវភាពរស់នៅរបស់មនុស្សជាតិ។ ទស្សនៈស្តីពីពាក្យសិទ្ធិអ្នកនិពន្ធ កើតចេញពីគំនិត ហើយក្លាយជាច្បាប់ការពារសិទ្ធិលើស្នាដៃវប្បធម៌ ដែលគួរតែត្រូវបានផ្តល់អត្ថន័យ និងការពារ ហើយអ្នកដែលបានបង្កើតស្នាដៃគួរតែត្រូវបានការពារក្នុងសង្គមនិងក្នុងវិស័យសេដ្ឋកិច្ច។

សៀវភៅមគ្គុទ្ទេសក៏នេះ សរសេរឡើងសម្រាប់មនុស្សគ្រប់គ្នានៅទ្វីបអាស៊ី រួមទាំងអ្នកបង្កបង្កើតសម្រេចបានជាស្នាដៃវប្បធម៌ និងអ្នកដែលប្រើប្រាស់ស្នាដៃទាំងនោះ។ ខ្ញុំសង្ឃឹមថាសៀវភៅនេះនឹងផ្ដល់ចំណេះដឹងជ្រៅជ្រះស្ដីពីគំនិត សិទ្ធិអ្នកនិពន្ធ។ ខ្ញុំសប្បាយរីករាយជាអតិបរមា បើសៀវភៅនេះរួមចំណែកចំពោះកិច្ចការពារស្នាដៃ និងការប្រើប្រាស់ស្នាដៃ ដែលជាស្នាដៃជួយអភិវឌ្ឍព្រលឹង ក៏ដូចជាការរួមចំណែកគាំទ្រការខិតខំរបស់អ្នកពាក់ព័ន្ធនឹងសិទ្ធិអ្នកនិពន្ធ។ សេចក្ដីប៉ងប្រាថ្នាដ៏ធំធេងរបស់ខ្ញុំមិនត្រឹមតែផ្ដល់ចំណេះដឹងចំពោះអ្នកបានបង្កបង្កើតស្នាដៃ ដូចជាអ្នកនិពន្ធ វិចិត្រករ អ្នកសរសេរឃុតល្ខោន ឬភាពយន្ត អ្នករចនាកវី តន្ត្រីករ អ្នកធ្វើការក្នុងបណ្ដាញសារពត៌មាន ការបោះផ្សាយ ទូរផ្សាយ រោងពុម្ព និងក្នុងការផ្សាយពាណិជ្ជកម្មប៉ុណ្ណោះទេ ថែមទាំងចំពោះអ្នកប្រើប្រាស់ស្នាដៃ ដូចជាសិស្សានុសិស្ស និស្សិត និងសាធារណជនទូទៅ អ្នកទាំងឡាយដែលសង្ឃឹមថានឹងធ្វើការងារបង្កើតស្នាដៃវប្បធម៌ អ្នកដែលទទួលខុសត្រូវគាំទ្រកិច្ចការសិទ្ធិអ្នកនិពន្ធពេលបច្ចុប្បន្ន និងអនាគត ព្រមទាំងអ្នកដែលនឹងអានសៀវភៅនេះទៀតផង។

ទោះបីអ្នកខ្លះត្អូញត្អែរថា មានការលំបាកក្នុងការយល់ដឹងអំពីច្បាប់សិទ្ធិអ្នកនិពន្ធ តែតាមការពិតជាច្បាប់ងាយយល់និងសាមញ្ញ។ ច្បាប់សិទ្ធិអ្នកនិពន្ធ រួមមានច្បាប់ទាំងអស់ពាក់ព័ន្ធនឹងសិទ្ធិអ្នកនិពន្ធប្រកបដោយបទប្បញ្ញត្តិត្រឹមត្រូវ និងសមស្របណាស់ ដែលមនុស្សគ្រប់គ្នាអាចទទួលយកបាន ដូចជាត្រូវគោរពស្នាដៃដែលអ្នកផ្សេងបានខិតខំបង្កើត និងត្រូវតែធ្វើកិច្ចសន្យាសុខចិត្តព្រមបង់ប្រាក់កម្រៃចំពោះបុព្វសិទ្ធិ បើលោកអ្នកចង់ប្រើប្រាស់ស្នាដៃនោះ។ សិទ្ធិអ្នកនិពន្ធ ជាសិទ្ធិដ៏សំខាន់នៃយើងទាំងអស់គ្នា ព្រោះតាមរយៈការគោរពបទប្បញ្ញត្តិ ដែលមានចែងក្នុងច្បាប់ ផ្ដល់ជាកម្លាំងជំរុញឱ្យយើងបង្កបង្កើតស្នាដៃវប្បធម៌ឱ្យបានសម្បូរ។

សព្វថ្ងៃនេះ គ្រប់ប្រទេសនៅទ្វីបអាស៊ី និងប្រទេសជាច្រើនក្នុងសកលលោកមានច្បាប់សិទ្ធិអ្នកនិពន្ធ។



ដូចបានជម្រាបជូនរួចមកហើយ ច្បាប់សិទ្ធិអ្នកនិពន្ធទទួលស្គាល់ជនដែលបង្កើតបាននូវស្នាដៃវប្បធម៌ហើយជននោះមានសិទ្ធិផ្តាច់មុខលើស្នាដៃនិងធានាទទួលបាននូវផលប្រយោជន៍ពេលណាមានអ្នកផ្សេងធ្វើអាជីវកម្មលើស្នាដៃរបស់ខ្លួន។ ពាក្យ **"ស្នាដៃ"** ក្នុងសៀវភៅនេះ មានន័យថា ផលិតផលដើមខាងវិស័យអក្សរសាស្ត្រ វិទ្យាសាស្ត្រ សិល្បៈ ឬ តូរ្យតន្ត្រី កើតចេញពីការច្នៃប្រឌិតបង្កើតឡើងដោយគំនិតប្រាជ្ញា ឬមនោសញ្ចេតនា។ ជនជាអ្នកបង្កើតបានស្នាដៃ ហៅថា **អ្នកនិពន្ធ**។ ដោយសិទ្ធិអ្នកនិពន្ធត្រូវបានច្បាប់ប្រគល់ឱ្យចំពោះជនដែលបង្កើតបានស្នាដៃ ទើបជននោះទទួលបានសិទ្ធិ តាមច្បាប់ត្រូវហៅថា **សិទ្ធិអ្នកនិពន្ធ**។ តាមពិតជនដែលមានសិទ្ធិគ្រប់គ្រងលើស្នាដៃមួយ គឺត្រូវបានទទួលស្គាល់ដោយច្បាប់ថាជាម្ចាស់កម្មសិទ្ធ**ស្នាដៃអ្នកនិពន្ធ**។ មានករណីជាច្រើន ដែលម្ចាស់កម្មសិទ្ធិលើស្នាដៃអ្នកនិពន្ធ គឺជាអ្នកនិពន្ធ តែទោះបីយ៉ាងណាក៏ដោយ ពេលដែលម្ចាស់កម្មសិទ្ធិស្នាដៃអ្នកនិពន្ធមានសិទ្ធិផ្ទេរ **(លក់)** ជូល ឬចែកជាមរតកនូវសិទ្ធិបេតិកភណ្ឌនៃស្នាដៃរបស់ខ្លួន (**អានទំព័រ១៨** ) ឱ្យទៅបុគ្គល ឬក្រុមហ៊ុនណាមួយ នោះក៏នឹងមានការផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិ លើស្នាដៃអ្នកនិពន្ធ ។ មានន័យថា ម្ចាស់កម្មសិទ្ធិលើស្នាដៃអ្នកនិពន្ធមិនមែនសុទ្ធតែជាអ្នកនិពន្ធទាំងអស់ឡើយ។

បើលោកអ្នកប្រៀបធៀបច្បាប់សិទ្ធិអ្នកនិពន្ធនៃប្រទេសនិមួយៗនៅអាស៊ី លោកអ្នកនឹងរកឃើញភាពខុសគ្នាតិចតួចស្តីពីរយៈពេល និងគំនិត។ ការបកស្រាយដ៏តឹងរឹងអំពីច្បាប់ ទំនងជាបង្ហាញឱ្យឃើញថាវត្ថុមួយដែលត្រូវការពារក្នុងប្រទេសមួយ មិនត្រូវបានការពារនៅក្នុងប្រទេសមួយផ្សេងទេ។ ទោះបីយ៉ាងណាក៏ដោយ ក៏ភាពខុសគ្នាមានតិចតួចបំផុត ពេលដែលសន្ធិសញ្ញាអន្តរជាតិបានជួយបង្កើតឱ្យមានការព្រមព្រៀងគ្នាចំពោះកិច្ចការពារសិទ្ធិអ្នកនិពន្ធ។ ជាដំបូងយើងត្រូវពិនិត្យមើលខ្លឹមសារជាមូលដ្ឋានស្តីពីសិទ្ធិអ្នកនិពន្ធ ដែលចែករំលែកឱ្យគ្នាទៅវិញទៅមកនៅគ្រប់ប្រទេស។ ខ្ញុំសង្ឃឹមថា សៀវភៅមគ្គុទ្ទេសក៍នេះនឹងបម្រើជាស្តង់ដាមួយរបស់សិទ្ធិអ្នកនិពន្ធនៅក្នុងភូមិភាគអាស៊ី។

# ១ ស្នាដៃ



# ១ ស្នាដៃ

តើអ្វីខ្លះដែលត្រូវទទួលស្គាល់ថាជា **ស្នាដៃ** មានកិច្ចការពារពីច្បាប់? សូមមើលប្រភេទនៃស្នាដៃដែលទទួលនូវកិច្ចការពារពីច្បាប់ជាអន្តរជាតិនិងក្នុងទ្វីបអាស៊ី។ នៅប្រទេសជប៉ុន ស្នាដៃត្រូវបែងចែកជាប្រភេទដូចតទៅ ៖

**ស្នាដៃអក្សរសាស្ត្រ ៖ ប្រលោមលោក ស្នាដៃសាកល្បង ឈុតរឿង កំណាព្យ។ល។**

**ស្នាដៃតន្ត្រី ៖ អក្សរភ្លេង ទំនុកច្រៀង ។ល។**

**ស្នាដៃរបាំនិងកាយវិការ ៖ របាំនាដសាស្ត្រ ដូចជារបាំបុរាណ ឬរបាំសម័យទំនើប និងកាយវិការ ។ល។**

**ស្នាដៃសិល្បៈសូនរូប ៖ រូបគំនូរ ការឆ្លាក់ពុម្ព រូបចម្លាក់ គំនូរតុក្កតា អក្សរសិល្បៈ ឆាកសម្តែងសិល្បៈសិប្បកម្ម ។ល។**

**ស្នាដៃស្ថាបត្យកម្ម ៖ គំនូរស្ថាបត្យកម្ម និងអគារ ។**

**ផែនទី និងដ្យាក្រាម ៖ ផែនទី ប្លង់លម្អិត (blueprints) ដ្យាក្រាម គំនូររចនា រូបភាពពន្យល់ ម៉ូដែល ។ល។**

**ភាពយន្ត ៖ ខ្សែភាពយន្ត កម្មវិធីទូរទស្សន៍ វីដេអូហ្គេមផ្នែកទន់ ។ល។**

**រូបថត ៖ រូបថត រូបថតស្លឺសេ ។ល។**

**កម្មវិធី ៖ កម្មវិធីកុំព្យូទ័រ ។ល។**

ប្រភេទនៃស្នាដៃផ្សេងទៀតដែលត្រូវទទួលនូវកិច្ចការពារស្របច្បាប់ រួមមានស្នាដៃបកប្រែ ស្នាដៃសម្រួល ស្នាដៃកែលម្អ ស្នាដៃយកលំនាំតាមស្នាដៃដើម (ស្នាដៃបន្ត) និងស្នាដៃកែសម្រួលដូចជាឯកសារសមោធាន កំណាព្យសម្រាំង ទស្សនាវដ្ដី និងកាសែត (ស្នាដៃចងក្រង)។ ចំណុចសំខាន់ត្រូវចងចាំគឺប្រភេទនៃស្នាដៃដែលត្រូវទទួលនូវកិច្ចការពារពីច្បាប់។ (សូមពិនិត្យច្បាប់សិទ្ធិអ្នកនិពន្ធនៃប្រទេសនិមួយៗដើម្បីបញ្ជាក់សម្គាល់នូវប្រភេទនៃស្នាដៃ។)

# ២ សិទ្ធិបេតិកភណ្ឌ និងសិទ្ធិសីលធម៌ របស់អ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល



# ២ សិទ្ធិបេតិកភណ្ឌ និងសិទ្ធិសីលធម៌របស់អ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

ផ្នែកនេះនឹងអធិប្បាយលម្អិតអំពីសិទ្ធិរបស់អ្នកនិពន្ធដែលរួមមានសិទ្ធិបេតិកភណ្ឌ និងសិទ្ធិសីលធម៌ ព្រមទាំងសិទ្ធិប្រហាក់ប្រហែលដែលជាកម្មសិទ្ធិរបស់អ្នកបញ្ជូនស្នាដៃ។

## សិទ្ធិអ្នកនិពន្ធ

ដូចខ្ញុំបានពន្យល់នៅខាងដើមហើយ សិទ្ធិអ្នកនិពន្ធសម្រាប់ការពារស្នាដៃវប្បធម៌ ដូច្នេះសិទ្ធិនេះមានភាពខុសគ្នាបន្តិចបន្តួចពីសិទ្ធិផ្សេងៗទៀត។ ឧទាហរណ៍ បុគ្គលម្នាក់ជាម្ចាស់លើវត្ថុអ្វីមួយ វត្ថុនោះត្រូវគេទទួលស្គាល់ថាមានម្ចាស់គ្រប់គ្រងដែលគេហៅថា ម្ចាស់កម្មសិទ្ធិ ឬអ្នកមានសិទ្ធិជាម្ចាស់លើទ្រព្យសម្បត្តិ។ សិទ្ធិជាម្ចាស់លើទ្រព្យសម្បត្តិអាចត្រូវផ្ទេរឱ្យបុគ្គលផ្សេងទៀត។ ដោយសារសិទ្ធិអ្នកនិពន្ធជាសិទ្ធិនៃម្ចាស់កម្មសិទ្ធិ ហើយសិទ្ធិនោះអាចត្រូវផ្ទេរឱ្យអ្នកដទៃបាន ទើបសិទ្ធិនោះត្រូវគេហៅថា "សិទ្ធិបេតិកភណ្ឌ"។ តាមពាក្យផ្សេងទៀតគេអាចហៅថា សិទ្ធិអាចទទួលបានជាប្រាក់កាស។ លើសពីនេះដោយសារសិទ្ធិនេះបានមកពីលទ្ធផលនៃការបង្កើតស្នាដៃដែលប្រើគំនិតបញ្ញា ទើបត្រូវចាត់ទុកថាជាកម្មសិទ្ធិបញ្ញា (សិទ្ធិជាម្ចាស់លើទ្រព្យសម្បត្តិខាងបញ្ញា) ដូចជាសិទ្ធិប្រកាសនីយបត្រតក្កកម្ម សិទ្ធិគំនូរឧស្សាហកម្ម និងសិទ្ធិពាណិជ្ជនាម។

តើសិទ្ធិអ្នកនិពន្ធមានន័យថាជាផ្នែកសាមញ្ញមួយនៃសិទ្ធិលើទ្រព្យសម្បត្តិ?



ប្រទេសទាំងឡាយដែលអនុវត្តច្បាប់តាមបែបប្រទេសអង់គ្លេសនិងអាមេរិក ជាប្រវត្តិសាស្ត្រ ប្រទេសទាំងនោះបានផ្តល់សារសំខាន់ទៅលើលក្ខណៈសម្បត្តិនៃសិទ្ធិបេតិកភណ្ឌរបស់សិទ្ធិអ្នកនិពន្ធ។ សិទ្ធិអ្នកនិពន្ធ តាមភាសាអង់គ្លេសគេប្រើ ពាក្យ “copyright” មានន័យថាសិទ្ធិចម្លង ហើយសិទ្ធិចម្លងនេះផ្តល់សិទ្ធិសម្រាប់ផលិតឡើងវិញនូវស្នាដៃមួយ។ ផ្ទុយទៅវិញ ប្រទេសផ្សេងៗទៀត ដូចជាប្រទេសបារាំង និងប្រទេសអាល្លឺម៉ង់ចាត់ទុក សិទ្ធិសីលធម៌សំខាន់ជាង ដែលជាទស្សនៈមួយទទួលឥទ្ធិពលពីការអភិវឌ្ឍនៃគំនិតសង្គមក្នុងទ្វីបអឺរ៉ុប។ យោលទៅលើភាសាបារាំង និងអាល្លឺម៉ង់ កិច្ចការសិទ្ធិអ្នកនិពន្ធគឺគេប្រើពាក្យថា សិទ្ធិអ្នកនិពន្ធ។ ជាសេចក្តីសង្ខេប ប្រទេសទាំងនោះផ្តល់សារប្រយោជន៍ទៅលើទស្សនៈការពារពិភពបញ្ញារបស់អ្នកនិពន្ធ គឺការពារទស្សនៈ និងអ្នកដែលមានគំនិតបញ្ញាជាងការឱ្យតម្លៃទៅលើទ្រព្យសម្បត្តិជាស្នាដៃ ដែលបានផលិតឡើងច្រើនច្បាប់សម្រាប់លក់ដូរ។ ដូច្នេះគំនិតស្តីពីសិទ្ធិអ្នកនិពន្ធមានលក្ខណៈសម្បត្តិពីរផ្សេងគ្នា គឺសិទ្ធិបេតិកភណ្ឌនិងសិទ្ធិសីលធម៌ ដែលបានអភិវឌ្ឍមុនគេនៅអឺរ៉ុប។ ទស្សនៈនេះត្រូវបានផ្សព្វផ្សាយទៅកាន់ទ្វីបអាស៊ីស្ទើរតែគ្រប់ប្រទេសចាប់តាំងពីពាក់កណ្តាលសតវត្សទី២០ រហូតចុងសតវត្សទី២០។

តាមការពន្យល់ខាងលើ លោកអ្នកអាចមើលឃើញថា សិទ្ធិអ្នកនិពន្ធមានលក្ខណៈសម្បត្តិពីរធំៗ : សិទ្ធិបេតិកភណ្ឌ និងសិទ្ធិសីលធម៌របស់អ្នកនិពន្ធ។ យើងត្រូវតែយកចិត្តទុកដាក់នៅពេលប្រើពាក្យសិទ្ធិអ្នកនិពន្ធ។ មនុស្សជាច្រើនប្រើពាក្យសិទ្ធិអ្នកនិពន្ធមានន័យសាមញ្ញថា សិទ្ធិជាម្ចាស់ទ្រព្យសម្បត្តិលើស្នាដៃ ឯមនុស្សផ្សេងទៀតឱ្យនិយមន័យបញ្ចូលគ្នាទាំងពីរលក្ខណៈសម្បត្តិ គឺសិទ្ធិជាម្ចាស់សិទ្ធិបេតិកភណ្ឌ និងសិទ្ធិ

សីលធម៌។ ក្នុងសៀវភៅនេះ ខ្ញុំនឹងប្រើពាក្យសិទ្ធិអ្នកនិពន្ធបញ្ជាក់ពីសិទ្ធិទាំងអស់ គឺពាក្យសិទ្ធិបេតិកភណ្ឌបង្ហាញពីសិទ្ធិជាម្ចាស់ទ្រព្យសម្បត្តិលើស្នាដៃ និងសិទ្ធិសីលធម៌បង្ហាញពីសិទ្ធិជាម្ចាស់លើសិទ្ធិសីលធម៌របស់អ្នកនិពន្ធ។ ជាសំខាន់ត្រូវយល់ដឹងថា សិទ្ធិអ្នកនិពន្ធគឺសិទ្ធិមនុស្សជាសាកលដែលមានចែងច្បាស់លាស់ក្នុងសេចក្តីប្រកាស និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិមនុស្ស។ សិទ្ធិបេតិកភណ្ឌដែលទទួលស្គាល់ដោយច្បាប់នៅគ្រប់ប្រទេសចែងថា បុគ្គលណាយកស្នាដៃអ្នកដទៃ ហើយធ្វើអាជីវកម្មលើស្នាដៃនោះដោយគ្មានសុំការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ បុគ្គលនោះត្រូវចាត់ទុកថាជាជនល្មើសច្បាប់។ ប្រហែលគ្នានេះដែរ សិទ្ធិសីលធម៌ក៏ត្រូវច្បាប់ការពារមិនឱ្យមានការរំលោភបំពានឡើយ។

## សិទ្ធិបេតិកភណ្ឌលើស្នាដៃ

ផ្នែកនេះពន្យល់អំពីខ្លឹមសារនៃសិទ្ធិអ្នកនិពន្ធ។ យើងផ្តើមចេញពីសិទ្ធិបេតិកភណ្ឌលើស្នាដៃ ដែលមនុស្សភាគច្រើនយល់ជាសាមញ្ញថា សិទ្ធិអ្នកនិពន្ធ។ សិទ្ធិបេតិកភណ្ឌលើស្នាដៃអាចត្រូវបែងចែកជាច្រើនប្រភេទដូចខាងក្រោម :
១-សិទ្ធិផលិតឡើងវិញ។ ២-សិទ្ធិសម្តែង។ ៣-សិទ្ធិបញ្ចាំង។ ៤-សិទ្ធិផ្សព្វផ្សាយជាសាធារណៈ។ ៥-សិទ្ធិសូត្រ។ ៦-សិទ្ធិតាំងពិព័រណ៍។ ៧-សិទ្ធិចែកចាយ ផ្ទេរកម្មសិទ្ធិ និងជួល។ ៨-សិទ្ធិបកប្រែ សម្រួលកែសម្រួល និងយកលំនាំតាម។ ៩-សិទ្ធិធ្វើអាជីវកម្មលើស្នាដៃបន្ត។

ប្រទេសនិមួយៗ តិចឬច្រើនតែងតែបែងចែកសិទ្ធិជាច្រើនប្រភេទនូវសិទ្ធិបេតិកភណ្ឌតាមវិធីដូចបានរៀបរាប់ (ពីព្រោះសិទ្ធិទាំងនោះបែងចែកចេញពីសិទ្ធិផ្តាច់មុខនៃសិទ្ធិអ្នកនិពន្ធដែលពាក្យច្បាប់ហៅថាសិទ្ធិសាខា “branch rights” ក៏ត្រូវប្រើសម្រាប់បញ្ជាក់អំពីសិទ្ធិទាំងអស់នោះ)។ សិទ្ធិទាំងនោះស្ថិតក្រោមសិទ្ធិអ្នកនិពន្ធហើយអ្នកនិពន្ធតែមួយគត់គឺជាម្ចាស់កម្មសិទ្ធិ។ សិទ្ធិនិមួយៗនឹងត្រូវពន្យល់លម្អិតបន្ថែមដូចខាងក្រោម។

ច្បាប់សិទ្ធិអ្នកនិពន្ធតាមប្រទេសនិមួយៗ តែងមានការសើរើកែសម្រួលជារឿយៗដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃលក្ខខណ្ឌសង្គម ដូចជាការចម្រើនជឿនលឿនខាងបច្ចេកវិទ្យា។ យោលទៅលើសភាពការណ៍បែបនេះហើយ ទើបមានសិទ្ធិថ្មីៗកើតឡើង។ ហេតុនេះ ជាការចាំបាច់ណាស់ត្រូវតែស្វែងយល់ដឹងអំពីភាពរីកចម្រើនថ្មីៗខាងច្បាប់សិទ្ធិអ្នកនិពន្ធ។

នៅប្រទេសជប៉ុន សិទ្ធិបេតិកភណ្ឌត្រូវបានបែងចែកជាសិទ្ធិសាខាដូចតទៅ:

## ១_សិទ្ធិផលិតឡើងវិញ

(សិទ្ធិការពារស្នាដៃ មិនឱ្យមានការផលិតឡើងវិញដោយគ្មានការអនុញ្ញាត)

សិទ្ធិផលិតឡើងវិញជាផ្នែកមួយសំខាន់បំផុតនៃសិទ្ធិបេតិកភណ្ឌ។ ការផលិតឡើងវិញមានន័យថា ការចម្លងឡើងវិញជាទម្រង់រូបីតាមមធ្យោបាយបោះពុម្ព ថតរូប ប៉ូលីក្រាហ្វី (polygraphy)ថតសម្លេង ឬថតរូបភាព ឬតាមមធ្យោបាយផ្សេងៗទៀតដែលមាន។ ជាសាមញ្ញមានន័យថា ប្រើប្រាស់ផ្នែកខ្លះ ឬទាំងស្រុងនៃស្នាដៃមួយ ដើម្បីបង្កើតទៅជាផលិតផលផ្សេងទៀត ឬចម្លង ឬបង្កើតទៅជាផលិតផលឮសម្លេងឬឃើញរូបភាព។ល។ ការបោះពុម្ពផ្សាយជាវិធីមួយមានចំណាស់បំផុតនៃការផលិតឡើងវិញ។ ជាទូទៅសិទ្ធិពាក់ព័ន្ធនឹងការបោះពុម្ពផ្សាយត្រូវហៅថាសិទ្ធិបោះពុម្ពផ្សាយដែលជាប្រភេទមួយនៃសិទ្ធិផលិតឡើងវិញ។ ការថតចម្លងនូវការសម្តែងកម្មវិធីទូរផ្សាយ ការធ្វើបាឋកថា ដើម្បីបង្កើតជាផលិតផលអាចមើលឃើញរូបភាព ឬស្តាប់ឮសម្លេងក៏អនុវត្តតាមសិទ្ធិផលិតឡើងវិញដែរ។ តាមពិត សិទ្ធិនេះទូលំទូលាយណាស់គ្របដណ្តប់លើសកម្មភាពទាំងឡាយដូចជា ការចម្លងអត្ថបទ ឬសៀវភៅរូបភាព តាមរយៈម៉ាស៊ីនស្កែន ម៉ាស៊ីនថតចម្លង ហើយក៏ដូចជាប្លង់នៃសំណង់អគារដែលចម្លង ជាប្លង់លម្អិត (blueprints) ជាដើម។

## ២_សិទ្ធិសម្តែង

(សិទ្ធិការពារស្នាដៃ មិនឱ្យមានការសម្តែងជាសាធារណៈដោយគ្មានការអនុញ្ញាត)

សិទ្ធិសម្តែងមានន័យថា សិទ្ធិសម្តែងជាសាធារណៈនូវឈុតរឿង ឈុតរបាំ ចម្រៀងតូរ្យតន្ត្រីដែលជាស្នាដៃរបស់បុគ្គលណាមួយបានតែងនិពន្ធ។ អ្នកនិពន្ធមានសិទ្ធិផ្តាច់មុខក្នុងការអនុញ្ញាតឬមិនអនុញ្ញាតឱ្យសម្តែងជាសាធារណៈ។ ចំណុចសំខាន់គឺពាក្យ "សាធារណៈ"។ ពាក្យសាធារណៈនេះមិនរាប់បញ្ចូលនូវការហាត់សម្តែងដោយខ្លួនឯង ឬសម្តែងដើម្បីកំសាន្តក្នុងគ្រួសារឡើយ។ សាធារណៈក្នុងសៀវភៅនេះមានន័យថា ចំពោះមុខប្រជាជនដ៏ច្រើនដោយមិនកំណត់ចំនួនឬឋានៈឡើយ។ សិទ្ធិនេះមិនត្រឹមតែអនុវត្តចំពោះការសម្តែងប៉ុណ្ណោះទេថែមទាំងអនុវត្តចំពោះការចាក់ស៊ីឌី។ល។ជាសាធារណៈ ឬការប្រើឧបករណ៍បំពងសម្លេងផ្សព្វផ្សាយនូវការសម្តែងជូនប្រជាជនដែលនៅខាងក្រៅសាលឬរោងមហោស្រពទៀតផង។

## ៣_សិទ្ធិបញ្ចាំង

(សិទ្ធិការពារស្នាដៃមិនឱ្យមានការបញ្ចាំងជាសាធារណៈដោយគ្មានការអនុញ្ញាត)

សិទ្ធិបញ្ចាំងមានន័យថាសិទ្ធិបញ្ចាំងស្នាដៃបុគ្គលណាមួយទៅលើផ្ទាំងសំពត់សឬលើវត្ថុផ្សេងទៀត។ នាអតីតកាល សិទ្ធិនេះអនុវត្តចំពោះការបញ្ចាំងខ្សែភាពយន្ត ប៉ុន្តែយោលទៅលើភាពចម្រើនជឿនលឿនខាងបច្ចេកវិទ្យាក្នុងការបញ្ចាំងរូបភាព សព្វថ្ងៃសិទ្ធិនេះត្រូវអនុវត្តចំពោះការបញ្ចាំងស្នាដៃឬរូបភាពតាមម៉ាស៊ីនកុំព្យូទ័រនិងតាមកញ្ចក់ អិលស៊ី (LC screen) ដោយម៉ាស៊ីនបញ្ចាំងអិលស៊ី (LC projectors) ។ល។ ដូច្នេះហើយបានជាច្បាប់សិទ្ធិអ្នកនិពន្ធ នៃប្រទេសជាច្រើនបច្ចុប្បន្ននេះ ទទួលស្គាល់សិទ្ធិបញ្ចាំងដែលជាសិទ្ធិបង្ហាញស្នាដៃសោតទស្សន៍ជាសាធារណៈ។ សព្វថ្ងៃ សិទ្ធិនេះក៏ត្រូវអនុវត្តចំពោះការបញ្ចាំងរូបថតឬរូបនៅស្មៀមនៃស្នាដៃសិល្បៈទៅលើផ្ទាំងសំពត់ស ឬលើវត្ថុផ្សេងទៀតដែរ។

## ៤-សិទ្ធិបញ្ជូនជាសាធារណៈ

(សិទ្ធិការពារស្នាដៃមិនឱ្យមានការបញ្ជូនជាសាធារណៈដោយគ្មានការអនុញ្ញាត)

អ្នកនិពន្ធមានសិទ្ធិផ្តាច់មុខដើម្បីអនុញ្ញាតឱ្យបញ្ជូនស្នាដៃរបស់ខ្លួនជាសាធារណៈ។ ការបញ្ជូនជាសាធារណៈគឺផ្សាយតាមរយៈវិទ្យុ ទូរទស្សន៍ ។ល។ និងរួមទាំងផ្សាយតាមផ្កាយរណប ខ្សែកាប ទូរទស្សន៍ខ្សែកាប និងផ្សាយនូវស្នាដៃតាមបណ្តាញកុំព្យូទ័រ។

## ៥-សិទ្ធិសូត្រ

(សិទ្ធិការពារស្នាដៃ មិនឱ្យសូត្រជាសាធារណៈដោយគ្មានការអនុញ្ញាត)

សិទ្ធិសូត្រ ជាសិទ្ធិរបស់អ្នកនិពន្ធដើម្បីថ្លែង ឬនិយាយជាសាធារណៈអំពីស្នាដៃអក្សរសាស្ត្ររបស់ខ្លួន។ ជាឧទាហរណ៍ សិទ្ធិនេះរួមមានការនិយាយក្នុងអង្គប្រជុំប្រជាជននូវរឿងប្រលោមលោកដែលមានក្នុងសៀវភៅជាស្នាដៃរបស់ខ្លួនឯង ក៏ដូចជាថតចម្លងនូវការនិយាយនោះហើយចាក់ផ្សាយក្នុងអង្គប្រជុំជាសាធារណៈ។

## ៦-សិទ្ធិតាំងពិព័រណ៍

(សិទ្ធិការពារស្នាដៃ មិនឱ្យមានការតាំងពិព័រណ៍ជាសាធារណៈដោយគ្មានការអនុញ្ញាត)

សិទ្ធិនេះពាក់ព័ន្ធទៅនឹងការតាំងបង្ហាញនូវស្នាដៃសិល្បៈសូនរូបនិងសិល្បៈសិប្បកម្ម និងស្នាដៃរូបថត។ អ្នកនិពន្ធមានសិទ្ធិផ្តាច់មុខដើម្បីតាំងពិព័រណ៍ជាសាធារណៈនូវស្នាដៃរបស់ខ្លួន។ ឧទាហរណ៍សិទ្ធិនេះអនុវត្ត

ចំពោះការអនុញ្ញាតឱ្យដាក់តាំងពិព័រណ៍វប្បធម៌នូវស្នាដៃច្បាប់ដើមនៅទីកន្លែងដែលមនុស្សជាច្រើននឹងមើលឃើញ។ នៅប្រទេសជប៉ុន សិទ្ធិនេះអនុវត្តចំពោះតែការតាំងស្នាដៃច្បាប់ដើមប៉ុណ្ណោះ គឺមិនមែនស្នាដៃច្បាប់ចម្លងឡើយ តែនៅប្រទេសកូរ៉េ និងចិន អាចអនុញ្ញាតឱ្យដាក់តាំងពិព័រណ៍នូវផលិតផលដែលផលិតឡើងវិញបាន។ លើសពីនេះ នៅប្រទេសជប៉ុន ក្នុងករណីការតាំងពិព័រណ៍រូបថត គឺអនុវត្តចំពោះតែរូបថតណា ដែលមិនទាន់បានផ្សព្វផ្សាយប៉ុណ្ណោះ។ ចំណែករូបគំនូរដែលគូរលើផ្ទាំងសំពត់ ក្រដាស ។ល។ ក៏អនុញ្ញាតបានចំពោះតែស្នាដៃច្បាប់ដើម ឬ ស្នាដៃដែលមានតែមួយគត់។ ម្យ៉ាងវិញទៀត រូបថត និងរូបផ្ដិតលើឈើជាធម្មតា ច្បាប់ដើមគេអាចផលិតបានច្រើន ហើយការអនុញ្ញាតឱ្យដាក់តាំងពិព័រណ៍ក៏អនុវត្តចំពោះតែច្បាប់ដើមដែរ។

ដោយសារស្នាដៃផ្ទាំងគំនូរ និងស្នាដៃផ្សេងទៀតផ្នែកសិល្បៈអាចលក់ដូរបានហេតុនេះហើយម្ចាស់កម្មសិទ្ធិក៏អាចត្រូវផ្លាស់ប្ដូរម្ចាស់ដែរ។ នៅពេលដែលម្ចាស់កម្មសិទ្ធិត្រូវផ្លាស់ប្ដូរ ភាពជាម្ចាស់កម្មសិទ្ធិក៏ត្រូវផ្ទេរទៅឱ្យម្ចាស់កម្មសិទ្ធិថ្មី តែសិទ្ធិអ្នកនិពន្ធមិនត្រូវបានផ្ទេរទេ។ ទោះបីយ៉ាងណាក៏ដោយ ក៏ជាការនាំរំខានណាស់ ដែលម្ចាស់កម្មសិទ្ធិថ្មីមុននឹងតាំងបង្ហាញនូវទ្រព្យសម្បត្តិរបស់ខ្លួន ត្រូវតែសុំការអនុញ្ញាតពីម្ចាស់សិទ្ធិជាអ្នកនិពន្ធ។ តើសិទ្ធិតាំងពិព័រណ៍ក្នុងករណីបែបនេះដូចម្ដេចដែរ?

ប្រទេសច្រើនបំផុតក្នុងទ្វីបអាស៊ីពុំមានច្បាប់ច្បាស់លាស់ពាក់ព័ន្ធនឹងករណីនេះទេ។ ទោះបីយ៉ាងណាក៏ដោយនៅប្រទេសជប៉ុនច្បាប់ទទួលស្គាល់សិទ្ធិរបស់ម្ចាស់កម្មសិទ្ធិក្នុងការតាំងពិព័រណ៍នូវស្នាដៃច្បាប់ដើម (មិនរាប់បញ្ចូល ការតាំងជាអចិន្ត្រៃយ៍នៅខាងក្រៅអគារ) ក្នុងករណីដែលស្នាដៃនោះពុំទាន់បានផ្សព្វផ្សាយ ហើយអ្នកនិពន្ធយល់ព្រមឱ្យផ្សាយជាសាធារណៈ។

## ៧.សិទ្ធិចែកចាយ ផ្ទេរកម្មសិទ្ធិ និងជួល

(សិទ្ធិការពារស្នាដៃមិនឱ្យមានការចែកចាយ ផ្ទេរកម្មសិទ្ធិ និងជួលដោយគ្មានការអនុញ្ញាត)

នៅអាស៊ី សិទ្ធិនៃការចែកចាយមានចែងក្នុងច្បាប់សិទ្ធិអ្នកនិពន្ធប្រទេសជប៉ុន ប្រទេសកូរ៉េ និងក្រុងហុងកុង។ អ្នកនិពន្ធស្នាដៃខ្សែភាពយន្ត មានសិទ្ធិផ្ដាច់មុខ ដើម្បីលក់ ជួល ឬចែកចាយច្បាប់ចម្លងនៃស្នាដៃនោះ។ សិទ្ធិនេះជាសិទ្ធិរបស់សមិទ្ធិករដែលច្បាប់ផ្ដល់ឱ្យចែកចាយនូវខ្សែភាពយន្តជាស្នាដៃរបស់ខ្លួន។ សព្វថ្ងៃសិទ្ធិចែកចាយក៏ត្រូវអនុវត្តចំពោះការលក់ ជួល នូវស្នាដៃវីដេអូហ្គេមផ្នែកទន់(video-game software)។

ការចែកចាយមានន័យថា ការផលិតឡើងវិញនូវស្នាដៃភាពយន្តសម្រាប់សាធារណជន ដូចជាការលក់ ឬជួល កាសែ្សតវីដេអូ ឌីវីឌី។ល។ ដោយមិនគិតឬគិតពីប្រាក់កម្រៃ។ សិទ្ធិផ្ទេរភាពជាម្ចាស់កម្មសិទ្ធិ ជាសិទ្ធិផ្តល់ភាពជាម្ចាស់កម្មសិទ្ធិឱ្យមានសិទ្ធិផ្តល់នូវស្នាដៃច្បាប់ដើម (មិនរាប់បញ្ចូលស្នាដៃភាពយន្ត) និងច្បាប់ចម្លងចំពោះសាធារណជន ។ នៅប្រទេសនានា ដូចជាប្រទេសជប៉ុនជាដើម ពេលដែលភាពជាម្ចាស់ត្រូវបានផ្ទេរស្របច្បាប់ ហើយសិទ្ធិផ្ទេរនូវភាពជាម្ចាស់កម្មសិទ្ធិផុតកំណត់ ពេលនោះស្នាដៃអាចចែកចាយដោយសេរីដោយគ្មានការសុំអនុញ្ញាតពីម្ចាស់សិទ្ធិជាអ្នកនិពន្ធទៀតឡើយ។ តែត្រូវយកចិត្តទុកដាក់ឱ្យបានត្រឹមត្រូវព្រោះនៅប្រទេសមួយចំនួន សិទ្ធិផ្ទេរភាពជាម្ចាស់កម្មសិទ្ធិពុំមានផុតអាជ្ញាយុកាលឡើយ។ សិទ្ធិជួលជាសិទ្ធិផ្តល់ស្នាដៃ (មិនរាប់បញ្ចូលស្នាដៃភាពយន្ត) ចំពោះសាធារណជនតាមរយៈការជួលនូវច្បាប់ចម្លង។

## ៨.សិទ្ធិបកប្រែ សម្រួល កែសម្រួល និងយកលំនាំតាម

(សិទ្ធិការពារស្នាដៃ មិនឱ្យមានការបកប្រែ សម្រួល កែសម្រួល និងយកលំនាំតាមដោយគ្មានការអនុញ្ញាត)

ច្បាប់នេះចែងថា អ្នកនិពន្ធមានសិទ្ធិផ្តាច់មុខដើម្បីអនុញ្ញាតឱ្យបកប្រែ សម្រួល កែសម្រួលនូវចម្រៀងតូរ្យតន្ត្រី ឬយកលំនាំតាមស្នាដៃរបស់ខ្លួន ដើម្បីបង្កើតជាស្នាដៃបន្ត។

ការបកប្រែមានន័យថាសម្តែងឬបង្ហាញស្នាដៃអក្សរសាស្ត្រចេញពីភាសាដើមទៅជាភាសាមួយផ្សេងទៀត។ ពាក្យភាសា បញ្ជាក់ទៅលើពាក្យដែលប្រើប្រាស់សម្រាប់ទាក់ទងគ្នារវាងមនុស្ស ដូច្នេះភាសានេះមិនគិតបញ្ចូលនូវភាសាកុំព្យូទ័រទេ។ ដូចគ្នានេះដែរការបំប្លែងពាក្យពីគ្រាមភាសាទៅជាពាក្យ ដែលគេប្រើទូទៅក្នុងភាសាដដែលឬទៅជាពាក្យកូដឬប្រព័ន្ធអក្សរសម្រាប់មនុស្សខ្វាក់ក៏មិនហៅថាការបកប្រែដែរ។ ករណីបែបនេះត្រូវចាត់ទុកថា ជាការផលិតឡើងវិញ។ តាមពាក្យផ្សេងទៀត សិទ្ធិបកប្រែមានន័យថាជាសិទ្ធិបកប្រែស្នាដៃដើមទៅជាភាសាបរទេស។

ការសម្រួលមានន័យថាការបន្ថែមចំណុចមួយចំនួនទៅលើស្នាដៃតូរ្យតន្ត្រីដែលមានស្រាប់។ ឧទាហរណ៍ដូចជា សម្រួលតន្ត្រីបុរាណឱ្យក្លាយជាតន្ត្រីស្ករ (Jazz)។ ថ្មីៗនេះនៅប្រទេសជប៉ុនមានករណីមួយកើតឡើង គឺក្រុមហ៊ុន តូរ្យតន្ត្រីមួយបានផលិតតូរ្យតន្ត្រីស្ករ ដែលសម្រួលចេញពីស្នាដៃតូរ្យតន្ត្រីបុរាណមួយដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធបទភ្លេង តែទីបំផុតក្រុមហ៊ុននោះបានសម្រេចបោះបង់ការលក់ស៊ីឌីដោយសារមានការប្រឆាំងតវ៉ាពីអ្នកនិពន្ធបទភ្លេង។

ការកែសម្រួលមានន័យថាប្ដូរទម្រង់នៃស្នាដៃ។ ឧទាហរណ៍ដូចជាឆ្លាក់រូបបដិមាតាមរូបនៃផ្ទាំងគំនូរឬគូររូបគំនូរ តាមរូបថត។

ការយកលំនាំតាមមានន័យថាប្ដូរទម្រង់ស្នាដៃដើមមួយឱ្យក្លាយទៅជាឈុតសម្ដែង ឬជាខ្សែភាពយន្តដោយពុំមានកែប្រែខ្លឹមសារនៃសាច់រឿង។ ប្រភេទនៃស្នាដៃបែបនេះមានដូចជាស្នាដៃផ្សាយតាមកញ្ចក់ទូរទស្សន៍ដោយយកលំនាំតាមស្នាដៃដើមមួយ។ ការធ្វើឱ្យប្រសើរឡើងនូវកម្មវិធីកុំព្យូទ័រ ។ល។ ក៏ត្រូវចាត់ទុកថាជាការយកលំនាំតាមដែរ។

ជម្លោះកើតឡើងជារឿយៗស្ដីពីសិទ្ធិយកលំនាំតាម ព្រោះជាការលំបាកដើម្បីវិនិច្ឆ័យថាជាការយកលំនាំតាមស្នាដៃដើមដោយគ្មានការកែប្រែខ្លឹមសារឬគ្រាន់តែជាការធ្វើអាជីវកម្មលើគំនិត។ អ្នកខ្លះយល់ថាការធ្វើអាជីវកម្មលើគំនិតក៏ជាការយកលំនាំតាមដែរ។ ដូចបានរៀបរាប់នៅខាងដើមបញ្ជាក់ឱ្យដឹងហើយថា គំនិតមិនត្រូវទទួលនូវកិច្ចការពារពីច្បាប់សិទ្ធិអ្នកនិពន្ធឡើយ តែដោយសិទ្ធិយកលំនាំតាមជាផ្នែកមួយត្រូវទទួលកិច្ចការពារពីច្បាប់សិទ្ធិអ្នកនិពន្ធ ទើបជម្លោះស្ដីពីបញ្ហានេះកើតឡើង។ ជាទូទៅករណីទាំងឡាយណាដែលមានការផ្លាស់ប្ដូរតែប្រវត្តិ ហើយខ្លឹមសារនិងតួអង្គក្នុងស្នាដៃរក្សាដូចដើម នោះគឺត្រូវចាត់ទុកជាការយកលំនាំតាម។

## ៩.សិទ្ធិធ្វើអាជីវកម្មលើស្នាដៃបន្ត

(សិទ្ធិការពារស្នាដៃមិនឱ្យបង្កើតស្នាដៃបន្តដោយគ្មានការអនុញ្ញាត)

ដូចបានពន្យល់ក្នុងចំណុចទី៨ខាងលើបង្ហាញឱ្យឃើញថា ស្នាដៃបន្តជាស្នាដៃថ្មីដែលបង្កើតឡើងដោយការបកប្រែ ការសម្រួល ការកែសម្រួល ឬយកលំនាំតាម ។ ទោះបីអ្នកនិពន្ធថ្មីមានសិទ្ធិលើស្នាដៃដែលខ្លួនបានបង្កើតនូវស្នាដៃបន្តក៏ដោយ ក៏អ្នកនិពន្ធស្នាដៃដើមមានសិទ្ធិដូចអ្នកនិពន្ធស្នាដៃបន្តនេះដែរ។ ឧទាហរណ៍ដូចជា ផលិតករវីដេអូគំនូរជីវចលម្នាក់ផលិតវីដេអូគំនូរជីវចលសម្រាប់ធ្វើពាណិជ្ជកម្មដោយផ្អែកតាមសៀវភៅគំនូរថ្លុក ដូច្នេះការផលិតឡើងវិញ ត្រូវតែមានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិទាំងពីរ គឺផលិតករវីដេអូគំនូរជីវចលនិងអ្នកគូរគំនូរថ្លុកជាម្ចាស់ស្នាដៃដើម។ ទទួលការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិតែមួយគឺពុំទាន់គ្រប់គ្រាន់ឡើយ ត្រូវតែមានការអនុញ្ញាត ពីម្ចាស់សិទ្ធិអ្នកនិពន្ធទាំងអស់។



## សិទ្ធិធ្វើអាជីវកម្មលើស្នាដៃបន្តនិងការប្រើប្រាស់ជាបន្ទាប់បន្សំស្នាដៃបោះពុម្ពផ្សាយ

ដូចបានបញ្ជាក់ខាងលើបង្ហាញឱ្យឃើញថា សិទ្ធិធ្វើអាជីវកម្មលើស្នាដៃបន្តជាប្រភេទមួយនៃសិទ្ធិសាខាស្ថិតក្រោម ច្បាប់សិទ្ធិអ្នកនិពន្ធហើយជាសិទ្ធិផ្តាច់មុខនៃម្ចាស់កម្មសិទ្ធិលើស្នាដៃអ្នកនិពន្ធ ។

ម្យ៉ាងវិញទៀត ក្រៅពីការបោះពុម្ពផ្សាយស្នាដៃបន្តដែលក្លាយពីស្នាដៃដើម ក៏មានពាក្យសិទ្ធិបន្ទាប់បន្សំ ដែលមិនមែនជាពាក្យបញ្ញត្តិក្នុងច្បាប់សិទ្ធិអ្នកនិពន្ធ។ តែសិទ្ធិនេះផ្អែកលើការប្រើប្រាស់ស្នាដៃបោះពុម្ពផ្សាយជាលើក ទីពីរ ត្រូវបានប្រើប្រាស់ទូលំទូលាយរួចស្រេចទៅហើយនៅតាមប្រទេសនានាក្នុងផ្នែកឧស្សាហកម្មបោះពុម្ពផ្សាយ តាមគ្រប់ទម្រង់នៃការធ្វើអាជីវកម្ម។ នៅក្នុងកិច្ចសន្យានៃការបោះពុម្ពផ្សាយ អ្នកនិពន្ធ និងអ្នកបោះពុម្ពផ្សាយ បង្កើតកិច្ចព្រមព្រៀងជាច្រើនចំណុចទាក់ទងទៅនឹងសិទ្ធិបន្ទាប់បន្សំនេះ។

សិទ្ធិទាំងនេះក៏ត្រូវបានផ្ដល់ឱ្យទៅអ្នកបញ្ជូនស្នាដៃ មានផលិតករថតចម្លង ម្ចាស់អង្គភាពទូរផ្សាយ និងទូរទស្សន៍ខ្សែកាប អ្នកសម្ដែងដូចជាសិល្បករ និងតន្ត្រីករ។ តាមន័យទូលាយ ពាក្យនេះស្ថិតក្នុងជំពូកនៃច្បាប់សិទ្ធិអ្នកនិពន្ធ តែក្នុងករណីនៅប្រទេសជប៉ុន កូរ៉េ និងប្រទេសមួយចំនួនផ្សេងទៀត សិទ្ធិនេះត្រូវទទួលនូវកិច្ចការពារពីជំពូកមួយទៀតក្នុងច្បាប់សិទ្ធិអ្នកនិពន្ធ គឺជំពូកសិទ្ធិប្រហាក់ប្រហែល ដែលនឹងត្រូវពន្យល់បន្ថែមក្នុងទំព័រខាងក្រោយ។

## សិទ្ធិសីលធម៌

សិទ្ធិសីលធម៌ ជាធម្មតាមានសិទ្ធិផ្សព្វផ្សាយស្នាដៃជាសាធារណៈ ហើយជាសិទ្ធិកំណត់បង្ហាញឈ្មោះអ្នកនិពន្ធនិង សិទ្ធិរក្សាខ្លឹមសារនៃស្នាដៃ។

គំនិតស្ដីពីសិទ្ធិសីលធម៌ មិនមានប្រភពមកពីប្រព័ន្ធច្បាប់អង់គ្លេស ឬអាមេរិកឡើយ។ ពាក្យនេះទើបត្រូវបានបង្ហាញឱ្យដឹងនៅក្នុងអនុសញ្ញាទីក្រុងប៊ែន Berne Convention (មិនមានសិទ្ធិផ្សព្វផ្សាយស្នាដៃជាសាធារណៈទេ) និងក្នុងកិច្ចព្រមព្រៀងអន្តរជាតិនានាដូចជាអនុសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោក WIPO Convention ។

## សិទ្ធិផ្សព្វផ្សាយស្នាដៃជាសាធារណៈ

(សិទ្ធិការពារស្នាដៃមិនឱ្យផ្សព្វផ្សាយស្នាដៃដោយគ្មានការអនុញ្ញាត)

អ្នកនិពន្ធមានសិទ្ធិផ្សព្វផ្សាយស្នាដៃជាសាធារណៈនូវស្នាដៃដែលពុំទាន់បានផ្សព្វផ្សាយ មានន័យថាអ្នកនិពន្ធមានសិទ្ធិសម្រេចឱ្យផ្សព្វផ្សាយជាសាធារណៈនូវស្នាដៃទាំងពីរគឺស្នាដៃដើមនិងស្នាដៃបន្ត។ ក្នុងករណីស្នាដៃដែលសិទ្ធិបេតិកភណ្ឌត្រូវបានផ្ទេរឱ្យអ្នកផ្សេង អ្នកនិពន្ធត្រូវតែយល់ព្រមអនុញ្ញាតឱ្យតាំងពិព័រជាសាធារណៈ ព្រោះនឹងនាំឱ្យមានបញ្ហាធំចំពោះម្ចាស់កម្មសិទ្ធិ បើសិនជាអ្នកនិពន្ធជំទាស់ការតាំងពិព័រណ៍។ អនុសញ្ញាទីក្រុងប៊ែនពុំមានចែងពីសិទ្ធិផ្សព្វផ្សាយស្នាដៃជាសាធារណៈឡើយ។

## សិទ្ធិកំណត់បង្ហាញឈ្មោះអ្នកនិពន្ធ

(សិទ្ធិទាមទារឱ្យបង្ហាញឈ្មោះអ្នកនិពន្ធ)

ពេលស្នាដៃត្រូវបានផ្សព្វផ្សាយជាសាធារណៈ អ្នកនិពន្ធមានសិទ្ធិសម្រេចឱ្យបង្ហាញឬមិនឱ្យបង្ហាញឈ្មោះ និងសម្រេចឱ្យឬមិនសម្រេចឱ្យប្រើប្រាស់ឈ្មោះពិតឬរហស្សនាម។ អ្នកនិពន្ធមានសិទ្ធិសម្រេចដូចគ្នានេះដែរ ពេលដែលស្នាដៃបន្តត្រូវផ្សព្វផ្សាយជាសាធារណៈ។ សិទ្ធិនេះមិនមានន័យថា ឈ្មោះអ្នកនិពន្ធត្រូវតែបង្ហាញនោះទេ។

## សិទ្ធិរក្សាខ្លឹមសារស្នាដៃ

(សិទ្ធិការពារស្នាដៃមិនឱ្យមានការកែប្រែខ្លឹមសារ)

អ្នកនិពន្ធមានសិទ្ធិការពារខ្លឹមសារ និងចំណងជើងស្នាដៃរបស់ខ្លួនដោយមិនឱ្យមានការបំផ្លើស កាត់ចោលឬកែប្រែខ្លឹមសារផ្ទុយពីឆន្ទៈរបស់ខ្លួន។ ក្នុងករណីនៃការបោះពុម្ពផ្សាយ ឬតួរ្សតន្ត្រី ករណីនេះអាចនាំឱ្យកើតបញ្ហា នៅពេលណាមានសេចក្ដីត្រូវការដើម្បីផ្លាស់ប្ដូរឬកែអក្ខរាវិរុទ្ធ ពាក្យ ឬសំនួនសេចក្ដី។ ដោយពេលវេលាបែប្រួល បទដ្ឋាននៃសង្គមក៏ផ្លាស់ប្ដូរ ហើយសូម្បីតែវាក្យស័ព្ទ និងអក្ខរាវិរុទ្ធដែលយើងប្រើប្រាស់ក៏ផ្លាស់ប្ដូរដែរ។ អ្នកបោះពុម្ពផ្សាយអាចមានបំណងកែប្រែស្នាដៃដើម្បីងាយស្រួលអាន តែពួកគេពុំអាចកែប្រែស្នាដៃបានឡើយ បើគ្មានការជូនពតិមានជាមុនទៅអ្នកនិពន្ធ និងបើពុំបានទទួលការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ។

បន្ថែមទៅលើលក្ខខណ្ឌទាំងបី ដែលបានបង្ហាញខាងលើ បើសិនជាវិធីកែប្រែ និងការប្រើប្រាស់ស្នាដៃនោះបង្កឱ្យខូចកិត្តិនាមរបស់អ្នកនិពន្ធ អំពើនោះត្រូវចាត់ទុកជាការរំលោភបំពានលើសិទ្ធិសីលធម៌របស់អ្នកនិពន្ធ ហើយការហាមឃាត់ត្រូវតែអនុវត្តដើម្បីកុំឱ្យធ្វើការកែប្រែស្នាដៃនោះ។ នៅប្រទេសនានាដូចជាប្រទេសជប៉ុន សិទ្ធិសីលធម៌របស់អ្នកនិពន្ធត្រូវតែទទួលនូវការគោរព ទោះបីជាអ្នកនិពន្ធបានទទួលមរណភាពទៅហើយក្ដី។ ដូច្នេះគ្រួសារអ្នកនិពន្ធដែលកំពុងរស់នៅ អាចហាមឃាត់គ្រប់សកម្មភាព ដែលត្រូវចាត់ទុកថាជាសកម្មភាពរំលោភបំពានលើសិទ្ធិសីលធម៌របស់អ្នកនិពន្ធ ហើយត្រូវទាមទារឱ្យមានវិធានការស្ដារកិត្តិយសអ្នកនិពន្ធឡើងវិញ។



## សិទ្ធិប្រហាក់ប្រហែល

ច្បាប់សិទ្ធិអ្នកនិពន្ធនៃប្រទេសជាច្រើន មិនត្រឹមតែការពារសិទ្ធិរបស់អ្នកបង្កបង្កើតស្នាដៃប៉ុណ្ណោះទេ ថែមទាំងការពារអ្នកសម្តែងឬអ្នកដែលបញ្ជូននូវស្នាដៃជាសាធារណៈទៀតផង។ ឧទាហរណ៍ដូចជាអ្នកចម្រៀងម្នាក់ ទោះបីមិនបានបង្កបង្កើតនូវស្នាដៃថ្មីពិតប្រាកដមែន តែតាមរយៈសកម្មភាពសាមញ្ញគេកំពុងច្រៀងបទចម្រៀងដែលកំពុងអត្ថិភាពដោយប្រើវិធីនិងទម្រង់នៃមនោសញ្ចេតនាបង្កឱ្យអ្នកស្តាប់សប្បាយរំភើបនោះ ក៏ត្រូវចាត់ទុកថាជាសកម្មភាពបង្កបង្កើតដែរ។ សិទ្ធិប្រហាក់ប្រហែលជាសិទ្ធិដែលត្រូវបានប្រគល់ឱ្យចំពោះអ្វីៗគ្រប់យ៉ាង ដែលគេបានបំពេញតួនាទីសំខាន់ក្នុងការបញ្ជូនស្នាដៃជាសាធារណៈ។ នៅប្រទេសមួយចំនួនសិទ្ធិប្រហាក់ប្រហែលមិនត្រូវបានទទួលស្គាល់ឬដាក់ឱ្យអនុវត្តតាមប្រធានបទខុសៗគ្នា តែនៅប្រទេសជប៉ុន កូរ៉េ និងចិន សិទ្ធិនេះត្រូវអនុវត្តនិងគោរពចំពោះអ្នកសម្តែង ដូចជាតន្ត្រីករ សិល្បករ ផលិតករហ្វូណូក្រាម អង្គភាពទូរផ្សាយ និងស្ថានីយ៍ទូរទស្សន៍ខ្សែកាប។

ក៏ដូចជាសិទ្ធិអ្នកនិពន្ធដែរ សិទ្ធិប្រហាក់ប្រហែលត្រូវទទួលស្គាល់ជាស្វ័យប្រវត្តិដោយគ្មានលក្ខខណ្ឌពិសេសអ្វីទាំងអស់។ សិទ្ធិនេះក៏ត្រូវទទួលនូវកិច្ចការពារពីអនុសញ្ញាអន្តរជាតិនានា ដូចជាអនុសញ្ញាការពារអ្នកសម្តែង ផលិតករហ្វូណូក្រាមនិងអង្គភាពទូរផ្សាយ ហើយនិងអនុសញ្ញាការពារផលិតករហ្វូណូក្រាមប្រឆាំងនឹងការថតចម្លងហ្វូណូក្រាមដោយគ្មានការអនុញ្ញាត។ សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល ត្រូវទទួលកិច្ចការពារដាច់ដោយឡែកពីគ្នា ដូច្នេះចាំបាច់ត្រូវតែទទួលការអនុញ្ញាតផ្សេងគ្នា ដើម្បីអាចទទួលបាននូវសិទ្ធិប្រើប្រាស់ស្នាដៃនិមួយៗ។ ឧទាហរណ៍ ដូចជាពេលផលិតឡើងវិញនូវហ្វូណូក្រាម លោកអ្នកត្រូវតែមាន

ការអនុញ្ញាតពីអ្នកសម្តែងផង និងពីផលិតករហ្វូណូក្រាមផង (សិទ្ធិប្រហាក់ប្រហែល) ហើយក៏ត្រូវមានការអនុញ្ញាតពីអ្នកនិពន្ធបទភ្លេងនិងអ្នកនិពន្ធទំនុកច្រៀង (សិទ្ធិអ្នកនិពន្ធ) ថែមទៀត។

## រយៈពេលនៃកិច្ចការពារសិទ្ធិអ្នកនិពន្ធ

សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលដែលបានពិពណ៌នារហូតមកដល់ចំណុចនេះ មានតម្លៃអនុវត្តតាមច្បាប់ក្នុងរយៈពេលកំណត់ជាក់លាក់មួយគឺរយៈពេលនៃកិច្ចការពារសិទ្ធិ។ រយៈពេលនេះអាស្រ័យទៅដោយច្បាប់របស់ប្រទេសនិមួយៗតែជារឿយៗត្រូវការពារចាប់ពី៥០(ហាសិបឆ្នាំ) ទៅ៧០(ចិតសិបឆ្នាំ) ក្រោយពីថ្ងៃទទួលមរណភាពរបស់អ្នកនិពន្ធ។ រយៈពេលនៃកិច្ចការពារក៏ប្រែប្រួលទៅតាមប្រភេទនៃស្នាដៃដែរ។ នៅពេលដែលរយៈពេលនៃកិច្ចការពារបានបញ្ចប់ សិទ្ធិស្របច្បាប់លើស្នាដៃក៏ត្រូវបញ្ចប់ដែរ។ បន្ទាប់មក ស្នាដៃក៏ក្លាយជាសម្បត្តិសាធារណៈហើយអាចត្រូវធ្វើអាជីវកម្មដោយសេរី។ គោលដៅនៃការបង្កើតរយៈពេលការពារសិទ្ធិ គឺ ដើម្បីបង្កើនផលប្រយោជន៍ចំពោះអ្នកនិពន្ធ ហើយក៏ធ្វើឱ្យមានការយល់ច្បាស់ថាស្នាដៃនឹងក្លាយជាសម្បត្តិសង្គមទាំងមូលក្នុងរយៈពេលមួយជាកំណត់។ ការបង្កើតស្នាដៃនេះរួមចំណែកសម្រាប់បង្កើនការអភិវឌ្ឍវប្បធម៌។

## រយៈពេលនៃកិច្ចការពារសិទ្ធិបេតិកភណ្ឌ

នៅប្រទេសជាច្រើន ស្នាដៃមួយត្រូវទទួលនូវកិច្ចការពារជាស្វ័យប្រវត្តិក្រោមច្បាប់សិទ្ធិអ្នកនិពន្ធរបស់ប្រទេសរៀងៗខ្លួន នៅពេលដែលស្នាដៃនោះត្រូវបង្កើតបាននិងផ្សព្វផ្សាយជាសាធារណៈ (កិច្ចការពារនេះត្រូវទទួលស្គាល់ ដោយគ្មានលក្ខខណ្ឌ)។ ទោះបីយ៉ាងណាក៏ដោយ ក៏ប្រទេសមួយចំនួនមានប្រព័ន្ធចុះបញ្ជីស្នាដៃ នៅពេលដែលស្នាដៃនោះស្ថិតក្រោមកិច្ចការពារនៃច្បាប់សិទ្ធិអ្នកនិពន្ធ។ ការចុះបញ្ជីស្នាដៃបែបនេះជាវិធានការទប់ស្កាត់ការប្រើប្រាស់ខុសច្បាប់ដោយតតីយជន ហើយក៏ផ្តល់ផលប្រយោជន៍ចំពោះអ្នកនិពន្ធនៅពេលដែលបង្ហាញភស្តុតាង ជាស្នាដៃជាក់ស្តែង (នៅសហរដ្ឋអាមេរិក ជប៉ុន កូរ៉េ និងចិន ប្រព័ន្ធចុះបញ្ជីអនុវត្តចំពោះតែស្នាដៃផ្នែកទន់ Software តែប៉ុណ្ណោះ)។ ដូចបានអធិប្បាយនៅខាងដើមស្នាដៃមួយដែលត្រូវទទួលនូវកិច្ចការពារសិទ្ធិបេតិកភណ្ឌ គឺការពារក្នុងរយៈពេលមួយជាក់លាក់ដែលកំណត់ដោយច្បាប់នៃប្រទេសនិមួយៗ។ ទោះបីជារយៈពេលផ្អែកទៅលើប្រទេសនិមួយៗ និងប្រភេទនៃស្នាដៃក៏ដោយក៏ប្រទេសជាច្រើននៅទ្វីបអាស៊ីកំណត់រយៈពេលនៃកិច្ចការពារ៥០ (ហាសិបឆ្នាំ) ចាប់ពីថ្ងៃមរណភាពរបស់

អ្នកនិពន្ធ (ឈ្មោះអ្នកនិពន្ធដែលប្រើប្រាស់នៅលើស្នាដៃ)។ ថ្វីបើមានករណីលើកលែងជាច្រើន ដូចជាស្នាដៃ ឬក៏រូបថតបង្កើតឡើងជាប្រយោជន៍សម្រាប់ក្រុមហ៊ុនមួយ ក៏ករណីទាំងនោះមិនត្រូវបានយកមកអធិប្បាយនៅក្នុងសៀវភៅនេះទេ។ សព្វថ្ងៃនេះការបង្កើនរយៈពេលនៃកិច្ចការពារ ហាក់បីដូចជាមានការពេញនិយមទូទាំងពិភពលោកទៅហើយ។ នៅលោកខាងលិចមានការបង្កើនជាជំហាន១រយៈពេលនៃកិច្ចការពាររហូតដល់ទៅចិតសិបឆ្នាំឬក៏ច្រើនឆ្នាំថែមទៀត ឯប្រទេសមួយចំនួនទៀតក៏បានធ្វើវិសោធនកម្មច្បាប់របស់ប្រទេសគេឱ្យស្របទៅតាមនិន្នាការនេះដែរ។

## រយៈពេលនៃកិច្ចការពារសិទ្ធិប្រហាក់ប្រហែល

រយៈពេលនៃកិច្ចការពារសិទ្ធិប្រហាក់ប្រហែលក៏កំណត់ដោយច្បាប់សិទ្ធិអ្នកនិពន្ធនៅតាមប្រទេសនិមួយ១ដែរ ឬ ដោយកិច្ចព្រមព្រៀងនានាដូចជាកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពនៃកម្មសិទ្ធិបញ្ញាទាក់ទងនឹងពាណិជ្ជកម្ម TRIPS ដែលនឹងពន្យល់នៅផ្នែកខាងក្រោយ។ កិច្ចការពារចាប់ផ្តើមឡើងនៅពេលដែលស្នាដៃត្រូវសម្តែងជាលើកដំបូង សម្លេងត្រូវថតជាលើកដំបូង ឬត្រូវផ្សព្វផ្សាយជាសាធារណៈជាលើកដំបូង។ ក្នុងករណីរបស់អង្គភាពទូរផ្សាយ គឺផ្តើមការពារនៅពេលស្នាដៃត្រូវផ្សព្វផ្សាយ ឬបញ្ជូនតាមខ្សែកាបជាលើកដំបូង ។



# ៣ តើកិច្ចការពារស្នាដៃជាអន្តរជាតិ ប្រព្រឹត្តទៅដូចម្តេច?



# ៣ កិច្ចការពារស្នាដៃជាអន្តរជាតិ

នៅពេលធ្វើអាជីវកម្មលើស្នាដៃឆ្លងហួសពីព្រំដែនជាតិកាន់តែច្រើនឡើងៗ ប្រទេសនានាលើសកលលោកបានមានវិធានការការពារស្នាដៃតាមរយៈសន្ធិសញ្ញាអន្តរជាតិ។

ច្បាប់សិទ្ធិអ្នកនិពន្ធបង្កើតឡើងតាមប្រទេសនិមួយៗមានចែងពីសិទ្ធិផ្សេងៗទាក់ទងទៅនឹងស្នាដៃ។ លើសពីនេះ ក៏មានសិទ្ធិជាច្រើនត្រូវទទួលនូវកិច្ចការពារជាអន្តរជាតិទៀតផង។ ឧទាហរណ៍ដូចជាអនុសញ្ញាទាំងពីរគឺអនុសញ្ញាទីក្រុងប៊ែន Berne Convention និងអនុសញ្ញាសកលស្តីពីសិទ្ធិអ្នកនិពន្ធ Universal Copyright Convention សម្រាប់ការពារសិទ្ធិអ្នកនិពន្ធ ឯសិទ្ធិប្រហាក់ប្រហែលត្រូវទទួលនូវកិច្ចការពារពីអនុសញ្ញាសម្រាប់កិច្ចការពារអ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ The Convention for the Protection of Performers, Producers of Phonograms and Broadcasting Organizations ហើយនឹងអនុសញ្ញាសម្រាប់កិច្ចការពារ ផលិតករហ្វូណូក្រាមប្រឆាំងនឹងការចម្លងដោយគ្មានការអនុញ្ញាត The Convention for the Protection of Producers of Phonograms Against Unauthorized Duplication។ កិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក The Agreement Establishing the World Trade Organization (WTO) ផ្តើមឡើងនាឆ្នាំ១៩៩៤ និងបានចូលជាធរមាននាឆ្នាំ១៩៩៥។ មានឧបសម្ព័ន្ធមួយរបស់កិច្ចព្រមព្រៀងនេះជាកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពនៃកម្មសិទ្ធិបញ្ញាទាក់ទងនឹងពាណិជ្ជកម្ម TRIPS។ សិទ្ធិទាំងពីរគឺសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលមានចែងក្នុងកិច្ចព្រមព្រៀងនោះ។ លើសពីនេះ នាឆ្នាំ១៩៩៦ អង្គការកម្មសិទ្ធិបញ្ញាពិភពលោក WIPO បានបង្កើតសន្ធិសញ្ញាស្តីពីសិទ្ធិអ្នកនិពន្ធ WIPOCT និងសន្ធិសញ្ញាស្តីពីអ្នកសម្តែងនិងហ្វូណូក្រាម WIPOPPT ធ្វើជាប្រព័ន្ធមួយសម្រាប់ការពារសិទ្ធិអ្នកនិពន្ធ ដើម្បីឆ្លើយតបទៅនឹងឌីជីថលនីយកម្មជាអន្តរជាតិនិងបណ្តាញសកល Global Networks។



អនុសញ្ញានិងកិច្ចព្រមព្រៀងទាំងនោះផ្តល់នូវការព្រមព្រៀងជាទូទៅមួយស្តីពីកម្មសិទ្ធិបញ្ញាអន្តរជាតិដូចជាសិទ្ធិអ្នកនិពន្ធនិងការចុះកិច្ចសន្យារវាងប្រទេស និងប្រទេសដោយមានការព្រមព្រៀង ដើម្បីការពារស្នាដៃទៅវិញទៅមកជាអន្តរជាតិ។ ស្នាដៃដែលត្រូវការពារក្រោមសិទ្ធិសញ្ញានានាគឺការពារផ្អែកលើច្បាប់ជាតិប្រទេសនិមួយៗ។ ឧទាហរណ៏ដូចជា ស្នាដៃជនជាតិកូរ៉េផ្សព្វផ្សាយនៅក្នុងប្រទេសចិន ត្រូវទទួលនូវកិច្ចការពារដោយច្បាប់សិទ្ធិអ្នកនិពន្ធរបស់ប្រទេសចិន ហើយស្នាដៃជនជាតិចិនផ្សព្វផ្សាយនៅប្រទេសកូរ៉េក៏ត្រូវទទួលនូវកិច្ចការពារដោយច្បាប់សិទ្ធិអ្នកនិពន្ធនៅប្រទេសកូរ៉េដែរ។

អស់រយៈពេលជាច្រើនឆ្នាំ សហរដ្ឋអាមេរិកជាសមាជិកនៃអនុសញ្ញាសាកលស្តីពីសិទ្ធិអ្នកនិពន្ធ Universal Copyright Convention តែមួយគត់ ហើយគ្រប់ស្នាដៃត្រូវតែមានសញ្ញាសិទ្ធិអ្នកនិពន្ធ © ដើម្បីទទួលបាននូវកិច្ចការពារជាអន្តរជាតិ។ នាថ្ងៃទី១ ខែមីនា ឆ្នាំ១៩៨៩ អាមេរិកបានចូលជាសមាជិកនៃអនុសញ្ញាទីក្រុងប៊ែន ហើយបានធ្វើវិសោធនកម្មច្បាប់ជាតិរបស់ខ្លួន ដើម្បីឱ្យបានសមស្របជាមួយនឹងអនុសញ្ញា។ ប្រទេសទាំងឡាយជាសមាជិកនៃអនុសញ្ញាទីក្រុងប៊ែនមិនចាំបាច់មានសញ្ញាសិទ្ធិអ្នកនិពន្ធ © ដើម្បីការពារស្នាដៃជាអន្តរជាតិទៀតឡើយ។

# ៤ ការធ្វើអាជីវកម្មលើស្នាដៃអ្នកនិពន្ធ



# ៤ ការធ្វើអាជីវកម្មលើស្នាដៃអ្នកនិពន្ធ

អនុលោមតាមច្បាប់ សិទ្ធិអ្នកនិពន្ធជាសិទ្ធិសម្រាប់ផ្តល់ការអនុញ្ញាត និងជាសិទ្ធិទទួលបានមកវិញនូវប្រាក់កម្រៃ ដែលធ្វើអាជីវកម្មលើស្នាដៃ។ ការអនុញ្ញាតមានន័យថា សេរីភាពសម្រាប់សម្រេច ឬមិនសម្រេចនូវការផ្តល់សិទ្ធិ ចំពោះជនណាផ្សេងដើម្បីធ្វើអាជីវកម្មលើស្នាដៃ ហើយប្រាក់កម្រៃជាសិទ្ធិទាមទារឱ្យបង់ប្រាក់បង្កើតស្នាដៃទៅម្ចាស់កម្មសិទ្ធិ។ បើសិនជាជនណាមិនព្រមទទួលតាមលក្ខខណ្ឌនេះ ការចរចាដើម្បីធ្វើអាជីវកម្មលើស្នាដៃពុំអាចឈានដល់កិច្ចព្រមព្រៀងគ្នាឡើយ។ ខ្ញុំនឹងអធិប្បាយពីការយល់ដឹងជាមូលដ្ឋាននិងពីគំនិតដែលទាក់ទងទៅនឹងការធ្វើអាជីវកម្មលើស្នាដៃ។



## វិធីនៃការធ្វើអាជីវកម្មលើស្នាដៃ

ការធ្វើអាជីវកម្មលើស្នាដៃមានន័យថា ប្រើប្រាស់សិទ្ធិបេតិកភណ្ឌនៃម្ចាស់កម្មសិទ្ធិលើស្នាដៃ។ ន័យនេះគឺជាកិច្ចព្រមព្រៀងមួយដែលត្រូវស្រុះស្រួលគ្នារវាងម្ចាស់កម្មសិទ្ធិនិងជនដែលសុំការអនុញ្ញាតប្រកបអាជីវកម្ម (អ្នកប្រើប្រាស់) លើស្នាដៃអ្នកនិពន្ធ។ ដូចបានពន្យល់នៅខាងដើម ជាគោលការណ៍សិទ្ធិបេតិកភណ្ឌរួមមានសិទ្ធិផ្ដល់ការអនុញ្ញាតចំពោះជនដែលធ្វើអាជីវកម្មលើស្នាដៃនិងសិទ្ធិទាមទារប្រាក់កម្រៃលើស្នាដៃ។ ការធ្វើអាជីវកម្មលើស្នាដៃត្រូវផ្អែកលើកិច្ចសន្យាមួយ (អាជ្ញាប័ណ្ណ) ដែលបានមកពីការផ្ដល់ការអនុញ្ញាត។ សូម្បីមានការព្រមព្រៀង ធ្វើកិច្ចសន្យាផ្ទាល់មាត់ក៏ដោយ ក៏ត្រូវតែធ្វើកិច្ចសន្យាជាលាយលក្ខអក្សរទើបមានភាពប្រសើរជាង ដើម្បីចៀសវាងការយល់ខុសទៅវិញទៅមក។

នៅពេលដែលជនណាមួយមានបំណងធ្វើអាជីវកម្មលើស្នាដៃ ក្នុងពេលការចរចាគប្បីប្រកាន់ឱ្យខ្ជាប់នូវចំណុចទាំងឡាយដូចខាងក្រោម:

ទីមួយ: បញ្ជាក់ឱ្យឃើញថាស្នាដៃដែលធ្វើអាជីវកម្ម ត្រូវទទួល ឬមិនទទួលនូវកិច្ចការពារពីច្បាប់សិទ្ធិអ្នកនិពន្ធនៃប្រទេសរបស់អ្នកប្រើប្រាស់។ ស្នាដៃណាដែលបានផលិត ឬផ្សព្វផ្សាយជាលើកដំបូងនាប្រទេសរបស់អ្នកនិពន្ធ ឬ ស្ថិតក្រោមកិច្ចការពាររបស់សន្ធិសញ្ញាអន្តរជាតិ ស្នាដៃនោះត្រូវទទួលនូវកិច្ចការពារពីច្បាប់។ ករណីបែបនេះមានសេចក្ដីអធិប្បាយនៅចំណុចបន្ទាប់។ បើសិនជាពុំមានករណីបែបនេះទេ ស្នាដៃនោះអាចត្រូវធ្វើអាជីវកម្មដោយសេរី។

ទីពីរ: ពិនិត្យឱ្យបានជាក់ច្បាស់ថា ស្នាដៃកំពុងតែស្ថិតក្នុងរយៈពេលនៃកិច្ចការពារ ឬក៏ផុតកំណត់រយៈពេលនៃកិច្ចការពារ។ បើសិនជាផុតកំណត់រយៈពេលកិច្ចការពារ លោកអ្នកអាចធ្វើអាជីវកម្មលើស្នាដៃនោះបានដោយសេរី។

ទីបី: បង្ហាញឱ្យឃើញថាវិធីធ្វើអាជីវកម្មស្ថិតនៅក្រៅ ឬនៅក្នុងការកម្រិតសិទ្ធិ។ បើសិនជាស្ថិតនៅក្នុងការកម្រិតសិទ្ធិស្នាដៃនោះអាចប្រើប្រាស់បានដោយសេរី និងពុំចាំបាច់មានការអនុញ្ញាតឡើយ។

បើលោកអ្នកបានអង្កេតចំណុចទាំងអស់ខាងលើ ហើយបានរកឃើញថា សិទ្ធិបេតិកភណ្ឌលើស្នាដៃកំពុងស្ថិតក្នុងរយៈពេលនៃកិច្ចការពារលោកអ្នកត្រូវតែសុំការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិដើម្បីទទួលសិទ្ធិធ្វើអាជីវកម្មលើស្នាដៃ។ ក្នុងករណីបែបនេះ ភាគីម្ចាស់កម្មសិទ្ធិ ដែលលោកអ្នកកំពុងសុំការអនុញ្ញាតសិទ្ធិនោះមិនមែនសុទ្ធតែជាអ្នកនិពន្ធ

ទាំងអស់ឡើយ ព្រោះក្នុងករណីខ្លះ សិទ្ធិលើស្នាដៃត្រូវបានផ្ទេរទៅឱ្យអង្គភាពគ្រប់គ្រងសិទ្ធិរួម និងករណីខ្លះទៀត អ្នកបោះពុម្ពផ្សាយ អ្នកទទួលការផលិត ឬអ្នកទទួលគ្រប់គ្រងអាចត្រូវចាត់ឱ្យធ្វើជាអ្នកទាក់ទងដើម្បីចរចាអំពីសិទ្ធិ។

## ការកម្រិតសិទ្ធិអ្នកនិពន្ធ

ក្រៅពីលក្ខខណ្ឌជាក់លាក់គឺមានការកម្រិតសិទ្ធិអ្នកនិពន្ធ។ កម្រិតសិទ្ធិមានន័យថាសិទ្ធិត្រូវទទួលការត្រួតពិនិត្យ។ មានន័យថា លើកលែងតែលក្ខខណ្ឌជាក់លាក់ បើសិទ្ធិបេតិកភណ្ឌអាចប្រើប្រាស់បាននោះគេអាចធ្វើអាជីវកម្មលើស្នាដៃដោយសេរី។ទោះបីយ៉ាងណាក៏ដោយ ថ្មីៗនេះ ការអនុវត្តយ៉ាងទូលាយតាមការកម្រិតសិទ្ធិបានបង្កឱ្យមានបញ្ហា ដូចជាបញ្ហាមួយបានកើតឡើងនៅប្រទេសជប៉ុនពេលថ្មីៗនេះ គឺការផលិតឡើងវិញសម្រាប់ប្រើប្រាស់ជាលក្ខណៈឯកជន ឬប្រើប្រាស់ក្នុងបណ្ណាល័យសាធារណៈ ។ល។ លើសពីនេះការមានបញ្ហាបែបនេះដោយសារតែពុំទាន់មានការយល់ដឹងច្បាស់លាស់អំពីភាពខុសគ្នារវាង "អាគតដ្ឋាន " ដែលត្រូវទទួលស្គាល់ស្របច្បាប់ និង "ការប្រើប្រាស់" ដែលត្រូវតែមានការអនុញ្ញាត។ ការកម្រិតសិទ្ធិអ្នកនិពន្ធគ្រាន់តែត្រូវយល់ដឹងសម្រាប់ទទួលស្គាល់ជាករណីលើកលែងមួយចំនួនតាមច្បាប់កំណត់ប៉ុណ្ណោះ។ ដូច្នេះកិច្ចការសំខាន់ត្រូវតែចងចាំថា គោលដៅដ៏ចំបងបំផុតគឺការពារផលប្រយោជន៍នៃម្ចាស់កម្មសិទ្ធិ។ ជាកិច្ចការសំខាន់ដែលត្រូវតែយល់ដឹង ទោះបីការកម្រិតសិទ្ធិត្រូវច្បាប់ទទួលស្គាល់ក៏ដោយ ក៏ពុំមានឥទ្ធិពលលើសិទ្ធិសីលធម៌របស់អ្នកនិពន្ធឡើយ លើកលែងតែករណីត្រូវកែអក្ខរាវិរុទ្ធឬពាក្យចាំបាច់សម្រាប់គោលបំណងអប់រំសិក្សា។ ត្រូវតែយកចិត្តទុកដាក់រកឱ្យឃើញច្បាស់លាស់ថា អនុវត្តត្រឹមត្រូវឬមិនត្រឹមត្រូវតាមការកម្រិតសិទ្ធិ ហើយត្រូវតែប្រុងប្រយ័ត្នគឺពុំមែនជាការអនុវត្តតាមច្បាប់នេះទូលាយពេកទេ។

## ការផលិតឡើងវិញសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន

ការផលិតឡើងវិញសម្រាប់ប្រើប្រាស់ក្នុងកាលទេសៈណាមួយតាមការកម្រិតសិទ្ធិ ដូចជាប្រើប្រាស់ផ្ទាល់ខ្លួន ឬក្នុងគ្រួសារ នោះអាចអនុញ្ញាតប្រើប្រាស់បាន។ ទោះបីយ៉ាងណាក៏ដោយ ក្នុងករណីផលិតឡើងវិញនូវស្នាដៃឌីជីថល ឬ វីដេអូ ក៏ចាំបាច់ត្រូវតែបង់ប្រាក់កម្រៃជូនម្ចាស់កម្មសិទ្ធិ។ លើសពីនេះការផលិតឡើងវិញនូវស្នាដៃមួយសម្រាប់ការងារមួយក្នុងក្រុមហ៊ុនហើយសម្រាប់មនុស្សតែម្នាក់ប្រើប្រាស់ក៏ដោយ ក៏ការផលិតឡើងវិញនោះត្រូវចាត់ទុកថាជាការងារពាណិជ្ជកម្ម ព្រោះការផលិតឡើងវិញបែបនេះមិនមែនសម្រាប់ប្រើប្រាស់

ផ្ទាល់ខ្លួនឡើយ ។ ដូច្នេះស្នាដៃមិនត្រូវអនុញ្ញាតឱ្យចម្លងដោយសេរីតាមបែបនេះទេ ។ ក្នុងករណីដូចគ្នានេះដែរ ការប្រើប្រាស់ឧបករណ៍ សម្ភារៈក្នុងផ្ទះដូលវីដេអូ ឬស៊ីឌីដើម្បីចម្លងស្នាដៃ ក៏មិនត្រូវបានចាត់ទុកថាជាការផលិតឡើងវិញដើម្បីទុកប្រើប្រាស់ផ្ទាល់ខ្លួនដែរ ព្រោះឧបករណ៍សម្ភារៈក្នុងទីនោះសម្រាប់បម្រើជាសាធារណៈ ដូច្នេះស្នាដៃចម្លងនោះត្រូវចាត់ទុកថាជាស្នាដៃចម្លងគ្មានការអនុញ្ញាតសិទ្ធិ ។

## ភាពខុសគ្នារវាងការធ្វើអាជីវកម្មនិងការស្រង់អាគតដ្ឋាន

ត្រូវមានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិទើបធ្វើអាជីវកម្មលើស្នាដៃបាន ។ ម្យ៉ាងទៀតអនុលោមតាមច្បាប់សិទ្ធិអ្នកនិពន្ធនៃប្រទេសនីមួយៗ ពុំចាំបាច់មានការអនុញ្ញាតដើម្បីស្រង់អាគតដ្ឋានពីស្នាដៃរបស់អ្នកផ្សេងយកមកដាក់ក្នុងស្នាដៃរបស់ខ្លួនឡើយ ។ ទោះបីយ៉ាងណាក៏ដោយ ក៏មានលក្ខខណ្ឌច្បាស់លាស់កំណត់អំពីការស្រង់អាគតដ្ឋាននិងគ្រប់គ្រងការប្រើប្រាស់ស្នាដៃ ។

## លក្ខខណ្ឌសម្រាប់ការស្រង់អាគតដ្ឋាន

តើលក្ខខណ្ឌអ្វីខ្លះសម្រាប់កំណត់ច្បាស់លាស់ និងគ្រប់គ្រងការប្រើប្រាស់សេចក្តីស្រង់អាគតដ្ឋាន? ទីមួយគឺស្នាដៃណាដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈទើបអាចស្រង់អាគតដ្ឋានបាន ។ លោកអ្នកមិនអាចស្រង់អាគតដ្ឋានពីស្នាដៃដែលពុំទាន់បានចេញផ្សព្វផ្សាយឡើយ ។ ប្រការទាំឡាយនៃការទាក់ទងគ្នារវាងស្នាដៃថ្មី (ក) និងស្នាដៃ ដែលត្រូវស្រង់យកអាគតដ្ឋាន (ខ) មានដូចតទៅនេះ :

១-ស្នាដៃ (ក) ជាស្នាដៃសំខាន់ ឯអាគតដ្ឋានដែលស្រង់ពីស្នាដៃ (ខ) ជាចំណុចបន្ទាប់បន្សំ(ការទាក់ទងបម្រើជាភ័ស្តុតាងគោល)

២-មានភាពខុសគ្នាច្បាស់លាស់រវាង(ក)និងចំណុចដែលដកស្រង់ចេញពី(ខ) ។

៣-ជាការចាំបាច់ណាស់ដើម្បីស្រង់អាគតដ្ឋានពី(ខ)សម្រាប់បង្កើតស្នាដៃ(ក) ។

៤-អាគតដ្ឋានស្រង់ពី(ខ)ត្រូវកំណត់ចំណុចសំខាន់ៗមានចំនួនជាអប្បបរមា ។

៥-អាគតដ្ឋានស្រង់ពី(ខ)ត្រូវសរសេរឱ្យត្រឹមត្រូវដូចស្នាដៃដើម ។

៦-ប្រភពដកស្រង់ពី(ខ)ត្រូវបញ្ជាក់បង្ហាញឱ្យបានច្បាស់លាស់ ។

៧-ការស្រង់អាគតដ្ឋានមិនត្រូវរំលោភបំពានលើសិទ្ធិសីលធម៌របស់អ្នកនិពន្ធស្នាដៃ(ខ)ឡើយ ។

គេអាចស្រង់អាគតដ្ឋានបាន បើអនុវត្តតាមលក្ខខណ្ឌដូចខាងលើ។ សិទ្ធិប្រើប្រាស់ជាឯកជននូវសិទ្ធិអ្នកនិពន្ធមានបំណងលើកទឹកចិត្តបុគ្គលម្នាក់ៗឱ្យបង្កបង្កើតថ្មី។ ផ្តល់ការលើកទឹកចិត្តបែបនេះ នឹងជំរុញឱ្យអ្នកនិពន្ធបង្កបង្កើតថ្មី ហើយមនុស្សជាច្រើនថែមទៀតនឹងទទួលបានផលប្រយោជន៍ពីសកម្មភាពបង្កបង្កើត។ សកម្មភាពនេះបានជាប្រយោជន៍ដល់ការអភិវឌ្ឍវប្បធម៌ ហើយទីបំផុតទទួលលទ្ធផលជាទ្រព្យសម្បត្តិរួមរបស់មនុស្សគ្រប់ៗគ្នា។ ដូច្នេះជាបំណង គឺធ្វើឱ្យសម្រេចនូវតុល្យភាពរវាង "កិច្ចការពារសិទ្ធិ" និង "ការសម្រួលដើម្បីធ្វើអាជីវកម្មលើស្នាដៃ" ទើបគេអាចអនុវត្តបានសមស្របដោយគ្មានបញ្ហា។ តុល្យភាពនេះអាចសម្រេចលទ្ធផល បើសិនជាអ្នកប្រើប្រាស់ស្នាដៃយល់ដឹងទឹកចិត្តរបស់ម្ចាស់ស្នាដៃ ហើយអ្នកបង្កបង្កើតស្នាដៃយល់ដឹងអំពីស្ថានភាពនៃអ្នកប្រើប្រាស់។ ដើម្បីប្រើប្រាស់ស្នាដៃអ្នកនិពន្ធ កិច្ចការសំខាន់ដែលត្រូវតែយល់ដឹងគឺភាពខុសគ្នារវាងការធ្វើអាជីវកម្មលើស្នាដៃ និងការស្រង់អាគតដ្ឋានចេញពីស្នាដៃ។ គំនិតដែលយល់ថាការស្រង់អាគតដ្ឋានចេញពីស្នាដៃមួយជាសិទ្ធិដែលគេផ្តល់ឱ្យហើយសិទ្ធិនេះដាច់ដោយឡែកពីការធ្វើអាជីវកម្មលើស្នាដៃ គំនិតយល់បែបនេះជាការយល់ខុស។ ការស្រង់អាគតដ្ឋានចេញពីស្នាដៃមួយជារបៀបមួយនៃការធ្វើអាជីវកម្ម តែបើមានលក្ខខណ្ឌពិសេសដែលសិទ្ធិអ្នកនិពន្ធពុំមានការហាមឃាត់ស្នាដៃនោះគេអាចដកស្រង់បានដោយសេរី។ លោកអ្នកត្រូវតែយល់ឱ្យច្បាស់ថាបញ្ញត្តិនេះជាករណីលើកលែងមួយ។ ផ្ទុយទៅវិញ បើលោកអ្នកអនុវត្តលក្ខខណ្ឌស្រង់អាគតដ្ឋានសម្រាប់បំពេញស្ថានភាពផ្ទាល់ខ្លួន ត្រូវតែព្យាយាមពិនិត្យបញ្ញត្តិនេះឱ្យបានហ្មត់ចត់ បើមិនដូច្នោះទេ នឹងជួបបញ្ហា។ បញ្ហាពិតជាកម្រកើតមាន បើអ្នកប្រើប្រាស់ស្នាដៃអនុវត្តតាមដោយសុភនិច្ឆ័យ ឯម្ចាស់សិទ្ធិក៏វាយតម្លៃថាជាការអនុវត្តត្រឹមត្រូវនិងយល់ព្រមជាមួយគ្នានូវរបៀបធ្វើអាជីវកម្ម ហើយចៀសវាងការធ្វើអាជីវកម្មតាមវិធីដែលនាំឱ្យម្ចាស់សិទ្ធិប្រឆាំងជំទាស់។

## ការរំលោភបំពានលើសិទ្ធិអ្នកនិពន្ធ

អនុលោមតាមច្បាប់និងសន្ធិសញ្ញានៃប្រទេសនិមួយៗ សិទ្ធិអ្នកនិពន្ធត្រូវទទួលនូវកិច្ចការពារទាំងនៅក្នុងប្រទេស និងអន្តរជាតិ។ ទោះបីយ៉ាងនេះក៏ដោយ ក៏ការរំលោភបំពានលើសិទ្ធិអ្នកនិពន្ធថ្មីៗនេះកើតមានរាលដាលឡើង។ លោកអ្នកបានកត់សម្គាល់ឃើញគេផ្សាយតាមសារពត៌មាន វិទ្យុ និងលើកញ្ចក់ទូរទស្សន៍។ល។ ការរំលោភបំពាន មានន័យថាអំពើទាំងឡាយណាដែលរំលោភបំពានច្បាប់សិទ្ធិអ្នកនិពន្ធដូចជាប្រើប្រាស់ស្នាដៃអ្នកនិពន្ធដោយគ្មានការអនុញ្ញាតសិទ្ធិដែលជាសិទ្ធិផ្តាច់មុខរបស់អ្នកនិពន្ធ និងការចុះបញ្ជីស្នាដៃដោយអ្នកផ្សេងដែលមិនមែនជាម្ចាស់កម្មសិទ្ធិ។ បើសិនជាជនណាមួយលួចកម្មសិទ្ធិរបស់អ្នកដទៃដែលបានខិតខំបង្កើត ហើយជននោះយកទៅធ្វើជាសម្បត្តិឬយកទៅបំបាត់ចោលដោយគ្មានការសុំអនុញ្ញាត

អំពើបែបនេះត្រូវចាត់ទុកជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរ។ មនុស្សគ្រប់គ្នាដឹងថា ការលួចទ្រព្យសម្បត្តិរបស់អ្នកដទៃជាអំពើខុសច្បាប់។ នៅពេលដែលទ្រព្យសម្បត្តិនោះក្លាយទៅជាវត្ថុអរូបីដូចជាសិទ្ធិអ្នកនិពន្ធ មនុស្សទាំងឡាយហាក់បីដូចជាមិនខ្វាចរអែងនឹងលួច។ កម្មសិទ្ធិបញ្ញា ដូចជាសិទ្ធិអ្នកនិពន្ធជាទ្រព្យសម្បត្តិមានតម្លៃ ដែលជាសិទ្ធិទទួលបានមកពីការបង្កបង្កើតស្នាដៃដោយគំនិត និងមនោសញ្ចេតនា។ ឈានចូលសតវត្សទី២១ សកម្មភាពចែករំលែកការយល់ដឹងរួមគ្នាជាកិច្ចការមានសារសំខាន់ ដែលត្រូវតែយល់ថាការរំលោភសិទ្ធិជាអំពើល្មើសច្បាប់។

## តើការរំលោភបំពានសិទ្ធិមានប្រភេទបែបណាខ្លះ?

សព្វថ្ងៃនេះ យើងអាចមើលឃើញការរំលោភបំពានកម្មសិទ្ធិបញ្ញាមានច្រើនប្រភេទកំពុងកើតឡើងតាមប្រទេសនិមួយៗក្នុងទ្វីបអាស៊ី។ តើលោកអ្នកធ្លាប់បានឃើញខ្សែអាត់ចម្រៀងតូរ្យតន្ត្រី ស៊ីឌី វីដេអូ ឬ ឌីវីឌី ដាក់លក់តាមចិញ្ចើមថ្នល់ និងច្រកផ្លូវឬទេ? ប្រភេទផ្សេងៗនៃកុំព្យូទ័រផ្នែកទន់បានដាក់លក់ជាផ្នែកមួយមានតម្លៃធម្មតា។ ផលិតផលទាំងនេះត្រូវបានផលិតឡើងវិញជាសម្ងាត់ដោយគ្មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិអ្នកនិពន្ធនិងដោយគ្មានបង់ប្រាក់កម្រៃឡើយឬអាចនិយាយថាគ្មានអាជ្ញាបណ្ណ។ ផលិតផលបែបនេះគេហៅថាផលិតផលលួចចម្លង ឯការលួចផលិតគឺជាអំពើប្រឆាំង នឹងច្បាប់ ហើយការដាក់លក់ផលិតផលទាំងនោះនៅគ្រប់ប្រទេសទាំងអស់គេចាត់ទុកថាជាបទឧក្រិដ្ឋ។ ដូច្នេះបើលោកអ្នកឃើញផលិតផលបែបនេះដាក់លក់សូមកុំទិញ ទោះបីជាមានតម្លៃថោកក៏ដោយ។ បើទិញផលិតផល ខុសច្បាប់បែបនេះ លោកអ្នកនឹងក្លាយជាអ្នកសមគំនិតក្នុងការប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម។ផលិតផលបែបនេះពេលត្រូវបានទិញនៅឯបរទេសនឹងត្រូវរឹបអូសយកវិញបើសិនជាភ្នាក់ងារគយបានរកឃើញនៅពេលវិលត្រឡប់មកប្រទេសវិញ ហើយបើសិនជាទិញផលិតផលបែបនេះក្នុងគោលបំណងលក់ដូរនោះនឹងត្រូវទទួលការពិន័យតាមច្បាប់ជាធរមាន។



# ៥ ការប្រែប្រួលបរិស្ថានជុំវិញស្នាដៃ



# ៥ ការប្រែប្រួលបរិស្ថានជុំវិញស្នាដៃ

ចាប់ពីចុងសតវត្សទី២០ រចនាសម្ព័ន្ធទូរគមនាគមន៍រួមមានបណ្តាញកុំព្យូទ័រ ទូរស័ព្ទប្រើសែល (Cell phone) និងការផ្សព្វផ្សាយតាមផ្កាយរណបមានការអភិវឌ្ឍខ្លាំងក្លា។ ប្រៀបធៀបជាមួយនឹងសតវត្សកន្លងទៅ និងសូម្បីតែក្នុងទសវត្សរ៍ថ្មីៗនេះអ្នកស្រុកនៃប្រទេសឧស្សាហកម្មរីកចម្រើន និងប្រទេសកំពុងអភិវឌ្ឍបានទទួលនូវពត៌មានយ៉ាងច្រើនដែលពុំធ្លាប់មាន។ ភាពចម្រើនជឿនលឿនខាងបច្ចេកវិទ្យាបានធ្វើឱ្យមានផលប៉ះពាល់យ៉ាងធំលើវិស័យវប្បធម៌។ កាលពីមួយរយឆ្នាំមុន ក្នុងពិភពលោកយើងនេះមានជនមួយចំនួនតូចតែប៉ុណ្ណោះដែលបានទទួលស្គាល់សិទ្ធិអ្នកនិពន្ធលើស្នាដៃវប្បធម៌ ហើយភាគច្រើននៃអ្នកទាំងនោះគឺសិល្បករ ដូចជាវិចិត្រករគំនូរ អ្នកនិពន្ធ និងតន្ត្រីករ។ អ្នកច្បាប់និងអ្នកប្រាជ្ញក៏មានតែមួយចំនួនដែរដែលពាក់ព័ន្ធទៅនឹងការពិភាក្សាទាក់ទងទៅនឹងសិទ្ធិអ្នកនិពន្ធ។ មកទល់នឹងពេលថ្មីៗនេះ ជនដែលពាក់ព័ន្ធនឹងសកម្មភាពបង្កបង្កើតដោយមានវិជ្ជាជីវៈនៅតែមានកម្រិត ហើយជនដែលធ្វើអាជីវកម្មលើស្នាដៃក៏មានកម្រិតទៅតាមប្រភេទអាជីវកម្មមួយចំនួនតូចនៃឧស្សាហកម្មវប្បធម៌ ដូចជាប្រព័ន្ធពត៌មាន ( អ្នកបោះពុម្ពផ្សាយ អង្គភាពទូរផ្សាយ សារពត៌មាន ។ល។ ) ផលិតករហ្វូណូក្រាម ក្រុមហ៊ុនភាពយន្ត ។ល។ អាចនិយាយថា សូម្បីតែមនុស្សសាមញ្ញដែលពុំយល់អំពីសិទ្ធិអ្នកនិពន្ធ ក៏មិនជួបប្រទះនូវភាពរាំងស្ទះនៃដំណើរជីវិតប្រចាំថ្ងៃរបស់គេដែរ។ តើសភាពការណ៍នេះពិតឬទេចំពោះពេលបច្ចុប្បន្ននេះ?

បច្ចុប្បន្ននេះ យើងផ្សព្វផ្សាយជារឿយៗ ពាក្យ **សិទ្ធិអ្នកនិពន្ធ** និង **កម្មសិទ្ធិបញ្ញា**តាមកញ្ចក់ទូរទស្សន៍ វិទ្យុ សារពត៌មាននិងទស្សនាវដ្តី។ យើងកំពុងទទួលនូវពត៌មានដ៏ច្រើនអនេក ដោយគ្មានទីបញ្ចប់ ។ ដោយសារតែមានពត៌មានច្រើនទាក់ទងទៅនឹងសិទ្ធិអ្នកនិពន្ធបែបនេះហើយ ទើបជីវភាពប្រចាំថ្ងៃរបស់យើងត្រូវទទួលឥទ្ធិពលពីសិទ្ធិអ្នកនិពន្ធ។ ការទទួលឥទ្ធិពលនេះ រួមមាននៅតាមសាលារៀន ការអប់រំក្នុងសង្គម សេវាក្នុងសង្គម បរិស្ថាន សកម្មភាពវប្បធម៌ និងសកម្មភាពរបស់អ្នកស្ម័គ្រចិត្ត។ ឧទាហរណ៍

សំខាន់បំផុតគឺភាពទាក់ទងគ្នារវាងមនុស្សសាមញ្ញនិងសិទ្ធិអ្នកនិពន្ធតាមរយៈកុំព្យូទ័រ ធ្វើឱ្យយើងមិនចាំបាច់ចំណាយពេលយូរតទៅទៀតដើម្បីគិតពីអនាគតនៃជីវិតរស់នៅ។

កុំព្យូទ័របានក្លាយជាចំណែកសំខាន់មួយនៃជីវិតរស់នៅរបស់យើងក្នុងរយៈពេលម្ភៃឆ្នាំចុងក្រោយនេះ។ ភាពចម្រើនជឿនលឿនរបស់បច្ចេកវិទ្យាឌីជីថល ដូចជាអ៊ិនធឺណិត អ៊ីមែល និងគមនាគមន៍ទិន្នន័យបានបង្កឱ្យពិភពលោកប្រែប្រួលរីកចម្រើនថ្មី ហើយកុំព្យូទ័របានក្លាយជាឧបករណ៍ចាំបាច់មិនត្រឹមតែសម្រាប់វិស័យអក្សរសាស្ត្រទេ ថែមទាំងសម្រាប់បង្កបង្កើតតួរ្យតន្ត្រី ខ្សែភាពយន្ត និងផលិតនូវស្នាដៃទាំងនោះសម្រាប់អ្នកប្រើប្រាស់ទៀតផង។ ឌីជីថលនីយកម្មអាចផលិតឡើងវិញនូវស្នាដៃដោយគ្មានបាត់គុណភាពឬខុសពីច្បាប់ដើមឡើយ។ លើសពីនេះ កុំព្យូទ័របង្កលទ្ធភាពឱ្យមនុស្សអាចបង្កើតស្នាដៃបានដោយប្រើតែចំណេះដឹងតិចតួច ដែលកាលពីមុនគឺទាមទារនូវសមត្ថភាពជំនាញនិងបទពិសោធន៍ច្បាស់លាស់។ ឧទាហរណ៍ដូចជាការតែងតួរ្យតន្ត្រី នាបច្ចុប្បន្នយើងប្រើកម្មវិធីផ្នែកទន់ (software programs) យើងអាចតែងបានដោយងាយស្រួលទោះបីជាយើងមិនចេះប្រើប្រាស់ឧបករណ៍ភ្លេងក៏ដោយ។ ការថតចម្លងមានចំនួនច្រើនសន្ធឹកសន្ធាប់ ដែលធ្លាប់ប្រព្រឹត្តទៅមានដំណើរយឺតៗនាសម័យមុន តែសព្វថ្ងៃនេះយើងអាចថតចម្លងបានរហ័សភ្លាមៗ។ ជាលក្ខណៈសាមញ្ញពិសេស យើងអាចផ្ទុកចំនួនតួរ្យតន្ត្រីច្រើនអនេក ឬទិន្នន័យផ្សេងៗទៀតទៅក្នុង MD មួយ ឬក្នុងមេឌីយ៉ាផ្សេងទៀតនិងអាចកាន់ក្នុងដៃបាន។ អត្រានៃការអភិវឌ្ឍមានសន្ទុះលឿនខ្លាំងក្លា គឺអភិវឌ្ឍមួយឆ្នាំស្មើនឹងប្រាំមួយទៅប្រាំបីឆ្នាំ ដោយសារហេតុនេះ ហើយទើបគេដាក់ឈ្មោះថា "យុគសម័យឆ្នាំសុនខ"។

នៅពេលយើងធ្វើអាជីវកម្មលើស្នាដៃ យើងមិនត្រឹមតែសប្បាយរីករាយជាមួយនឹងភាពសម្បូរនៃបច្ចេកវិទ្យាឌីជីថលទេថែមទាំងសប្បាយជាមួយនឹងការបង្កើតស្នាដៃទៀតផង ។ដូច្នេះទើបសម័យសព្វថ្ងៃនេះ ជនណាក៏អាចក្លាយជាអ្នកបង្កបង្កើតស្នាដៃបានដែរ ។ ព្រមពេលជាមួយគ្នានេះ បដិវត្តន៏បច្ចេកវិទ្យាក៏បានបង្កឱ្យមានលទ្ធផលឥតព្រាងទុកកើតជាព្រឹត្តិការណ៍និងប្រភេទថ្មីនៃឧក្រិដ្ឋកម្ម ។ សកម្មភាពខុសច្បាប់ប្រព្រឹត្តឡើងដោយពួកជនខិលខូច ជំនាញខាងកុំព្យូទ័ ដែលរាតត្បាតចូលបណ្តាញកុំព្យូទ័រ និងការលិចធ្លាយនូវទិន្នន័យផ្ទាល់ខ្លួនកំពុងតែកើនឡើងយ៉ាងឆាប់រហ័ស ។ ការគ្រប់គ្រងពតិមានក្នុងកិច្ចការរដ្ឋបាលនៃរដ្ឋាភិបាលក៏ដូចជាក្នុងអង្គការនិមួយៗនិងក្នុងក្រុមហ៊ុនកំពុងត្រូវចោទជាសំណួរ ។ ពីព្រោះពតិមានឌីជីថលអាចកែប្រែបានដោយងាយស្រួល នាំឱ្យមនុស្សម្នាក់ៗ ស្ថិតនៅចំពោះមុខគ្រោះថ្នាក់នៃការរំលោភបំពានលើសិទ្ធិអ្នកនិពន្ធដោយមិនដឹងខ្លួន ។ ស្ថិតក្នុងសភាពការណ៍បែបនេះ យើងត្រូវតែយល់ដឹងឱ្យបានគ្រប់គ្រាន់ អំពីចំណេះផ្នែកសិទ្ធិអ្នកនិពន្ធ ហើយសម្រេចចិត្ត គោរពច្បាប់សិទ្ធិអ្នកនិពន្ធនៅតាមប្រទេសរបស់ខ្លួន ដើម្បីការពារស្នាដៃដែលជាបេតិកភណ្ឌវប្បធម៌រួម និងជាទ្រព្យសម្បត្តិនៃសង្គមមនុស្សជាតិ ។

## ឌីជីថលនីយកម្ម ការភ្ជាប់បណ្តាញ និងសិទ្ធិអ្នកនិពន្ធ

ដូចបានអធិប្បាយនៅខាងដើម ការប្រែប្រួលរីកចម្រើនជាក់ស្តែងបំផុតក្នុងបរិស្ថាននៃសិទ្ធិអ្នកនិពន្ធ គឺឌីជីថលនីយកម្មនិងការភ្ជាប់បណ្តាញ ។ ឌីជីថលនីយកម្មធ្វើឱ្យយើងអាចថតចម្លងនិងកែប្រែនូវស្នាដៃបានយ៉ាងងាយស្រួល ហើយរក្សាគុណភាពដូចស្នាដៃដើមទោះបីការថតចម្លងនោះប្រព្រឹត្តទៅច្រើនលើកឬចំនួនច្រើនច្បាប់ក៏ដោយ ។ ដោយសារគុណភាពនៃច្បាប់ចម្លងដូចច្បាប់ដើម គេក៏អាចប្រើប្រាស់

ច្បាប់ចម្លងនោះសម្រាប់ថតចម្លងធ្វើជាច្បាប់ចម្លងផ្សេងៗទៀត។ លទ្ធផលនេះជាសកម្មភាពប្រឆាំងនឹងច្បាប់ ហើយអំពើនេះនាំឱ្យច្បាប់ចម្លងកើនចំនួនច្រើនឡើងដោយការថតចម្លងចេញពីច្បាប់ចម្លង។ ដោយហេតុតែឌីជីថលនីយកម្មបង្កលក្ខណៈងាយស្រួលសម្រាប់កែប្រែស្នាដៃដើម យើងឃើញមានគ្រោះថ្នាក់ដ៏ធំមួយទៀតចំពោះការរំលោភបំពានលើសិទ្ធិបកប្រែនិងសិទ្ធិរក្សាខ្លឹមសាររបស់ស្នាដៃ។ គុណភាពខ្ពស់នៃការថតចម្លងពតិមានដូចជា CD-ROMs ។ល។ បង្កលទ្ធភាពឱ្យការធ្វើអាជីវកម្មលើស្នាដៃម្តងហើយម្តងទៀតដោយគ្មានការផ្លាស់ប្តូរគុណភាពឡើយ។ ឆ្លើយតបទៅនឹងការប្រែប្រួលដ៏គំហុកនៃប្រភេទអាជីវកម្ម និងចំនួននៃការរំលោភបំពាន។ល។ ដែលបង្កឡើងដោយឌីជីថលនីយកម្ម ទើបប្រទេសនានាកំពុងកែសម្រួលឡើងវិញនូវច្បាប់សិទ្ធិអ្នកនិពន្ធ ដោយបញ្ចូលថែមនូវការបង់កម្រៃ និងការកម្រិតសិទ្ធិស្តីពីការថតចម្លងសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន។ ចំណែកឯការភ្ជាប់បណ្តាញ ក៏កំពុងតែរីកចម្រើនឆាប់រហ័សមិនត្រឹមតែតាមបណ្តាញអ៊ិនធឺណិតអន្តរជាតិទេ ថែមទាំងបណ្តាញរបស់ក្រុមហ៊ុននានាក្នុងប្រទេសនីមួយៗទៀតផង។ បណ្តាញទាំងនេះកំពុងប្រើប្រាស់សម្រាប់បញ្ជូនស្នាដៃចម្រុះដូចជា ចម្រៀងតូរ្យតន្ត្រី រូបភាព និងល្បែងផ្ទែកទន់ game software។ តែពេលដែលស្នាដៃត្រូវបានបញ្ជូនដោយគ្មានការអនុញ្ញាត និងមិនអាចរក្សាទុកបាននោះការខាតបង់ផលប្រយោជន៍នឹងឡើងដល់កម្រិតជាសាកល។ ការបរាជ័យចំពោះមុខគ្រោះថ្នាក់បែបនេះនាំឱ្យអ្នកនិពន្ធបាត់ជំនឿទុកចិត្តលើក្រុមហ៊ុនបណ្តាញ។ ប្រទេសនានាកំពុងស្វាបស្ទង់រកប្រភេទនៃសិទ្ធិណាដែលសមស្របសម្រាប់បញ្ជូនតាមបណ្តាញ ដូចជាសិទ្ធិបញ្ជូនជាសាធារណៈដែលមានក្នុងច្បាប់ជាតិ និងសន្ធិសញ្ញាអន្តរជាតិ។

# សំណួរ & ចម្លើយ

## សំណួរ៖ តើចំណងជើងសៀវភៅ ការផ្សាយពាណិជ្ជកម្ម ខុលខ ជាស្នាដៃឬទេ?

ក្នុងករណីខ្លះមានការពិបាកនឹងវិនិច្ឆ័យថាអ្វីគួរចាត់ទុកជាស្នាដៃឬមិនមែនជាស្នាដៃដែលត្រូវទទួលនូវកិច្ចការពារពីច្បាប់សិទ្ធិអ្នកនិពន្ធ ដូចជាចំណងជើងសៀវភៅ ផ្ទាំងផ្សាយពាណិជ្ជកម្ម លក្ខណៈអក្សរ គំនូរព្រាង និងស្នាដៃរចនា។ ជាទូទៅ អ្វីៗភាគច្រើនបំផុតសុទ្ធតែត្រូវទទួលនូវកិច្ចការពារពីច្បាប់សិទ្ធិអ្នកនិពន្ធ តែលក្ខណសម្បត្តិដែលត្រូវចាត់ទុកថាជា "ស្នាដៃ " គឺអ្វីដែលជាឫសគល់ដើម និងជាការសម្តែងចេញជាស្នាដៃនៃការបង្កបង្កើតថ្មីដោយគំនិត ឬមនោសញ្ចេតនា។

## សំណួរ៖ តើគំនិតត្រូវទទួលនូវកិច្ចការពារពីច្បាប់សិទ្ធិអ្នកនិពន្ធឬទេ?

គំនិតមួយដែលកើតមានក្នុងខួរក្បាលរបស់លោកអ្នក ទោះបីមានប្រយោជន៍អស្ចារ្យយ៉ាងណាក៏ដោយក៏មិនអាចចាត់ទុកជា "ស្នាដៃ" បានឡើយ ដូច្នេះគំនិតមិនត្រូវទទួលនូវកិច្ចការពារពីច្បាប់សិទ្ធិអ្នកនិពន្ធទេ។ តែបើសៀវភៅសាកល្បងឬសៀវភៅដែលសរសេរពន្យល់អំពីគំនិត សៀវភៅនោះនឹងត្រូវចាត់ទុកថាជា "ស្នាដៃ" ។

## សំណួរ៖ តើករណីណាខ្លះដែលស្នាដៃមួយមិនត្រូវទទួលនូវកិច្ចការពារពីច្បាប់?

ស្នាដៃត្រូវទទួលនូវកិច្ចការពារពីច្បាប់ក្នុងរយៈពេលមួយកំណត់។ បើសិនជាសិទ្ធិបេតិកភណ្ឌត្រូវផុតពេលកំណត់ស្នាដៃនឹងមិនត្រូវទទួលនូវកិច្ចការពារបន្តទៀតឡើយ។ ទោះបីស្នាដៃជាសម្បត្តិវប្បធម៌ដែលបង្កបង្កើតដោយបុគ្គលក៏ដោយ ក៏ស្នាដៃនោះជាទ្រព្យសម្បត្តិរបស់សង្គមដែរ ព្រោះមនុស្សជាច្រើនប្រើប្រាស់ស្នាដៃទាំងនោះ។



រយៈពេលកំណត់សម្រាប់ការពារបានកន្លងផុតទៅ សង្គមទាំងមូលគួរតែអាចប្រើប្រាស់ស្នាដៃទាំងនោះបានដោយសេរី។ ហេតុនេះ ស្នាដៃដែលផុតកំណត់រយៈពេលការពារ នឹងក្លាយទៅជាទ្រព្យសម្បត្តិសាធារណៈ។ លើសពីនេះនៅប្រទេសជប៉ុន កូរ៉េ ចិន និងប្រទេសដទៃទៀត ឯកសារសាធារណៈដូចជាច្បាប់ បទប្បញ្ញត្តិ និងសេចក្តីសម្រេចរបស់តុលាការ មិនត្រូវទទួលនូវកិច្ចការពារពីច្បាប់សិទ្ធិអ្នកនិពន្ធទេ។

## សំណួរ: តើច្បាប់សិទ្ធិអ្នកនិពន្ធទទួលការពារគេហទំព័របណ្តាញ (websites) ឬទេ?

បើសិនគំបន់បណ្តាញមួយបង្កបង្កើតដោយក្រុមហ៊ុនឬបុគ្គល បង្ហាញនូវស្នាដៃបង្កើតថ្មី គំបន់បណ្តាញនោះត្រូវទទួលស្គាល់ជាស្នាដៃមួយ។ អាស្រ័យហេតុនេះ នៅពេលដែលយើងប្រើប្រាស់គំបន់បណ្តាញ យើងគប្បីយកចិត្តទុកដាក់ឱ្យបានហ្មត់ចត់បំផុត ដើម្បីចៀសវាងការរំលោភបំពានលើសិទ្ធិបេតិកភណ្ឌ និងសិទ្ធិសីលធម៌។ លើសពីនេះគំបន់បណ្តាញមួយចំនួន ក៏មានផ្ទុកទៅដោយស្នាដៃផ្សេងៗទៀតផង។ ក្នុងករណីបែបនេះ ដូចជារូបគំនូរឬរូបថតក្នុងគំបន់បណ្តាញដែលត្រូវយកទៅប្រើក្នុងទស្សនាវដ្តី សិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធត្រូវចាត់ទុកថាមានសុពលភាព។ ម្យ៉ាងទៀត បើលោកអ្នកបង្កើតគំបន់បណ្តាញដោយខ្លួនឯង ឬលោកអ្នកផ្តល់ប្រាក់កម្រៃឱ្យអ្នកផ្សេងបង្កើត នោះជាការចាំបាច់ត្រូវតែបញ្ជាក់អត្តសញ្ញាណនៃម្ចាស់កម្មសិទ្ធិឱ្យបានច្បាស់ពិតប្រាកដ។

# សំណួរ & ចម្លើយ

## សំណួរ៖  ដូចម្តេចដែលហៅថាស្នាដៃសហការ?

ស្នាដៃសហការ ជាស្នាដៃដែលបង្កើតឡើងដោយអ្នកនិពន្ធច្រើននាក់ (សហអ្នកនិពន្ធ) ហើយស្នាដៃនោះមិនអាចបែងចែកនិងមិនអាចប្រើប្រាស់ដាច់ដោយឡែកពីគ្នាបានឡើយ ។ ករណីបែបនេះអ្នកនិពន្ធទាំងអស់ចែករំលែកសិទ្ធិអ្នកនិពន្ធរៀងៗខ្លួន និងត្រូវតែអនុវត្តតាមកិច្ចព្រមព្រៀងដែលបានយល់ព្រមជាមួយគ្នា ។

តើសៀវភៅរូបភាពដែលមានរូបភាពលម្អ និងអត្ថបទបង្កើតឡើងដោយមនុស្សពីរនាក់ផ្សេងគ្នាត្រូវទទួលនូវសិទ្ធិដូចម្តេចដែរ? ករណីនេះ ដោយមិនរាប់បញ្ចូលនូវស្នាដៃដែលបានបញ្ជាក់អត្តសញ្ញាណច្បាស់លាស់ជាស្នាដៃសហការ នោះរូបភាពលម្អត្រូវចាត់ទុកជាស្នាដៃសិល្បៈ ឯអត្ថបទចាត់ជាស្នាដៃអក្សរសាស្ត្រ ហើយអ្នកនិពន្ធនៃស្នាដៃនិមួយៗត្រូវទទួលនូវសិទ្ធិដោយឡែកៗពីគ្នា ។

## សំណួរ៖  តើរឿងនិទានត្រូវទទួលកិច្ចការពារពីច្បាប់សិទ្ធិអ្នកនិពន្ធឬទេ?

ជាទូទៅ រឿងនិទានដែលគេចេះចាំសុះសាយទូលំទូលាយ រឿងព្រេង ។ល ។ គឺហួសផុតឆ្ងាយពីរយៈពេលកំណត់នៃកិច្ចការពាររបស់ច្បាប់សិទ្ធិអ្នកនិពន្ធ ។

ក្នុងករណីដែលរឿងនិទានភាគច្រើនបានបង្កបង្កើតឡើងដោយអ្នកក្នុងស្រុកជាអ្នកនិយាយរឿងនិទាននោះអាចចាត់ជាស្នាដៃត្រូវការពារដោយច្បាប់ ។ បើសិនជាផ្នែកសំខាន់នៃសាច់រឿងរក្សាដដែលគ្មានកែប្រែ ហើយមានចំណុចមួយចំនួនត្រូវបានថែមឬកាត់ចោល រឿងនិទាននោះមិនចាត់ថាជាស្នាដៃថ្មីឡើយ ។ ក្នុងករណីប្រហែលគ្នានេះដែរ ជនណាមួយបានស្តាប់គេនិយាយរឿងប្រាប់ ជននោះយកដំណើររឿង

ដែលបានស្តាប់មកសរសេរហើយអ្វីដែលបានសរសេរក៏មិនត្រូវចាត់ទុកជាស្នាដៃដែរ ។ តែពេលដែលចំណុចសំខាន់ៗនៃរឿងនិទានត្រូវគេប្រើប្រាស់ជាភាគសំខាន់ហើយមានចំណុចប្លែកៗបន្ថែមបង្កើតជាដំណើររឿងថ្មី រឿងនោះត្រូវទទួលស្គាល់ថាមានបង្កើតខ្លឹមសារថ្មី ដូច្នេះរឿងនិទានបែបនេះគេចាត់ទុកជាស្នាដៃថ្មី ។

## សំណួរៈ តើមនុស្សម្នាក់ៗអាចក្លាយជាអ្នកនិពន្ធបានឬទេ?

ជនណាមួយបង្កើតបាន "ស្នាដៃ" ជននោះអាចក្លាយជាអ្នកនិពន្ធ ទោះបីជននោះជាកុមារឬជាអ្នកគ្មានវិជ្ជាជីវៈជាអ្នកនិពន្ធក៏ដោយ ។ ពុំមានការបែងចែកភាពខុសគ្នាថាស្នាដៃល្អ ឬស្នាដៃអាក្រក់ទេ ឱ្យតែស្នាដៃកើតចេញពីគំនិតដើមឬមនោសញ្ចេតនារបស់ជនណាមួយ ជននោះគឺជាអ្នកនិពន្ធហើយ ។

## សំណួរៈ តើអ្នកណាជាម្ចាស់កម្មសិទ្ធិលើស្នាដៃបកប្រែ?

ដោយសារតែសិទ្ធិបកប្រែត្រូវចាត់ជាសិទ្ធិបោះពុម្ពផ្សាយ ទើបមានមនុស្សជាច្រើនយល់ច្រឡំថាអ្នកបោះពុម្ពផ្សាយជាម្ចាស់កម្មសិទ្ធិលើស្នាដៃបកប្រែ ។ សិទ្ធិបោះពុម្ពផ្សាយជាសិទ្ធិបោះពុម្ពឬផលិតឡើងវិញនូវអត្ថបទដើមតាមមធ្យោបាយគ្រឿងយន្ត ឬគីមី ។ សិទ្ធិបោះពុម្ពផ្សាយមិនរាប់បញ្ចូលនូវសិទ្ធិបកប្រែស្នាដៃទៅជាភាសាផ្សេងទេ ។ បើអ្នកបោះពុម្ពផ្សាយមានបំណងបោះផ្សាយស្នាដៃទៅជាភាសាមួយផ្សេងទៀតគឺចាំបាច់ត្រូវតែធ្វើកិច្ចសន្យាដោយរួមបញ្ចូលនូវសិទ្ធិបកប្រែ ។ ក្នុងករណីបែបនេះ កិច្ចសន្យាមិនគប្បីគ្រាន់តែត្រួតពិនិត្យសិទ្ធិប៉ុណ្ណោះទេថែមទាំងត្រូវបញ្ជាក់ពីរាល់សកម្មភាពនិងប្រាក់កម្រៃដើម្បីអនុវត្តនូវសិទ្ធិនោះទៀតផង ។

# សំណួរ & ចម្លើយ

## សំណួរៈ តើសិទ្ធិអ្នកនិពន្ធនៃប្រទេសដែលពុំបានចូលរួមក្នុងសន្ធិសញ្ញាប្រព្រឹត្តទៅដូចម្តេចដែរ?

ទីមួយ យោងតាមបញ្ជីក្នុងតារាងសម្រាប់បង្ហាញពីកិច្ចព្រមព្រៀងអន្តរជាតិឬសន្ធិសញ្ញានានាដែលរួមមានប្រទេសរបស់លោកអ្នកជាសមាជិកដែរ បញ្ជាក់ឱ្យយល់ថា ពុំមានកាតព្វកិច្ចត្រូវការពារសិទ្ធិអ្នកនិពន្ធនៃប្រជាជាតិដែលមិនមែនជាសមាជិកឡើយ ។តែបើស្នាដៃនៃប្រទេសណាមួយក្នុងចំណោមប្រទេសមិនមែនជាសមាជិកត្រូវបានបោះផ្សាយឬផ្សព្វផ្សាយជាសាធារណៈលើកដំបូងនៅប្រទេសណាមួយជាសមាជិកនៃសន្ធិសញ្ញាអន្តរជាតិ ស្នាដៃនោះត្រូវទទួលបាននូវកិច្ចការពារ។ ម្យ៉ាងវិញទៀត ប្រទេសដែលមិនមែនជាសមាជិកនៃសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ ក៏ត្រូវមានកាតព្វកិច្ចទទួលនូវកិច្ចការពារស្នាដៃសិទ្ធិអ្នកនិពន្ធដែរបើប្រទេសនោះជាសមាជិកនៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពនៃកម្មសិទ្ធិបញ្ញាទាក់ទងនឹងពាណិជ្ជកម្ម (TRIPS Agreement) ដែលជាផ្នែកមួយនៃកិច្ចព្រមព្រៀងទីក្រុងម៉ារ៉ាកេសក្នុងការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក (Marrakesh Agreement Establishing theWTO) ។

## សំណួរៈ តើការបង្ហាញពីប្រភពមានន័យយ៉ាងដូចម្តេច?

ការបង្ហាញប្រភពមានន័យថា ការបញ្ជាក់ច្បាស់លាស់ពីអ្នកនិពន្ធនៃស្នាដៃដែលត្រូវបានគេដកស្រង់។ ចំណងជើងរបស់ស្នាដៃ ឈ្មោះរបស់អ្នកនិពន្ធ អ្នកបោះពុម្ពផ្សាយ ។ល។ គប្បីបង្ហាញឱ្យឃើញច្បាស់លាស់តាមរបៀបសមស្របដែលជាទម្រង់មួយត្រឹមត្រូវក្នុងការផលិតឡើងវិញឬការធ្វើអាជីវកម្ម។

## សំណួរៈ តើគេអាចសង្ខេប ឬបកប្រែសម្រង់បានឬទេ?

ជាការពិតគេអាចសង្ខេបឬបកប្រែសម្រង់បាន តែគប្បីយកចិត្តទុកដាក់ឱ្យបានល្អ ព្រោះបើសិនជាការបកប្រែ ឬសង្ខេបធ្វើឱ្យខុសន័យ នោះអាចក្លាយជាការរំលោភបំពានលើសិទ្ធិសីលធម៌របស់អ្នកនិពន្ធវិញ។

## សំណួរៈ ដូចម្តេចទៅដែលហៅថាសម្រង់រិះគន់ ឬសម្រង់ខុសពីន័យដើម?

លោកអ្នកអាចស្រង់ពីអាគតដ្ឋានបានដោយសេរីនិងដោយត្រឹមត្រូវសម្រាប់គោលបំណងធ្វើការរិះគន់។ តែបើខ្លឹមសារដកស្រង់ត្រូវបានកែប្រែឱ្យខុសពីគោលបំណងរបស់អ្នកនិពន្ធ ឬក៏ប្រើប្រាស់សម្រាប់បង្អាច់បង្ខូចលោកអ្នកនឹងទទួលការចោទប្រកាន់ពីបទរំលោភបំពានលើសិទ្ធិសីលធម៌របស់អ្នកនិពន្ធ ឬពីបទបង្ខូចកេរ្តិ៍ឈ្មោះ។ល។

# សំណួរ & ចម្លើយ

### សំណួរៈ តើគេអាច "ស្រង់រូបថត" បានឬទេ?

គោលបំណងស្រង់យករូបថតចេញពីស្នាដៃណាមួយ មិនប្រាកដថាមានឬមិនមានលក្ខខណ្ឌត្រូវអនុញ្ញាតឱ្យទេ។ ឧទាហរណ៍ដូចជា បើសិនលោកអ្នកបញ្ចូលរូបថតពាក់កណ្តាលខ្លួនរបស់អ្នកណាម្នាក់ដែលមានក្នុងស្នាដៃ ករណីនេះមិនមានសេចក្តីត្រូវការចាំបាច់ឱ្យដកស្រង់ពីស្នាដៃ "ខ" ដើម្បីបង្កើតស្នាដៃ "ក" ទេ ហើយក៏ពុំអនុញ្ញាតឱ្យស្រង់យករូបថតទៅប្រើប្រាស់បានដែរ។

### សំណួរៈ តើសៀវភៅដែលមានរូបផ្ទាំងគំនូរសមុច្ច័យ ឬកាតាឡុករូបភាពនៃការតាំងពិព័រណ៍ចាត់ទុកជាសៀវភៅ "សម្រង់" ឬទេ?

ពាក្យ "កូនសៀវភៅ" ត្រូវបានទទួលស្គាល់ដោយច្បាប់សិទ្ធិអ្នកនិពន្ធ។ សមុច្ច័យរូបភាពនៅក្នុងសៀវភៅ បង្កើតបានជាកាតាឡុកពិព័រណ៍ បណ្ណប្រកាស បណ្ណប្រៃសណីយ៍ ។ល។ សម្រាប់លក់ដូរជាពាណិជ្ជកម្មត្រូវចាត់ទុកជាការផលិតឡើងវិញ គឺមិនចាត់ជាសៀវភៅដកស្រង់ទេ។ ដូច្នេះករណីបែបនេះត្រូវអនុវត្តតាមសិទ្ធិផលិតឡើងវិញ ហើយការអធិប្បាយពីសិទ្ធិនេះមាននៅក្នុងជំពូកខាងដើម។

## សំណួរៈ តើរូបថត ឬឃ្លាខ្លីៗសម្រាប់ការផ្សាយពាណិជ្ជកម្មជា "សម្រង់" ឬទេ?

តើគេអាចដកស្រង់រូបថត រូបភាពលម្អ ឬពាក្យខ្លីៗងាយចាំចេញពីស្នាដៃរបស់ជនណាម្នាក់សម្រាប់ផ្សាយពាណិជ្ជកម្មបានឬទេ? ករណីបែបនេះពុំមានលក្ខខណ្ឌណាត្រូវឱ្យដកស្រង់បានឡើយ ដូច្នេះពុំមានការយល់ព្រមអនុញ្ញាតដាច់ខាត ។

## សំណួរៈ តើគេអាចដកយកសម្រង់ចេញពីបណ្តាញតំបន់បានឬទេ?

បណ្តាញតំបន់ជាស្នាដៃ ហើយសូម្បីតែបណ្តាញតំបន់ដែលប្រកាសជា "link-free" ក៏ត្រូវតែទទួលនូវកិច្ចការពារពីច្បាប់សិទ្ធិអ្នកនិពន្ធដែរ ។ ដើម្បីអាចប្រើប្រាស់បណ្តាញតំបន់មួយបាន ចាំបាច់ត្រូវតែមានការអនុញ្ញាត ។ តែទោះបីយ៉ាងណាក៏ដោយ ក៏មានករណីខ្លះដូចជារូបភាពលម្អនិងរូបថតដែលប្រើក្នុងបណ្តាញតំបន់ គឺត្រូវផ្តាច់ចេញពីសិទ្ធិអ្នកនិពន្ធ ។ សូមចងចាំថា ការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិរបស់បណ្តាញតំបន់ មិនអាចចាត់ទុកជាការអនុញ្ញាតផ្លូវការសម្រាប់ឱ្យប្រើប្រាស់រូបភាពឡើយ ។

## សំណួរៈ តើគេអាចដកស្រង់នូវកម្មវិធីឥតបង់ប្រាក់កម្រៃ (freeware) ចេញពីអ៊ីនធឺណិតបានដែរឬទេ?

ផ្នែកទន់ (software) ដែលមានក្នុងអ៊ិនធឺណិត រួមទាំងកម្មវិធីឥតបង់ប្រាក់កម្រៃ គេអាចដកស្រង់បានដោយមិនចាំបាច់បង់ប្រាក់កម្រៃឡើយ តែបើការដកស្រង់ shareware ចាំបាច់ត្រូវតែបង់ប្រាក់កម្រៃ ។ តើកម្មវិធីឥតបង់ប្រាក់កម្រៃ ត្រូវទទួលនូវកិច្ចការពារពីច្បាប់សិទ្ធិអ្នកនិពន្ធឬទេ? ទោះបីអាចប្រើប្រាស់ដោយសេរីមែន តែក៏មិនមានន័យថាត្រូវបដិសេធសិទ្ធិនៃកម្មវិធីនេះដែរ ។ មានករណីជាច្រើន

# សំណួរ & ចម្លើយ

អ្នកនិពន្ធនៃកម្មវិធីឥតបង់ប្រាក់កម្រៃ បានដាក់ឱ្យប្រើប្រាស់សេរីក្នុងអង្គប្រជុំដោយចំហក្នុងគោលបំណង ទទួលបានមកវិញនូវការធ្វើវិនិយោគជាដំបូងហើយនឹងតម្រូវឱ្យបង់ប្រាក់កម្រៃនាពេលអនាគតចំពោះ កម្មវិធីដែលបានកែថ្មីប្រសើរឡើង។ ករណីបែបនេះម្ចាស់សិទ្ធិមិនបដិសេធសិទ្ធិលើស្នាដៃទេ តែបានហាមឃាត់ បណ្តោះអាសន្នមិនឱ្យអនុវត្តសិទ្ធិនេះ។

## សំណួរៈ តើគេអាចបង្កើតសៀវភៅមួយមានខ្លឹមសារជាសម្រង់ស្រង់ចេញពីស្នាដៃផ្សេងបាន ឬទេ?

អ្នកបោះពុម្ពផ្សាយមួយចំនួនមានផែនការធ្វើគម្រោងបែបនេះ។ ទោះបីយ៉ាងណាក៏ដោយ ក៏ករណីនេះមិនត្រូវបានចាត់ទុកជាសម្រង់ទេ។ ការប្រមែប្រមូលខ្លឹមសារតិចតួចចេញពីខ្លឹមសារធំនៃស្នាដៃ ដែលបានបោះផ្សាយរួចហើយសម្រាប់បង្កើតតែសៀវភៅ គឺជាការធ្វើអាជីវកម្មលើស្នាដៃដោយមិនអាច ប្រកែកតវ៉ាបានឡើយ។ ករណីនេះ ពាក់ព័ន្ធទៅនឹងការប្រើប្រាស់សិទ្ធិផលិតឡើងវិញ មិនមែនជាសិទ្ធិ បោះពុម្ពផ្សាយទេ ព្រោះមានការបោះផ្សាយស្នាដៃទាំងមូល ដូច្នេះត្រូវតែមានការអនុញ្ញាតពីអ្នកនិពន្ធ មិនមែនពីអ្នកបោះពុម្ពផ្សាយឡើយ។ ហេតុនេះហើយ អ្នកបោះពុម្ពផ្សាយមិនអាចអនុញ្ញាតឱ្យតតិយជន ផលិតឡើងវិញនូវផ្នែកខ្លះនៃស្នាដៃដោយគ្មានការយល់ព្រមពីអ្នកនិពន្ធឡើយ ទោះជាការបោះផ្សាយនោះ សម្រាប់ការផ្សាយពាណិជ្ជកម្ម ឬសម្រាប់បម្រើកិច្ចការផ្សេងៗទៀតក៏ដោយ។ មានតែម្ចាស់កម្មសិទ្ធិអ្នកនិពន្ធ តែមួយគត់ដែលអាចអនុញ្ញាតសិទ្ធិបាន។

# សំណួរ & ចម្លើយ

**ដកស្រង់ពីសិក្ខាសាលាបណ្តុះបណ្តាលថ្នាក់ជាតិស្តីពីចំណេះដឹងសិទ្ធិអ្នកនិពន្ធ ដែលសហការរៀបចំដោយមជ្ឈមណ្ឌលវប្បធម៌អាស៊ី-ប៉ាស៊ីហ្វិកនៃអង្គការយូណេស្កូ និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈនៃព្រះរាជាណាចក្រកម្ពុជា នៅរាជធានីភ្នំពេញ ថ្ងៃទី៨-១០ ខែតុលា ឆ្នាំ២០០៨**

**សំណួរ : តើច្បាប់សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែលផ្តល់ប្រយោជន៍អ្វីខ្លះចំពោះអ្នកនិពន្ធ? តើច្បាប់នេះអាចផ្តល់ជាមធ្យោបាយឬក៏វិធីណាមួយដែលអាចផ្តល់លាភការដល់ម្ចាស់សិទ្ធិ?**

ច្បាប់សិទ្ធិអ្នកនិពន្ធធានាបាននូវសិទ្ធិជាម្ចាស់របស់អ្នកនិពន្ធ ប៉ុន្តែមិនមានន័យថាអ្នកនិពន្ធទាំងអស់ទទួលបាននូវប្រាក់កម្រៃជាស្វ័យប្រវត្តិនោះទេ ។ ដើម្បីចៀសវាងការជជែកគ្នា អ្នកនិពន្ធគួរតែធ្វើកិច្ចសន្យាជាលាយលក្ខអក្សរជាមួយនឹងអ្នកដែលយកស្នាដៃរបស់ខ្លួនទៅប្រើប្រាស់ ។

**សំណួរ : មានអ្នកចម្រៀងជាច្រើនដែលច្រៀងបទរបស់អ្នកដទៃ ក្នុងករណីបែបនេះតើមានពាក់ព័ន្ធនឹងច្បាប់សិទ្ធិអ្នកនិពន្ធដែរឬទេ?**

បទចម្រៀងទាំងអស់ត្រូវទទួលកិច្ចការពារពីច្បាប់សិទ្ធិអ្នកនិពន្ធ ។ ម្ចាស់បទចម្រៀងមានសិទ្ធិត្រួតពិនិត្យបទចម្រៀងរបស់ខ្លួនក្នុងការបោះពុម្ពផ្សាយ ឬក៏ច្រៀងជាសាធារណៈ ។

**សំណួរ : តើគួរមានការកែសម្រួលបន្ថែមច្បាប់សិទ្ធិអ្នកនិពន្ធ ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាទំនើបដែរឬទេ?**

ច្បាប់សិទ្ធិអ្នកនិពន្ធត្រូវតែមានការកែសម្រួលតិចតួចឱ្យទាន់សភាពការណ៍ តែចៀសវាងការអានមិនយល់ និងមានភាពស្មុគស្មាញ ។ និយាយដោយលំអិត គឺកិច្ចការអ្វីៗនៅក្នុងច្បាប់ត្រូវតែធ្វើការដោះស្រាយតាមផ្លូវច្បាប់ ។

**សំណួរ ៖ នៅពេលដែលយើងប្រើប្រាស់កម្មវិធី Microsoft តើយើងត្រូវសុំច្បាប់អនុញ្ញាតដែរឬទេ?**

អ្នកគួរតែទិញច្បាប់ចម្លងស្តីអំពីកម្មវិធីនេះ ដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ ។ អ្នកប្រើប្រាស់កុំព្យូទ័រមិនចាំបាច់សុំច្បាប់ពី Microsoft នោះទេ ។

**សំណួរ ៖ នៅពេលដែលអ្នកណាម្នាក់ប្រើប្រាស់ពត៌មាននៅក្នុងអ៊ិនធឺណិត ក្នុងការធ្វើពាណិជ្ជកម្ម តើប្រការនេះជាការរំលោភបំពានដែរឬទេ?**

នៅពេលដែលបញ្ចូលពតិមានទៅក្នុងអ៊ិនធឺណិត មានន័យថាពតិមាននោះត្រូវបានផ្សព្វផ្សាយជាសាធារណៈ ។ ប្រសិនបើអ្នកពុំអនុញ្ញាតឱ្យសាធារណជនអានពតិមាននោះ អ្នកគួរតែដាក់ជាលេខកូដសម្ងាត់ការពារគឺប្រៀបដូចជាសៀវភៅមួយក្បាលដែលអ្នកដាក់ទុកក្នុងថតតុ ហើយពុំចង់ឱ្យអ្នកណាអាន អ្នកត្រូវតែចាក់សោរថតតុនោះជាការស្រេច ។

**សំណួរ ៖ បច្ចុប្បន្ននេះមានអ្នកខ្លះបានយកបទចម្រៀងចាស់ៗពីដើម ទៅប្តូរច្រៀងជាបទសាសនា បទប្រជាប្រិយ៍ តើនេះជាការរំលោភបំពានឬទេ?**

ជាអំពើរំលោភបំពានប្រសិនបើបទចម្រៀងចាស់ៗទាំងនោះនៅក្នុងរយៈពេលនៃកិច្ចការពារពីច្បាប់សិទ្ធិអ្នកនិពន្ធ ហើយយកទៅផ្លាស់ប្តូរដោយពុំមានការអនុញ្ញាតច្បាប់ពីម្ចាស់សិទ្ធិ ។

**សំណួរ ៖ ប្រសិនបើខ្ញុំសរសេរពីឈុតសិល្បៈសម្រាប់ខ្សែភាពយន្ត ហើយមាននរណាម្នាក់យកទៅប្រើប្រាស់ដោយគ្មានការអនុញ្ញាត នោះជាការរំលោភបំពានដែរឬទេ?**

ពិតណាស់នោះគឺជាការរំលោភបំពានហើយ ។

**សំណួរ ៖ តើគេអាចចម្លងប្រវត្តិរបស់ប្រទេសដទៃបានដែរឬទេ?**

ពុំមែនជាការរំលោភបំពានឡើយ ប្រសិនការចម្លងនោះក្នុងគោលបំណងបម្រើការអប់រំសិក្សា ។

**សំណួរ : ប្រសិនបើខ្ញុំត្រូវធ្វើការផលិតឡើងវិញនូវស្នាដៃរបស់ជនណាមួយ តើខ្ញុំត្រូវសុំការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិដែរឬទេ?**

ប្រាកដណាស់ អ្នកត្រូវតែសុំការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិជាមុនសិន ទើបអាចធ្វើការផលិតឡើងវិញនូវស្នាដៃរបស់គេបាន ។

**សំណួរ : តើយើងត្រូវសុំការអនុញ្ញាតច្បាប់ដែរឬទេ ដើម្បីចម្លងនូវឯកសារផ្លូវការដូចជាច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ។ល។**

អនុលោមតាមច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល រាល់ឯកសារផ្លូវការអាចចម្លងបានដោយពុំចាំបាច់សុំការអនុញ្ញាតពីរាជរដ្ឋាភិបាលឡើយ ។

**សំណួរ : ប្រសិនបើជនណាម្នាក់ធ្វើការបកប្រែសៀវភៅពីភាសាបរទេសមកជាភាសាខ្មែរ សម្រាប់ធ្វើការបោះពុម្ពផ្សាយដោយមានការអនុញ្ញាតច្បាប់ពីម្ចាស់ដើមសៀវភៅ តើអ្នកណាជាម្ចាស់កម្មសិទ្ធិលើការបកប្រែ? អ្នកបកប្រែ ឬគ្រឹះស្ថានបោះពុម្ពផ្សាយ?**

ប្រសិនបើគ្រឹះស្ថានបោះពុម្ពផ្សាយទទួលបាននូវការអនុញ្ញាតច្បាប់ពីម្ចាស់កម្មសិទ្ធិដើម ហើយអ្នកបកប្រែគ្រាន់តែទទួលបាននូវកម្រៃក្នុងការបកប្រែ នោះម្ចាស់គ្រឹះស្ថានបោះពុម្ពផ្សាយជាម្ចាស់កម្មសិទ្ធិលើការបកប្រែ តែអ្នកបកប្រែក៏នឹងត្រូវទទួលបានកិច្ចការពារជាម្ចាស់លើសិទ្ធិសីលធម៌ ។

**សំណួរ : តើជាការរំលោភបំពានដែរឬទេ ប្រសិនបើអ្នកតែងបទភ្លេងម្នាក់ដែលសរសេរបានបទចម្រៀងតាមកិច្ចសន្យាសម្រាប់ក្រុមហ៊ុនមួយ ហើយអ្នកតែងបទភ្លេងនោះបានកែផ្នែកខ្លះនៃបទចម្រៀង និងលក់ទៅឱ្យក្រុមហ៊ុនដទៃទៀត?**

ប្រសិនបើអ្នកនិពន្ធបទភ្លេងទទួលនូវប្រាក់កម្រៃពីក្រុមហ៊ុនតាមកិច្ចសន្យា ក្រុមហ៊ុនត្រូវតែទទួលបាននូវសិទ្ធិជាម្ចាស់លើបទចម្រៀង ។ ករណីអ្នកតែងបទភ្លេងបានកែឬលក់ទៅឱ្យក្រុមហ៊ុនដទៃនោះគឺជាការរំលោភបំពាន ។ ទោះបីអ្នកនិពន្ធបទភ្លេងមានសិទ្ធិជាម្ចាស់លើបទចម្រៀងរបស់ខ្លួនដែលតែងឡើងក៏ដោយ ក៏ក្រុមហ៊ុនផ្អែកតាមកិច្ចសន្យាមានសិទ្ធិផ្ដាច់មុខក្នុងការផលិតនិងផ្សព្វផ្សាយនូវបទចម្រៀងនោះ ឯអ្នកនិពន្ធបទភ្លេងពុំមានសិទ្ធិកែខ្លឹមសារ ឬលក់ទៅឱ្យក្រុមហ៊ុនដទៃបានឡើយ ។

## សំណួរ ៖ តើអ្នកអាចធ្វើការត្រួតពិនិត្យភ្លេងការបោះពុម្ពផ្សាយសៀវភៅដែរឬទេ?

ចម្លើយតែមួយ គឺត្រូវប្រើប្រាស់ប្រព័ន្ធបោះត្រាជំនួសឱ្យការផ្ដិតមេដៃ។ ប្រសិនបើសៀវភៅច្បាប់ណាដែលពុំមាន ស្នាមបោះត្រា នោះបង្ហាញឱ្យយើងឃើញថាជាសៀវភៅដែលខុសច្បាប់ និងលួចចម្លង។

## សំណួរ ៖ នៅកម្ពុជាតើស្នាដៃបរទេសត្រូវទទួលនូវកិច្ចការពារពីច្បាប់ដែរឬតែ?

បច្ចុប្បន្នកម្ពុជាជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ដូច្នេះរាល់ស្នាដៃបរទេសទាំងអស់ដែលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោកត្រូវតែទទួលនូវកិច្ចការពារពីច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលរបស់កម្ពុជា។

## សំណួរ ៖ ប្រសិនបើមានការផ្សាយពាណិជ្ជកម្មដ៏មានប្រជាប្រិយតាមទូរទស្សន៍ស្តីពីអ្នកធ្វើរថយន្ត ដែលឈុតផ្សព្វផ្សាយនោះផលិតឡើងដោយធ្វើត្រាប់តាមគេទាំងអស់ ឬប្រហាក់ប្រហែល តើនេះជាការរំលោភបំពានឬទេ?

ករណីនេះអាចថាជាការរំលោភបំពានឬមិនមែន អាស្រ័យលើខ្លឹមសារក្នុងឈុតផ្សព្វផ្សាយនោះយកតម្រាប់តាមគេភាគច្រើនឬស្ទើរតែទាំងអស់។ ប្រសិនបើយកតម្រាប់តាមលើផ្នែកគំនិត ទស្សនាទានប្រការនេះមិនថ្មីទេ។ ប៉ុន្តែពាក្យពេចន៍ ខ្លឹមសារ បើចម្លងតាមគេស្ទើរតែទាំងអស់ នោះគឺជាការរំលោភបំពាន។ ដើម្បីងាយស្រួលក្នុងការដោះស្រាយ ត្រូវតែអនុវត្តតាមផ្លូវច្បាប់។



# សេចក្តីបន្ថែម

## អនុសញ្ញា សន្ធិសញ្ញា និងនិន្នាការអន្តរជាតិ



# សេចក្តីបន្ថែម | អនុសញ្ញា សន្ធិសញ្ញា និងនិន្នាការអន្តរជាតិ

ប្រព័ន្ធច្បាប់ដែលទាក់ទងទៅនឹងកម្មសិទ្ធិបញ្ញាមានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ដោយផ្អែកតាមនយោបាយវប្បធម៌ និងឧស្សាហកម្ម ព្រមទាំងកត្តាផ្សេងៗទៀត។ ភាពចម្រើនជឿនលឿនឆាប់រហ័សរបស់សកលភាវូបនីយកម្ម តាមរយៈការបង្កើតហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងគមនាគមន៍បានបង្កើតឱ្យមានបញ្ហាថ្មីៗដូចជាការប៉ះទង្គិចគ្នា និងទំនាស់ខាងពាណិជ្ជកម្មស្តីពីកម្មសិទ្ធិបញ្ញា។ ពិសេសទំនាស់ខាងសិទ្ធិអ្នកនិពន្ធ រួមមានការលួចចម្លងស៊ីឌីតូរ្យតន្ត្រី និងកុំព្យូទ័រផ្អែកទន់ បង្កឱ្យកើតជាបញ្ហាធំធេង។ នាទសវត្សរ៍កន្លងទៅ ដើម្បីដោះស្រាយបញ្ហានេះ ប្រទេសនានាដែលពុំធ្លាប់មានច្បាប់ក៏បានអនុម័តបង្កើតច្បាប់ទទួលជោគជ័យជាបន្តបន្ទាប់។ តែការបង្កើតច្បាប់នៅតាមប្រទេសនិមួយៗក៏ពុំទាន់មានប្រសិទ្ធិភាពគ្រប់គ្រាន់សម្រាប់ត្រួតពិនិត្យបញ្ហាទាំងនោះបានដែរ។ ដូច្នេះ ដើម្បីរកឱ្យឃើញនូវដំណោះស្រាយជាអន្តរជាតិមួយ គេក៏បានបង្កើតបណ្តាញនិងច្បាប់ផ្សេងៗថែមទៀត។ ចំណុចសំខាន់បំផុតនៃកិច្ចការទាំងនោះមានអធិប្បាយនៅខាងក្រោម។ (ចំនួនប្រជាជាតិ និងតំបន់ជាសមាជិកគិតត្រឹមខែកុម្ភៈ ឆ្នាំ២០០៩។ ឯក្រុងហុងកុង និងម៉ាកាវ តម្រូវឱ្យមានការចុះហត្ថលេខាដោយប្រទេសចិន ទើបអាចសុំចូលជាសមាជិកសន្ធិសញ្ញាសិទ្ធិអ្នកនិពន្ធ និងសន្ធិសញ្ញាសិទ្ធិប្រហាក់ប្រហែល។)

## ● **អនុសញ្ញាទីក្រុងប៊ែន** (Berne Convention)

ឈ្មោះពេញនៃអនុសញ្ញានេះ គឺអនុសញ្ញាទីក្រុងប៊ែនសម្រាប់ការពារស្នាដៃអក្សរសាស្ត្រ និងស្នាដៃសិល្បៈ (The Berne Convention for the Protection of Literary and Artistic Works)។ អនុសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិអ្នកនិពន្ធនេះមានអាយុចាស់បំផុត ដែលកើតឡើងតាំងពីឆ្នាំ១៨៨៦ និង

បានកែសម្រួលនៅទីក្រុងរ៉ូម នាឆ្នាំ ១៩២៨ នៅទីក្រុងប្រ៊ុចសែលនាឆ្នាំ១៩៤៨ ហើយនៅទីក្រុងប៉ារីស នាឆ្នាំ១៩៧៥។ សព្វថ្ងៃអនុសញ្ញានេះមានសមាជិកទាំងអស់ចំនួន១៦៤ប្រទេស រួមមានសហរដ្ឋអាមេរិក ដែលទើបបានចូលជាសមាជិកនៅឆ្នាំ១៩៨៩។ អនុសញ្ញាទីក្រុងប៊ែនមានគោលការណ៍សំខាន់ៗចំនួនបីគឺៈ ១-ប្រព្រឹត្តិកម្មថ្នាក់ជាតិ (យោងតាមអនុសញ្ញាទីក្រុង ប៉ារីស)។ ២-ប្រតិសកម្ម (គ្រប់ស្នាដៃទាំងអស់ត្រូវទទួលនូវកិច្ចការពារ ទោះបីស្នាដៃទាំងឡាយដែលបានផ្សព្វ ផ្សាយមុនពេលអនុសញ្ញាចូលជាធរមានក៏ដោយ លើកលែងតែស្នាដៃណាដែលបានក្លាយជាទ្រព្យសម្បត្តិ សាធារណៈរួចទៅហើយ) ។ ៣-គ្មានលក្ខខណ្ឌ(មានកិច្ចការពារជាស្វ័យប្រវត្តិ ហើយពុំមានលក្ខខណ្ឌត្រូវបំពេញ បែបបទឡើយ)។

## អនុសញ្ញាសកលស្តីពីសិទ្ធិអ្នកនិពន្ធ (Universal Copyright Convention)

សហរដ្ឋអាមេរិកនិងប្រទេសនៅតំបន់អាមេរិកឡាទីន ទាមទារការចុះបញ្ជី តំកល់ និងបញ្ជាក់អំពីអត្តសញ្ញាណសម្គាល់ស្នាដៃអ្នកនិពន្ធ ទើបទទួលបាននូវកិច្ចការពារពីច្បាប់សិទ្ធិអ្នកនិពន្ធ។ ដូច្នេះហើយបានជាកាលពីមុននេះ ប្រទេសទាំងឡាយនោះមិនព្រមចូលរួមជាសមាជិកនៃអនុសញ្ញាទីក្រុងប៊ែនដែលទទួលការពារសិទ្ធិអ្នកនិពន្ធដោយគ្មានលក្ខខណ្ឌទេ។ ហេតុនេះជាភាពចាំបាច់មិនអាចខ្វះបាន ទើបមានការបង្កើតជាកិច្ចសន្យារវាងប្រទេសទាមទារបែបបទ និងប្រទេសការពារសិទ្ធិអ្នកនិពន្ធដោយគ្មានលក្ខខណ្ឌដែលជាសមាជិកអនុសញ្ញាទីក្រុងប៊ែន។ នាឆ្នាំ១៩៥២រួមជាមួយអង្គការយូណេស្កូ UNESCO ដែលទទួលនាទីជាអ្នកកណ្តាលបានបង្កើតអនុសញ្ញាសកលស្តីពីសិទ្ធិអ្នកនិពន្ធ ហើយអនុញ្ញាតឱ្យប្រទេសទាំងពីរក្រុមក្លាយជាសមាជិក។ អនុសញ្ញាថ្មីនេះបានផ្តល់លទ្ធភាពឱ្យការពារស្នាដៃរបស់ប្រទេសជាសមាជិកនៃអនុសញ្ញាទីក្រុងប៊ែន និងប្រទេសដែលមានច្បាប់ទាមទារការបំពេញបែបបទការពារស្នាដៃដូចជាការបញ្ជាក់បង្ហាញនូវនិមិត្តសញ្ញាសិទ្ធិអ្នកនិពន្ធ ឈ្មោះម្ចាស់កម្មសិទ្ធិ ហើយនិងឆ្នាំបោះពុម្ពផ្សាយជាលើកដំបូង។ អង្គការយូណេស្កូ UNESCO ជាអ្នកទទួលកាន់កិច្ចការនៃអនុសញ្ញានេះ។ លើសពីការបញ្ជាក់បង្ហាញអំពីនិមិត្តសញ្ញាសិទ្ធិអ្នកនិពន្ធ ក៏នៅមានលក្ខណៈពិសេសផ្សេងៗទៀតរបស់អនុសញ្ញារួមមាន ប្រព្រឹត្តិកម្មថ្នាក់ជាតិ (សូមអានផ្នែកខាងលើ)និងភាពគ្មានប្រតិសកម្ម (ពេលត្រូវបានចុះហត្ថលេខា អនុសញ្ញានេះ មិនអនុវត្តចំពោះស្នាដៃដែលមិនទទួលនូវកិច្ចការពារក្នុងប្រទេសទាមទារការផ្តល់នូវកិច្ចការពារទេ)។ បច្ចុប្បន្នអនុសញ្ញានេះមានប្រទេសជាសមាជិកចំនួន៩៨។

- **អនុសញ្ញាទីក្រុងរ៉ូម (The Rome Convention) ឬអនុសញ្ញាអន្តរជាតិសម្រាប់ការពារអ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ**

អនុសញ្ញានេះបង្កើតឡើងដោយសម្ព័ន្ធភាពទីក្រុងប៊ែន (The Berne Alliance) អង្គការពលកម្មអន្តរជាតិ (ILO) និងអង្គការយូណេស្កូ (UNESCO) សម្រាប់ការពារសិទ្ធិអ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ ។ ទោះបីប្រព្រឹត្តិកម្មថ្នាក់ជាតិជាលក្ខណៈពិសេសមួយក្នុងចំណោមលក្ខណៈពិសេសៗនៃអនុសញ្ញានេះក៏ដោយ ក៏មិនដូចប្រព្រឹត្តិកម្មថ្នាក់ជាតិដែលស្ថិតក្រោមអនុសញ្ញាទីក្រុងប៊ែន និងអនុសញ្ញាផ្សេងៗទៀតដែរ ។ ប្រព្រឹត្តិកម្មថ្នាក់ជាតិនេះ ផ្តល់កិច្ចការពារថ្នាក់ជាតិចំពោះតែសិទ្ធិណាដែលមានចែងក្នុងអនុសញ្ញានេះប៉ុណ្ណោះ ។ ចំណែកឯបទប្បញ្ញត្តិនៃកិច្ចការពារ គឺផ្តល់សិទ្ធិចំពោះអ្នកសម្តែងដើម្បីបញ្ឈប់ការផ្សាយតាមទូរផ្សាយ ការថតចម្លងនិងការថតខ្សែភាពយន្តអំពីការសម្តែងដោយគ្មានការអនុញ្ញាតសិទ្ធិ ហើយក៏ផ្តល់សិទ្ធិដើម្បីទទួលបាននូវប្រាក់កម្រៃជើងសារសម្រាប់ការប្រើប្រាស់ស្នាដៃជាលើកទីពីរតាមទូរផ្សាយដែលបម្រើគោលដៅពាណិជ្ជកម្ម ។ មានការផ្តល់សិទ្ធិចំពោះផលិតករហ្វូណូក្រាមគឺសិទ្ធិផលិតឡើងវិញនូវស្នាដៃ និងសិទ្ធិទទួលប្រាក់កម្រៃជើងសារចំពោះការប្រើប្រាស់ជាលើកទីពីរនូវស្នាដៃក្នុងគោលដៅពាណិជ្ជកម្មតាមទូរផ្សាយ ។ ផ្តល់សិទ្ធិចំពោះអង្គភាពទូរផ្សាយដើម្បីផ្សាយឡើងវិញតាមទូរផ្សាយនិងសិទ្ធិថតចម្លងសម្លេងនិងរូបភាព ។ សព្វថ្ងៃនេះអនុសញ្ញាទីក្រុងរ៉ូមមានប្រទេសជា សមាជិកចំនួន៨៧ ។

- **សន្ធិសញ្ញាការពារហ្វូណូក្រាម (Phonogram Protection Treaty)**

អង្គការយូណេស្កូ UNESCO និងអង្គការកម្មសិទ្ធិបញ្ញាពិភពលោក WIPO បានបង្កើតសន្ធិសញ្ញាការពារហ្វូណូក្រាមនាឆ្នាំ១៩៧១ ក្នុងគោលបំណងការពារហ្វូណូក្រាមដើម្បីមិនឱ្យមានការលួចចម្លង ។ លើសពីនេះ គឺដើម្បីហាមឃាត់ការផលិតហ្វូណូក្រាមឡើងវិញដោយគ្មានការអនុញ្ញាត និងការពារសិទ្ធិផលិតករហ្វូណូក្រាមនៃប្រទេសជាសមាជិកដែលពាក់ព័ន្ធនឹងការនាំចូលនិងការចែកចាយហ្វូណូក្រាម ។ សព្វថ្ងៃសន្ធិសញ្ញាការពារហ្វូណូក្រាមមាន ប្រទេសជាសមាជិកចំនួន៧៣ ។

- **ការប្រជុំតុមូលនៅអ៊ុយរូហ្គាយ និងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក (Uruguay Round and the WTO Agreement)**

ការចរចាពហុភាគីក្នុងអង្គប្រជុំតុមូលនៅប្រទេសអ៊ុយរូហ្គាយនាឆ្នាំ១៩៨៦ បានសម្រេចជាកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្ម (GATT) ។ បន្ទាប់មកមានការពិភាក្សាអស់រយៈពេលប្រាំបីឆ្នាំលើប្រធានបទស្តីពីកម្មសិទ្ធិបញ្ញា ហើយទទួលលទ្ធផលជាកិច្ចព្រមព្រៀងម៉ារ៉ាកេសសម្រាប់បង្កើតអង្គការ

ពាណិជ្ជកម្មពិភពលោក (WTO Agreement) ទើបអង្គការនេះបានកើតឡើងនាឆ្នាំ១៩៩៥។ កិច្ចព្រមព្រៀងនេះបានរំលាយចោលកិច្ចព្រមព្រៀងស្ដីពីពន្ធគយនិងពាណិជ្ជកម្ម (GATT) ហើយបង្កើតជំនួសវិញនូវអង្គការពាណិជ្ជកម្មពិភពលោក។ ដើម្បីមានច្បាប់ថ្មីសម្រាប់ការពារកម្មសិទ្ធិបញ្ញា កិច្ចព្រមព្រៀងស្ដីពីទិដ្ឋភាពនៃកម្មសិទ្ធិបញ្ញាទាក់ទងនឹងពាណិជ្ជកម្ម (TRIPS) ក៏ត្រូវបានបង្កើតឡើង។ ប្រទេសកម្ពុជាបានចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោកនាថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤ បន្ទាប់ពីកម្ពុជាបង្កើតបានច្បាប់សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល។

- **កិច្ចព្រមព្រៀងស្ដីពីទិដ្ឋភាពនៃកម្មសិទ្ធិបញ្ញាទាក់ទងនឹងពាណិជ្ជកម្ម (TRIPS)**

កិច្ចព្រមព្រៀងនេះមាន៧ផ្នែកនិង៧៣មាត្រា ហើយចែងពីសិទ្ធិនៃកម្មសិទ្ធិបញ្ញាដូចតទៅៈ ១-សិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល។ ២-ពាណិជ្ជនាម។ ៣-ការចង្អុលភូមិសាស្ត្រ។ ៤-គំនូរឧស្សាហកម្ម។ ៥-ប្រកាសនីយ បត្រតក្កកម្ម។ ៦-គំនូសបង្ហាញនៃសៀវគ្គីបង្រួម។ ៧-កិច្ចការពារពត៌មានសម្ងាត់។ ៨-ត្រួតពិនិត្យការអនុវត្ត សកម្មភាពមិនមែនប្រកួតប្រជែងក្នុងកិច្ចសន្យា។ ពាក់ព័ន្ធទៅនឹងសិទ្ធិអ្នកនិពន្ធជាដំបូងត្រូវតែគោរពតាមបញ្ញត្តិ ទាំងឡាយនៃអនុសញ្ញាទីក្រុងប៊ែន ហើយអនុសញ្ញានេះថែមទាំងទទួលស្គាល់ចលនាដែលនាំទៅដល់ការបង្កើន រយៈពេលនៃកិច្ចការពារទៀតផង។ សព្វថ្ងៃមានប្រទេសចំនួន១៥៣ជាសមាជិកនៃកិច្ចព្រមព្រៀងនេះ។

## អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO)

អង្គការកម្មសិទ្ធិបញ្ញាពិភពលោកជាអង្គការអន្តរជាតិមួយបង្កើតឡើងនាឆ្នាំ១៩៧០ ក្នុងគោលដៅជំរុញកិច្ចការពារកម្មសិទ្ធិបញ្ញាទូទាំងពិភពលោក និងធានាកិច្ចសហប្រតិបត្តិការរបស់សម្ព័ន្ធមិត្តខាងការងាររដ្ឋបាល។ ឆ្នាំ១៩៧៤ អង្គការនេះបានក្លាយជាភ្នាក់ងារមួយរបស់អង្គការសហប្រជាជាតិ ហើយមានទីស្នាក់ការនៅទីក្រុងហ្សឺណែវប្រទេសស្វីស។

ឆ្លើយតបទៅនឹងការអភិវឌ្ឍឆាប់រហ័សនៃបច្ចេកវិទ្យាពត៌មាន ដូចជាអ៊ិនធើណែត និងការប្រែប្រួលរីកចម្រើននៃលក្ខខណ្ឌសង្គម អង្គការកម្មសិទ្ធិបញ្ញាពិភពលោកខិតខំស្វែងរកមធ្យោបាយដើម្បីពង្រឹងកិច្ចការពារសិទ្ធិអ្នកនិពន្ធជាអន្តរជាតិ។ អង្គការនេះបានបង្កើតឧបសម្ព័ន្ធរបស់អនុសញ្ញាក្រុងប៊ែន ដែលបានពិនិត្យតាំងពីឆ្នាំ១៩៩១ ហើយ សម្រេចបានជាសន្ធិសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោកស្ដីពីសិទ្ធិអ្នកនិពន្ធ (WIPO Copyright Treaty) និងសន្ធិសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោកស្ដីពីអ្នកសម្ដែង និងហ្វូណូក្រាម (WIPO Performers and Phonograms Treaty) ។

## ● សន្ធិសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោកស្តីពីសិទ្ធិអ្នកនិពន្ធ

**(WIPO Copyright Treaty)**

អនុសញ្ញាក្រុងប៊ែនត្រូវគេកែសម្រួលឡើងវិញរៀងរាល់ម្ភៃឆ្នាំម្តង។ ទោះបីចំនួនប្រជាជាតិជាសមាជិកកើនឡើងក៏ដោយ ក៏ការកែសម្រួលត្រូវទាមទារការបោះឆ្នោតយល់ព្រមជាឯកច្ឆន្ទពីសម្ពន្ធមិត្តទាំងមូល។ ការបង្កើតសន្ធិសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោកស្តីពីសិទ្ធិអ្នកនិពន្ធ សម្រាប់បំពេញបន្ថែម និងពង្រឹងអនុសញ្ញាក្រុងប៊ែន ដើម្បីឆ្លើយតបទៅនឹងឌីជីថលនីយកម្ម និងបណ្តាញ។ ហេតុនេះ គោលការណ៍ជាមូលដ្ឋាននៃប្រព្រឹត្តិកម្មថ្នាក់ជាតិ កិច្ចការពារដោយគ្មានលក្ខខណ្ឌ និងប្រតិសកម្ម គឺរក្សានៅដដែល។ ឯខ្លឹមសារចំបងៗរបស់សន្ធិសញ្ញានេះមានដូចតទៅ: ១-ការពារកម្មវិធីកុំព្យូទ័រ។ ២-ការពារការចងក្រងប្រព័ន្ធទិន្នន័យ។ ៣-បទប្បញ្ញត្តិស្តីពីការផ្ទេរសិទ្ធិសម្រាប់គ្រប់ស្នាដៃ។ ៤-សិទ្ធិបេតិកភណ្ឌដែលពាក់ព័ន្ធនឹងកម្មវិធីកុំព្យូទ័រ ស្នាដៃភាពយន្ត និងហ្វូណូក្រាម។ ៥-សិទ្ធិផ្សព្វផ្សាយជាសាធារណៈ(សិទ្ធិបញ្ជូនស្នាដៃជាអន្តរកម្ម និងសិទ្ធិបញ្ជូនស្នាដៃតាមបណ្តាញ)។ ៦-បង្កើនរយៈពេលនៃកិច្ចការពាររូបថត(ច្រើនជាង៥០ឆ្នាំក្រោយថ្ងៃទទួលមរណភាពរបស់អ្នកនិពន្ធ)។ ៧-ហាមឃាត់ការបួរច្បាប់ចម្លងដែលទទួលនូវកិច្ចការពារពីច្បាប់ ។ល។ ៨-ហាមឃាត់ការកែប្រែសិទ្ធិគ្រប់គ្រងពតិមាន។ សព្វថ្ងៃសន្ធិសញ្ញានេះមានប្រទេសចំនួន៦៧ជាសមាជិក។

## ● សន្ធិសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោកស្តីពីអ្នកសម្តែងនិងហ្វូណូក្រាម

**(WIPO Performers and Phonograms Treaty)**

ថ្វីដ្បិតតែប្រធានបទនៃសន្ធិសញ្ញាចែងពីអ្នកសម្តែងនិងផលិតករហ្វូណូក្រាម តែសន្ធិសញ្ញានេះផ្តាច់ចេញទាំងស្រុងពីអនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារអ្នកសម្តែង ។ល។ និងសន្ធិសញ្ញាគោលស្តីពីសិទ្ធិប្រហាក់ប្រហែលពីព្រោះសហរដ្ឋអាមេរិកមិនទាន់បានផ្តល់សច្ចាប័នចំពោះសន្ធិសញ្ញានេះនៅឡើយ ។ខ្លឹមសារសំខាន់ៗនៃសន្ធិសញ្ញានេះមានៈ ១-ទទួលស្គាល់សិទ្ធិសីលធម៌ និងសិទ្ធិផ្សព្វផ្សាយស្នាដៃជាសាធារណៈរបស់អ្នកសម្តែង ។ល។ ២-ផ្តល់សិទ្ធិផ្សេងៗដូចជាសិទ្ធិផលិតឡើងវិញ សិទ្ធិជួលសម្រាប់បម្រើពាណិជ្ជកម្ម និងសិទ្ធិផ្ទេរសិទ្ធិ ចំពោះអ្នកសម្តែងដែលពាក់ព័ន្ធជាមួយនឹងផលិតករហ្វូណូក្រាម និងផលិតករថតចម្លង។ សន្ធិសញ្ញានេះមានចែងតែពីការសម្តែងណាដែលបន្លឺសម្លេងប៉ុណ្ណោះ។ មានប្រទេសចំនួន៦៦ជាសមាជិកនៃសន្ធិសញ្ញានេះ។

ដោយអនុវត្តតាមមធ្យោបាយបែបនេះហើយ ទើបប្រទេសទាំងឡាយលើសកលលោកបានបង្កើតជាគម្រោងសម្រាប់ការពារសិទ្ធិអ្នកនិពន្ធជាអន្តរជាតិ ។ ឆ្នាំកន្លងទៅថ្មីៗនេះ ប្រព័ន្ធអន្តរជាតិសម្រាប់ការពារកម្មសិទ្ធិបញ្ញា ដែលរួមមានសិទ្ធិអ្នកនិពន្ធ បានធ្វើឱ្យមានភាពសុខដុមរមនាកាន់តែប្រសើរឡើងៗ ។



# ប្រជាជាតិជាសមាជិកនៃអង្គការអន្តរជាតិ





# ប្រជាជាតិជាសមាជិកនៃអង្គការអន្តរជាតិ

(ស្រង់ពីឯកសារអង្គការកម្មសិទ្ធិបញ្ញាពិភពលោកនិងអង្គការពាណិជ្ជកម្មពិភពលោក ខែកុម្ភៈឆ្នាំ២០០៩)

| ប្រជាជាតិ | អង្គការកម្មសិទ្ធិបញ្ញាពិភពលោក(WIPO) | អង្គការពាណិជ្ជកម្មពិភពលោក (WTO) |
|---|---|---|
| អាហ្វហ្គានីស្ថាន | ✓ | |
| អាល់បានី | ✓ | ✓ |
| អាល់ហ្សេរី | ✓ | |
| អង់ដូរ៉ា | ✓ | |
| អង់ហ្គោឡា | ✓ | ✓ |
| អង់ទីហ្គា និងបាប៊ុយដា | ✓ | ✓ |
| អាហ្សង់ទីន | ✓ | ✓ |
| អាមេនី | ✓ | ✓ |
| អូស្ត្រាលី | ✓ | ✓ |
| អូទ្រីស | ✓ | ✓ |
| អាស៊ែបៃហ្សង់ | ✓ | |
| បាហាម៉ា | ✓ | |
| បារ៉ែន | ✓ | ✓ |
| បង់ក្លាដែស | ✓ | ✓ |
| បាបាដុស | ✓ | ✓ |
| បេឡារុស | ✓ | |
| បែលហ្សិក | ✓ | ✓ |
| បេលី | ✓ | ✓ |
| បេណាំង | ✓ | ✓ |
| ប៊ូតង់ | ✓ | |
| បូលីវី | ✓ | ✓ |
| បូស្នី | ✓ | |
| បុតស្វាណា | ✓ | ✓ |

| | | |
|---|---|---|
| ប្រេស៊ីល | ✓ | ✓ |
| ព្រុយណេ | ✓ | ✓ |
| ប៊ុលហ្គារី | ✓ | ✓ |
| បួគីណាហ្វាសូ | ✓ | ✓ |
| ប៊ូរុនឌី | ✓ | ✓ |
| កម្ពុជា | ✓ | ✓ |
| កាមេរូន | ✓ | ✓ |
| កាណាដា | ✓ | ✓ |
| កាប់វែរ | ✓ | ✓ |
| សាធារណរដ្ឋអាហ្វ្រិកកណ្តាល | ✓ | ✓ |
|ឆាដ | ✓ | ✓ |
| ស៊ីលី | ✓ | ✓ |
| ចិន | ✓ | ✓ |
| កូឡុំប៊ី | ✓ | ✓ |
| កូម័រ | ✓ | |
| កុងហ្គោ | ✓ | ✓ |
| កូស្តារីកា | ✓ | ✓ |
| កូឌីវ័រ | ✓ | ✓ |
| ក្រូអាស៊ី | ✓ | ✓ |
| គុយបា | ✓ | ✓ |
| ស៊ីប | ✓ | ✓ |
| សាធារណរដ្ឋឆែក | ✓ | ✓ |
| សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ | ✓ | |
| សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ | ✓ | ✓ |
| ដាណឺម៉ាក | ✓ | ✓ |
| ជីប៊ូទី | ✓ | ✓ |
| ដូមីនីក | ✓ | ✓ |

| | | |
|---|---|---|
| សាធារណរដ្ឋ ដូមីនីក | ✓ | ✓ |
| អេក្វាទ័រ | ✓ | ✓ |
| អេហ្ស៊ីប | ✓ | ✓ |
| អែលសាល់វ៉ាឌ័រ | ✓ | ✓ |
| ហ្គីណេ អេក្វាទ័រ | ✓ | |
| អេរីត្រេ | ✓ | |
| អេស្តូនី | ✓ | ✓ |
| អេត្យូពី | ✓ | |
| ហ្វីជី | ✓ | ✓ |
| សហគមន៍អឺរ៉ុប | | ✓ |
| ហ្វាំងឡង់ | ✓ | ✓ |
| បារាំង | ✓ | ✓ |
| ហ្គាបុង | ✓ | ✓ |
| ហ្គំប៊ី | ✓ | ✓ |
| ហ្សកហ្ស៊ី | ✓ | ✓ |
| អាល្លឺម៉ង់ | ✓ | ✓ |
| ហ្គាណា | ✓ | ✓ |
| ក្រិក | ✓ | ✓ |
| ហ្គ្រើណាត | ✓ | ✓ |
| ក្វាតេម៉ាឡា | ✓ | ✓ |
| ហ្គីណេ | ✓ | ✓ |
| ហ្គីណេប៊ីស្សូ | ✓ | ✓ |
| ហ្គីយ៉ាន | ✓ | ✓ |
| ហៃទី | ✓ | ✓ |
| បុរីវ៉ាទីកង់ | ✓ | |
| ហុងកុង (ចិន) | | ✓ |
| ហុងឌូរ៉ាស | ✓ | ✓ |
| ហុងគ្រី | ✓ | ✓ |

| | | |
|---|---|---|
| អ៊ីស្លង់ | ✓ | ✓ |
| ឥណ្ឌា | ✓ | ✓ |
| ឥណ្ឌូណេស៊ី | ✓ | ✓ |
| អ៊ីរ៉ង់ | ✓ | |
| អ៊ីរ៉ាក់ | ✓ | |
| អៀរឡង់ | ✓ | ✓ |
| អ៊ីស្រាអែល | ✓ | ✓ |
| អ៊ីតាលី | ✓ | ✓ |
| ហ្សាម៉ាអ៊ីក | ✓ | ✓ |
| ជប៉ុន | ✓ | ✓ |
| ហ៊្សកដានី | ✓ | ✓ |
| កាហ្សាក់ស្ថាន | ✓ | |
| កេនយ៉ា | ✓ | ✓ |
| កូវ៉ែត | ✓ | ✓ |
| កៀហ្ស៊ីស៊ីស្ថាន | ✓ | ✓ |
| សាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ | ✓ | |
| ឡេតូនី | ✓ | ✓ |
| លីបង់ | ✓ | |
| ឡេសូតូ | ✓ | ✓ |
| លីបេរីយ៉ា | ✓ | |
| លីប៊ី | ✓ | |
| ឡិចតិនស្តាញ | ✓ | ✓ |
| លីទុយអានី | ✓ | ✓ |
| លុចហ្សំបួ | ✓ | ✓ |
| ម៉ាកាវ (ចិន) | | ✓ |
| ម៉ាដាហ្គាស្កា | ✓ | ✓ |
| ម៉ាឡាវី | ✓ | ✓ |
| ម៉ាឡេស៊ី | ✓ | ✓ |

| | | |
|---|---|---|
| ម៉ាល់ឌីវ | ✓ | ✓ |
| ម៉ាលី | ✓ | ✓ |
| ម៉ាល់ត៍ | ✓ | ✓ |
| ម៉ូរីតានី | ✓ | ✓ |
| ម៉ូរីស | ✓ | ✓ |
| ម៉ិកស៊ិក | ✓ | ✓ |
| ម៉ុលដាវី | ✓ | ✓ |
| ម៉ូណាកូ | ✓ | |
| ម៉ុងហ្គោលី | ✓ | ✓ |
| ម៉ុងតេណេហ្គ្រូ | ✓ | |
| ម៉ារ៉ុក | ✓ | ✓ |
| ម៉ូសំប៊ិក | ✓ | ✓ |
| មីយ៉ាន់ម៉ា | ✓ | ✓ |
| ណាមីប៊ី | ✓ | ✓ |
| នេប៉ាល | ✓ | ✓ |
| ហូឡង់ | ✓ | ✓ |
| នូវ៉ែលសេឡង់ | ✓ | ✓ |
| នីការ៉ាហ្គ័រ | ✓ | ✓ |
| នីហ្សេ | ✓ | ✓ |
| នីហ្សេរីយ៉ា | ✓ | ✓ |
| ន័រវែស | ✓ | ✓ |
| អូម៉ង់ | ✓ | ✓ |
| ប៉ាគីស្ថាន | ✓ | ✓ |
| ប៉ាណាម៉ា | ✓ | ✓ |
| ប៉ាពួនូវ៉ែលហ្គីណេ | ✓ | ✓ |
| ប៉ារ៉ាហ្គាយ | ✓ | ✓ |
| ប៉េរូ | ✓ | ✓ |
| ហ្វីលីពីន | ✓ | ✓ |

| | | |
|---|---|---|
| ប៉ូឡូញ | ✓ | ✓ |
| ព័រទុយហ្គាល់ | ✓ | ✓ |
| កាតា | ✓ | ✓ |
| សាធារណរដ្ឋ កូរ៉េ | ✓ | ✓ |
| រ៉ូម៉ានី | ✓ | ✓ |
| សហព័ន្ធរុស្សី | ✓ | |
| រវ៉ាន់ដា | ✓ | ✓ |
| សាំងឃីត និង ណេវីស | ✓ | ✓ |
| សាំងលូស៊ី | ✓ | ✓ |
| សាំងវ៉ាំងសង់ និង ហ្គ្រីនណាឌីន | ✓ | ✓ |
| សាម័រ | ✓ | |
| សានម៉ារីណូ | ✓ | |
| សៅតូម៉េ និង ប្រាំងស៊ីប | ✓ | |
| អារ៉ាប់ប៊ីសាអូឌីត | ✓ | ✓ |
| សេណេហ្គាល់ | ✓ | ✓ |
| សែប៊ី | ✓ | |
| សីស្ហែល | ✓ | |
| សៀរ៉ាឡេអូន | ✓ | ✓ |
| សិង្ហបុរី | ✓ | ✓ |
| ស្លូវ៉ាគី | ✓ | ✓ |
| ស្លូវេនី | ✓ | ✓ |
| កោះសូឡូម៉ុង | | ✓ |
| សូម៉ាលី | ✓ | |
| អាហ្វ្រិកខាងត្បូង | ✓ | ✓ |
| អេស្ប៉ាញ | ✓ | ✓ |
| ស្រីលង្កា | ✓ | ✓ |
| ស៊ូដង់ | ✓ | |
| សូរីណាម | ✓ | ✓ |

| | | |
|---|---|---|
| ស្វាហ្ស៊ីឡង់ | ✓ | ✓ |
| ស៊ុយអែត | ✓ | ✓ |
| ស្វីស | ✓ | ✓ |
| ចិនតៃប៉ិ | | ✓ |
| សាធារណរដ្ឋ អារ៉ាប់ ស៊ីរី | ✓ | |
| តង់ហ្សានី | | ✓ |
| តាហ្ស៊ីគីស្ថាន | ✓ | |
| ថៃឡង់ | ✓ | ✓ |
| ម៉ាសេដូនី (អតីតសាធារណរដ្ឋ យូហ្គោស្លាវី ) | ✓ | ✓ |
| តូហ្គោ | ✓ | ✓ |
| តុងហ្គា | ✓ | ✓ |
| ទ្រីនីដាត និង តូបាហ្គោ | ✓ | ✓ |
| ទុយនីស៊ី | ✓ | ✓ |
| ទួកគី | ✓ | ✓ |
| ទួកម៉េនីស្ថាន | ✓ | |
| អ៊ូហ្គង់ដា | ✓ | ✓ |
| អ៊ុយក្រែន | ✓ | ✓ |
| អេមីរ៉ាត់អារ៉ាប់រួម | ✓ | ✓ |
| ចក្រភពអង់គ្លេស | ✓ | ✓ |
| សហរដ្ឋអាមេរិក | ✓ | ✓ |
| អ៊ុរុយហ្គាយ | ✓ | ✓ |
| អ៊ូសបេគីស្ថាន | ✓ | |
| វ៉េណេហ្ស៊ុយអេឡា | ✓ | ✓ |
| វៀតណាម | ✓ | ✓ |
| យេម៉ែន | ✓ | |
| សំប៊ី | ✓ | ✓ |
| ស៊ីមបាវ៉េ | ✓ | ✓ |

# សៀវភៅ
# សិទ្ធិអ្នកនិពន្ធ
# អ្នកស្រុកអាស៊ី

បោះពុម្ពផ្សាយជាភាសាខ្មែរលើកទី១

## អ្នកនិពន្ធ : តាម៉ុតស៊ូ ហូហ្ស៊ុយមី Tamotsu HOZUMI

លោក តាម៉ុតស៊ូ ហូហ្ស៊ុយមី កើតនៅឆ្នាំ១៩៤៧ នាក្រុងសាប៉ូរ៉ូ ប្រទេសជប៉ុន។ លោកបានបញ្ចប់ការសិក្សាផ្នែកអក្សរសាស្ត្រនៅមហាវិទ្យាល័យសិល្បៈនៃសកលវិទ្យាល័យវ៉ាសេដា Waseda University។ លោកទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់សេដ្ឋកិច្ចពីសាលាច្បាប់វ៉ាសេដា។ បន្ទាប់ពីបានធ្វើការងារក្នុងក្រុមហ៊ុនបោះពុម្ពផ្សាយ លោកហូហ្ស៊ុយមីបានបង្កើតក្រុមហ៊ុន Medialynx Japan Co., Ltd នៅខែវិច្ឆិកា ឆ្នាំ១៩៩៧ ហើយសព្វថ្ងៃលោកមានតួនាទីជាប្រធាននាយក។ Medialynx ជាភ្នាក់ងារគ្រប់គ្រងការងារសិទ្ធិអ្នកនិពន្ធដែលបានចុះបញ្ជីជាមួយភ្នាក់ងារកិច្ចការវប្បធម៌។ លោកជាសមាជិកគណៈកម្មាធិការសិទ្ធិអ្នកនិពន្ធ និងសិទ្ធិការបោះពុម្ពផ្សាយនិងជាទីប្រឹក្សានៃសមាគមអ្នកបោះពុម្ពសៀវភៅជប៉ុន។

**ស្នាដៃបោះពុម្ពផ្សាយ:** Heiko yunyu no horitsuron-chosakubutsu megutte (Legal Theory of Parallel Imports–Concerning Copyrighted Works), 1997, Tokyo Nunoi Shuppan; Kigyohomu to kokusaika (Business Affairs and Internationalization),1997, joint authors, Waseda University Graduate School Publishing Committee Kyarakuta- hakuso2000 (White Paper on Characters 2000), joint authors, 1999, Sogo Unicom; Shuppan keiyaku handobukku (Publishing Contract Handbook), 1997; Gaikokugoban/kokusai kyodo shuppan manual (Foreign Language Version of the International Joint Publishing Manual), 1996; Honyaku shuppan no tebiki (Translation Publishing Manual), 1989 (all of the latter were collaborative works published by the Japan Book Publishers Association.). លើសពីនេះហូហ្ស៊ុយមី បានបោះផ្សាយសៀវភៅបកប្រែមានរូបភាព។ល។

## អ្នកបកប្រែ : លោកស្រី ជៀង យ៉ារិន

លោកស្រីកើតនៅថ្ងៃទី២០ ខែមិនា ឆ្នាំ១៩៥៧ នៅក្រុងភ្នំពេញ ប្រទេសកម្ពុជា។ ឆ្នាំ១៩៨៩ លោកស្រីបានបញ្ចប់ការសិក្សាភាសាបារាំងផ្នែក Le Français du Secrétariat Commercial នៅសាលា Alliance Française នាក្រុងភ្នំពេញ និងឆ្នាំ១៩៩៤បានបញ្ចប់ការសិក្សាភាសាអង់គ្លេសផ្នែក General English Program with an English Proficiency Rating of Advanced នៅសាលា Australian Centres for Education នាក្រុងភ្នំពេញ។ លោកស្រីជាអតីតមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ តែចុងឆ្នាំ១៩៩១បានលាឈប់និងទៅបម្រើការងារនៅអង្គការកម្មវិធីអភិវឌ្ឍសហប្រជាជាតិ UNDP។ លោកស្រីក៏ធ្លាប់បម្រើការងារនៅក្រុមហ៊ុនជប៉ុនឈ្មោះ MARUBENI CORPORATION និងជានិយោជិតក្រុមហ៊ុនសែលកម្ពុជាពីឆ្នាំ១៩៩៣-២០០០។ ដោយសារមានសេចក្តីស្រឡាញ់វប្បធម៌ជាតិដ៏ជ្រាលជ្រៅលោកស្រីបានចំណាយពេលវេលាជាច្រើនជួយស្វាមីក្នុងការសិក្សាស្រាវជ្រាវ និងសរសេរឯកសារពាក់ព័ន្ធវិស័យវប្បធម៌ និងបានជួយព្រាងច្បាប់សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល។

**ស្នាដៃ:** សហការជាមួយស្វាមី និពន្ធនិងបោះផ្សាយសៀវភៅ "ខ្លែងខ្មែរ" នាឆ្នាំ២០០២។

## អ្នកគូបតែងលម្អ: លោកតារ៉ូ ហ្គោមី Taro GOMI

លោកកើតនៅឆ្នាំ ១៩៤៥ នាទីក្រុងតូក្យូ។ លោកបានសិក្សានៅវិទ្យាស្ថានរចនា Kuwazawa។ លោកបានបោះពុម្ពសៀវភៅស្តីពីរូបភាពជាង ៣០០សៀវភៅ ហើយសៀវភៅភាគច្រើនក្នុងចំណោមសៀវភៅរូបភាពខាងលើត្រូវបានបោះពុម្ពនៅក្រៅប្រទេស។ លោកតារ៉ូហ្គោមីមានឈ្មោះល្បីជាជនជាតិជប៉ុនខាងការតុបតែងលម្អសៀវភៅរូបភាព។ ជាអ្នកទទួលបោះពុម្ពសៀវភៅរង្វាន់ជ័យលាភីវប្បធម៌របស់ Sankei កុមារ, "Robo no Ishi" និងសៀវភៅផ្សេងៗ ជាច្រើនទៀត។ លើសពីនេះទាក់ទងនឹងសៀវភៅរូបភាព លោកបានច្នៃប្រឌិតបង្កើតថ្មីជាច្រើនប្លែកៗនៅក្នុងកិច្ចការបោះពុម្ពសៀវភៅដោយរាប់បញ្ចូលការងាររចនាលម្អនៅក្នុងការិយាល័យនិងការងារបន្ថែមទៀតដូចជាការសរសេរសៀវភៅការនិយាយជាសាធារណៈ និងការថតរូប។

លោកធ្វើជាអ្នកតំណាងស្នាដៃជាច្រើនទៀតរួមមាន Minna unchi (Everything Is Poop), Kingyo ga nigeta (My Goldfish Ran Away) សៀវភៅទាំងពីរនេះត្រូវបានបោះផ្សាយដោយ Fukuinkan Shoten; Saru, rururu (Monkey-key-key), Ehonkan; Kotoba zukan" (តុបតែងលម្អសៀវភៅវចនានុក្រម), Kaiseisha; Rakugaki ehon (សៀវភៅរូបភាព Doodling Picture Book), Bronze Shinsha។

# សៀវភៅ
# សិទ្ធិអ្នកនិពន្ធ
# អ្នកស្រុកអាស៊ី



បោះពុម្ពផ្សាយជាភាសាខ្មែរលើកទី១ ឆ្នាំ២០០៩

ISBN-9789995089115

9 789995 089115